# គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល ដើម្បីតាមដាននូវ
# សូចនាកររបស់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

**NGO Committee for the Monitoring of 3rd CDCF Indicators**

*NGO Committee*

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១១

## សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីការត្រួតពិនិត្យតាមដាន សូចនាករតាមដានរួមគ្នាដែលបានឯកភាពក្នុងវេទិកាកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍កម្ពុជាលើកទី៣ សម្រាប់ដាក់ជូនកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC) លើកទី១៨

**មាតិកា**

**សេចក្តីសង្ខេប** ........ ១
ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងការរៀបចំរបាយការណ៍ពាក់កណ្តាលអណ្តត្តិនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ចាប់ពីខែ មេសា ដល់ ខែកញ្ញា ឆ្នាំ២០១១........ ៧
វិស័យអប់រំ ........ ៩
វិស័យកំណែទម្រង់ដីធ្លី ........ ១៦
វិស័យព្រៃឈើ........ ២២
កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ........ ២៥
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តម្លាភាពថវិកា និងការពិនិត្យមើលពីសាធារណជន ........ ២៨
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្ម ........ ៣៤
**ឧបសម្ព័ន្ធ**........ ៣៨
បញ្ហាឆ្លងដែននៃការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីក្នុងតំបន់ទន្លេមេគង្គ ........ ៣៩
សេចក្តីថ្លែងការណ៍រួមរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំពោះសេចក្តីព្រាងលើកទី២ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល........ ៤៤

## សេចក្តីសង្ខេប

អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC)ដែលជាឱកាសដ៏វិសេសវិសាលមួយដើម្បី ពិនិត្យ និងពិភាក្សាវឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួម និងសកម្មភាពដែលបានព្រមព្រៀងគ្នានៅឯកិច្ចប្រជុំ វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា( CDCF ) នាខែមិថុនា ឆ្នាំ២០១០ដែលរួមមាន: (១) យុទ្ធសាស្រ្តជាតិគាំពារសង្គមដោយធានានូវប្រសិទ្ធិភាពនៃការអនុវត្ត (២) សមាហរណកម្មនៃការធ្វើផែនការយុទ្ធសាស្រ្ត ការរៀបចំថវិកា និងការគ្រប់គ្រងជំនួយ (៣) ប្រសិទ្ធិភាពនៃយន្តការកិច្ចពិភាក្សាភាពជាដៃគូ និង (៤) របៀបវារៈផ្សេងៗ។

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបខ្លឹមសារសំខាន់ៗដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍នីមួយៗ នៅក្នុងសេចក្តីថ្លែងការណ៍ ឬរបាយការណ៍តាមដានវឌ្ឍនភាពចំរុះវិស័យនេះ។

***តួនាទីរបស់សង្គមស៊ីវិលនៅក្នុងដំណើរការរៀបចំដំណើរការអភិវឌ្ឍន៍ជាតិ និងត្រួតពិនិត្យតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងកថាខ័ណ្ឌទី ៣៨៧ នៃផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដូច្នេះការប្តេជ្ញាចិត្តនេះគប្បីសម្រេចឱ្យបាននៅក្នុងការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិនៃផយអជ បច្ចុប្បន្នកម្ម ដែលនឹងចាប់ផ្តើមក្នុងឆ្នាំ ២០១១នេះ។*** បទពិសោធន៍នានាពាក់ព័ន្ធនឹងការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងដំណើរការរៀបចំផយអជ*បច្ចុប្បន្នកម្ម ២០០៩-២០១៣* បង្ហាញថា ពួកគាត់បានជួបប្រទះបញ្ហាប្រឈមមួយចំនួនរួមមានៈ ការផ្តល់ពេលវេលាមិនទាន់គ្រប់គ្រាន់សម្រាប់ការប្រមូល និងផ្តល់មតិយោបល់ អវត្តមាននូវសិក្ខាសាលពិគ្រោះយោបល់ថ្នាក់ជាតិចុងក្រោយ និងមានកិច្ចប្រជុំក្រុមការងារបច្ចេកទេសតែបីក្រុម ប៉ុណ្ណោះ (រួមមានសុខាភិបាល អប់រំ និង ដីធ្លី) ដែលប្រជុំ និងមានរបៀបវារៈស្តីពីការរៀបចំតាក់តែងធាតុចូលតាមផ្នែកនីមួយៗ សម្រាប់ *ផយអជ បច្ចុប្បន្នកម្ម។* ដើម្បីឱ្យមានការចូលរួមកាន់តែទូលំទូលាយពីសំណាក់អង្គការសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធនានា នៅក្នុងដំណើរការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិនៃ *ផយអជ បច្ចុប្បន្នកម្ម* នាពេលខាងមុខនេះ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) សូមស្នើឱ្យរាជរដ្ឋាភិបាល ដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ គិតគូរពិចារណាលើអនុសាសន៍មួយចំនួនដូចខាងក្រោមៈ (១) គួររៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសដោយដាក់បញ្ចូលនូវរបៀបវារៈស្តីពីការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិនៃ *ផយអជ បច្ចុប្បន្នកម្ម* (២) គួរផ្សព្វផ្សាយឯកសារដែលពាក់ព័ន្ធនឹងដំណើរការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិនៃ *ផយអជ បច្ចុប្បន្នកម្ម* ឱ្យបានទូលំទូលាយ (៣) គួរផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ផ្តល់មតិយោបល់ (និងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ) និង (៤) គួររៀបចំឱ្យមានការចូលរួមរបស់អង្គការសង្គមស៊ីវិលផ្សេងទៀត និងស្ថាប័នពាក់ព័ន្ធនានា (ក្រុមប្រឹក្សាឃុំ សង្កាត់ និងរដ្ឋសភាជាតិ) នៅក្នុងដំណើរការត្រួតពិនិត្យតាមដាននេះ។

***អង្គការមិនមែនរដ្ឋាភិបាលដែលត្រួតពិនិត្យតាមដានសូចនាករវិស័យអប់រំ សូមកោតសរសើរនូវកិច្ចខិតខំប្រឹងប្រែងជាប្រចាំ របស់ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍វិស័យអប់រំក្នុងការធ្វើឱ្យមានវឌ្ឍនភាពគួឱ្យកត់សំគាល់ឆ្ពោះទៅរកការសម្រេចបានគោលដៅការអប់រំសម្រាប់ទាំងអស់គ្នានៅក្នុងឆ្នាំ២០១៥។ ទោះជាយ៉ាងនេះក្តី គុណភាពអប់រំនៅតែជាការព្រួយបារម្ភដ៏ធំមួយសម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅក្នុងប្រទេសកម្ពុជានាពេលអនាគត។*** ដើម្បីដោះស្រាយបញ្ហានេះ ទាំងក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍគប្បីធានាថាៈ (១) មានគ្រូបង្រៀនដែលមានគុណភាព និងការលើកទឹកចិត្តគ្រប់គ្រាន់ទាំងសម្រាប់សាលារៀននៅជនបទ និងតំបន់ដាច់ស្រយ៉ាល។ ការបណ្តុះបណ្តាលក្នុងពេលផ្តល់សេវាកម្មឱ្យបានញឹកញាប់ និងការផ្តល់ប្រាក់បៀវត្សឱ្យបានសមរម្យ/ដែលអាចរស់បានចាំបាច់គួរគិតគូពិចារណា។ ជាងនេះទៅទៀត វេទិកាសម្រាប់គ្រូបង្រៀនបង្ហាញពីទស្សនៈ និងការព្រួយបារម្ភរបស់ខ្លួនចាំបាច់ត្រូវបង្កើតឡើង ។ (២) ប្រកាសស្តីពីការទប់ស្កាត់ការបង់ថ្លៃសេវាកម្មក្រៅផ្លូវការ ដែលជាឧបសគ្គដ៏ចំបងចំពោះសិទ្ធិទទួលបានការសិក្សា ការបន្តការសិក្សា និងគុណភាពអប់រំរបស់សិស្សត្រូវតែពង្រឹង។ (៣) សាលារៀនគ្រប់កំរិតថ្នាក់ដែលមានបំពាក់ទៅដោយឧបករណ៍រៀន និងបង្រៀនគ្រប់គ្រាន់ និងសមស្របមានចំនួនគ្រប់គ្រាន់ដើម្បីធានាបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នា និង (៤) កែលម្អការប្រឡងជាលក្ខណៈស្តង់ដារដើម្បីវាយតម្លៃពីលទ្ធផលនៃការសិក្សារៀនសូត្ររបស់សិស្ស យ៉ាងហោចណាស់ក៏នៅថ្នាក់ទី ៣ ទី ៦ ទី ៩ និងទី ១២ ដែរ។

***អង្គការមិនមែនរដ្ឋាភិបាលក៏សូមកោតសរសើរផងដែរ ចំពោះវឌ្ឍនភាពដែលធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបន្ត ពង្រឹងក្របខណ្ឌគោលនយោបាយដីធ្លី ទោះបីជាយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលសង្កេតឃើញថា វឌ្ឍនភាពបន្ថែមទៀត គួរតែអាចធ្វើទៅបានដើម្បីធានាសុវត្ថិភាពដីធ្លីសម្រាប់សហគមន៍ជនជាតិដើមភាគតិច និង ប្រជាពលរដ្ឋងាយនឹងរងគ្រោះ។*** រាជរដ្ឋាភិបាលកម្ពុជាបានពន្លឿនការដាក់បញ្ចូលទិន្នន័យ និងការចែកចាយប័ណ្ណកម្មសិទ្ធិដីធ្លី។ ទោះជាយ៉ាងណាក្តី ការពន្លឿនកិច្ចដំណើរការចុះបញ្ជីដីធ្លីដោយមានការយកចិត្តទុកដាក់ច្បាស់លាស់ទៅលើគ្រួសារក្រីក្រ និងជនងាយរងគ្រោះនៅទីក្រុង និងជនបទគឺ ជាកត្តាចាំបាច់បំផុត ដើម្បីធ្វើអោយប្រសើរឡើងនូវសុវត្ថិភាពកាន់កាប់ដីធ្លីរបស់ពួកគេ ជាពិសេស ប្រជាជនក្រីក្ររស់នៅក្នុងទីក្រុងដែលមួយចំនួនកំពុងបន្តស្ថិតនៅក្រោមការគម្រាមកំហែងនៃការតាំងលំនៅឋានថ្មីដោយមិនមានការស្ម័គ្រចិត្ត។ ការផ្តល់ប័ណ្ណកម្មសិទ្ធិ សមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចត្រូវបានពន្យារពេលបន្ថែមទៀត ខណៈ ដែលសហគមន៍ជនជាតិដើមភាគតិចបន្តបាត់បង់ដីធ្លី និងធនធានធម្មជាតិរបស់ខ្លួន។ អាស្រ័យហេតុនេះ អង្គការមិនមែនរដ្ឋាភិបាលសូមជម្រុញអោយរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវវឌ្ឍនភាពធំដុំដែលអាចវាស់វែងបានដើម្បីការពារសហគមន៍ជនជាតិដើមភាគតិច។

***ពាក់ព័ន្ធទៅនឹងសូចនាករតាមដានរួមសម្រាប់វិស័យព្រៃឈើ អង្គការមិនមែនរដ្ឋាភិបាល បានសង្កេតឃើញថា នៅក្នុងរយៈពេលរាយការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តថែមទៀតនៅក្នុងការដាំព្រៃឈើឡើងវិញលើដីរិចរិលបានលើសពីផែនការដែលបានកំនត់។ ប៉ុន្តែ តួលេខអំពីផ្ទៃដីដាំព្រៃឈើដែលត្រូវបានដាំឡើងវិញនេះត្រូវបានគេរាប់បញ្ចូលទាំងផ្ទៃដីដែលត្រូវបាន " ដាំព្រៃ ឈើឡើងវិញ" ជាលក្ខណៈចំការឯកវប្បកម្ម និងដំណាំកសិ-ឧស្សាហកម្ម។*** អង្គការមិនមែនរដ្ឋាភិបាល មានការបារម្ភថា ព្រៃឈើនៅកម្ពុជាកំពុងត្រូវបានគេបំលែង ដើម្បីបង្កើនផ្ទៃដីសម្រាប់ការអភិវឌ្ឍន៍ដំណាំឯកវប្បកម្ម តួយ៉ាងដូចជាសម្បទានដីសេដ្ឋកិច្ច ដែលជាកត្តានាំមុខមួយនៃកត្តានាំមុខចម្បង៧នៃការកាប់បំផ្លាញព្រៃឈើនៅកម្ពុជា។ បន្ថែមលើនេះទៀត សម្បទានដីសេដ្ឋកិច្ចគឺជាឧបសគ្គមួយដ៏ធំ ចំពោះដំណើរការទៅមុខរបស់កម្មវិធីស្តីពី ការកាត់បន្ថយការបំភាយឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងការរេចរិលព្រៃឈើ (REDD) នៅកម្ពុជាពីព្រោះថា កិច្ចការពារព្រៃឈើធម្មជាតិ និងធនធានធម្មជាតិគឺសំខាន់ក្រៃលែងចំពោះ REDD និង គឺជាមូលដ្ឋានគ្រឹះដើម្បីសម្រេចបាននូវនិរន្តរភាពបរិស្ថាន។

***អង្គការមិនមែនរដ្ឋាភិបាលក៏សូមស្វាគមន៍ផងដែរ ចំពោះឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពី ការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។*** ដើម្បីឱ្យវិស័យនេះបានល្អប្រសើរឡើង រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានឯកភាពគ្នារៀបចំច្បាប់មូលដ្ឋានសំខាន់៧បីដែលទាក់ទងនឹងមុខងារតុលាការ ព្រមទាំងបង្កើតនូវតុលាការគំរូ៤ ដោយបានដាក់ច្បាប់សំខាន់៧ និងតុលាការគំរូទាំង៤នោះទៅក្នុងសូចនាករតាមដានរួមគ្នា ដែលបានបង្ហាញយ៉ាងច្បាស់ពីការសន្យានូវការអនុវត្តជាក់ស្តែងក្នុងវិស័យនេះ។ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) សង្កេតឃើញថាមានការរីកចំរើនមួយចំនួនដែល ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងយុត្តិធម៌បានអនុវត្តក្នុងរយៈកាលប៉ុន្មានខែកន្លងមកនេះ។ ទោះបីជាយ៉ាងណា ការទទួលស្គាល់នូវសមិទ្ធផលជាច្រើនដែលបានធ្វើឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង យុត្តិធម៌ ដោយមានការចូលរួមពីដៃគូអភិវឌ្ឍន៍ សម្ព័ន្ធអង្គការគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ដែលបានធ្វើការឃ្លាំមើលដំណើរការកែទម្រង់ប្រព័ន្ធយុត្តិធម៌បានស្នើឡើងនូវអនុសាសន៍មួយចំនួនសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពិចារណា។ អនុសាសន៍ទាំងនោះរួមមាន ការអនុម័តនូវច្បាប់មូលដ្ឋានសំខាន់៧ទាំងបីឱ្យបាននៅត្រឹមឆ្នាំ២០១១ រួមជាមួយនឹងការផ្សព្វផ្សាយច្បាប់ទាំងនេះ ការធានាបាននូវការគាំទ្រគ្រប់គ្រាន់ទាំងហិរញ្ញវត្ថុ

និងបច្ចេកទេសសម្រាប់គម្រោងតុលាការគំរូ និងការផ្តល់នូវមូលនិធិដែលមាននិរន្តរភាពសម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការផ្នែកច្បាប់ និងដែលទាក់ទងនឹងប្រជាជនក្រីក្រ និងងាយរងគ្រោះ។

***អង្គការមិនមែនរដ្ឋាភិបាល សូមកោតសរសើររាជរដ្ឋាភិបាលកម្ពុជា ចំពោះវឌ្ឍនភាពយ៉ាងច្រើនលើការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ (ជាពិសេស តម្លាភាពថវិកាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុល លទ្ធកម្មសាធារណៈ និងទម្រង់នៃការធ្វើរបាយការណ៍ទៅកាន់ និងការទំនាក់ទំនងជាមួយសាធារណជន) ហើយយើងខ្ញុំជឿជាក់ថា នៅមានសកម្មភាពច្រើនបន្ថែមទៀតដែលអាចអនុវត្តបានក្នុងឆ្នាំ២០១១ ដើម្បីបន្តកែលម្អបន្ថែមទៀតនូវតម្លាភាពដំណើរការថវិកា។*** វឌ្ឍនភាពដែលសម្រេចបានដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ដែលត្រូវបានសង្កេតដោយអង្គការមិនមែនរដ្ឋាភិបាលមកទល់នឹងខែមីនា ឆ្នាំ២០១១ រួមមានការផ្សព្វផ្សាយឱកាសលទ្ធកម្មសាធារណៈនៅលើគេហទំព័រក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការកសាងរបាយការណ៍តាមដានបំណុលប្រចាំខែ ត្រីមាស និងឆ្នាំ និងការបញ្ចេញនូវរបាយការណ៍ពាក់កណ្តាលឆ្នាំនៃការអនុវត្តថវិកាឆ្នាំ២០១០នៅលើគេហទំព័រ របស់ក្រសួង និងសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១១ ដល់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាសម្រាប់ធ្វើការវិភាគដើម្បីបានជាធាតុចូលសម្រាប់ការពិភាក្សាសភា។ អង្គការមិនមែនរដ្ឋាភិបាលជឿជាក់ថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ អាចនឹងបន្តកែលម្អតម្លាភាពបន្ថែមទៀតនៃដំណើរការថវិកាតាមរយៈការបញ្ចប់គេហទំព័រលទ្ធកម្មសាធារណៈ ការផ្សព្វផ្សាយរបាយការណ៍តាមដានបំណុល និងការផ្តល់កិច្ចសន្យា ការផ្សព្វផ្សាយតួលេខថវិកាលម្អិតតាមក្រសួងនៅក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងការផ្សព្វផ្សាយរបាយការណ៍សវនកម្មឆ្នាំ២០០៧ ២០០៨ និង២០០៩ ក្នុងឆ្នាំ ២០១១នេះ។

***សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT) សូមសម្តែងនូវការកោតសរសើរចំពោះវឌ្ឍនភាពសំខាន់ៗលើគ្រប់ជ្រុងទាំងអស់នៃការអភិវឌ្ឍឧស្សាហកម្មនិស្សារណកម្ម ជាពិសេសការបង្កើតឱ្យមានក្របខ័ណ្ឌច្បាប់ និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។ ប៉ុន្តែ គេពុំឃើញមានការពិគ្រោះយោបល់ជាសាធារណៈត្រូវបានធ្វើឡើងឡើយ។*** យោងតាមរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ច្បាប់ និងបទបញ្ញត្តិមួយចំនួនត្រូវបានរៀបចំ និងបញ្ចប់។ ទោះបីយ៉ាងនេះក្តី មិនមានឯកសារគតិយុត្តិណាមួយត្រូវបានផ្សព្វផ្សាយដល់សាធារណជន និងសង្គមស៊ីវិលសម្រាប់ការពិគ្រោះយោបល់ឡើយមកទល់នឹងពេលនេះ។ លើសពីនេះទៀត មិនមានវឌ្ឍនភាពណាដែលត្រូវបានរាយការណ៍អំពីការប្តេជ្ញាចិត្តក្នុងការទទួលយកគោលការណ៍គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ក្រៅពីការផ្សព្វផ្សាយចំណូលពីឧស្សាហកម្មនិស្សារណកម្មជាតួលេខសរុបមួយនៅក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) លើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ហេតុដូចនេះ ដោយសារការគ្រប់គ្រងចំណូលធនធាននេះមានសារៈសំខាន់ចំពោះការអភិវឌ្ឍរបស់កម្ពុជា សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធានសូមអំពាវនាវដល់រាជរដ្ឋាភិបាល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ចាត់វិធានការណ៍ដើម្បីធានាឱ្យមានការចូលរួមពីសាធារណជន និងអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីពន្ធប្រេង ច្បាប់សារពើពន្ធលើការធ្វើអាជីវកម្មរ៉ែ និងច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មប្រេង ពោលគឺតាមរយៈការផ្សព្វផ្សាយឯកសារសេចក្តីព្រាងច្បាប់ទាំងនេះ ព្រមជាមួយការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការធ្វើការពិគ្រោះយោបល់ជាសាធារណៈ ហើយសូមឱ្យមានការពិចារណាអំពីសមាជិកភាព EITI ជាកត្តាអាទិភាពមួយនៅក្នុងផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសអន្តរ

ក្រសួង ហើយព្រមទាំងប្រកាន់យកគោលការណ៍ EITI ដោយធ្វើឱ្យប្រសើរឡើងនូវភាពទៀងទាត់ និងភាពគ្រប់ជ្រុងជ្រោយនៃការរាយការណ៍អំពីចំណូលដែលបានមកពីឧស្សាហកម្មនិស្សារណកម្មនៅក្នុង TOFE លើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សម្ព័ន្ធទន្លេកម្ពុជាសូមសំដែងនូវសារទរដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះវឌ្ឍនភាពលើវិស័យជាច្រើននៃអនុវិស័យជលផល និងការអភិវឌ្ឍន៍ជំរើសថាមពល ដូចជាការអនុវត្តន៍កំណែទម្រង់ច្បាប់ជលផល ការលើកកម្ពស់ថាមពលបែបវិមជ្ឈការក្នុងប្រទេសកម្ពុជា និងការឆ្លើយតបទៅនឹងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តភាពនៃអាងទន្លេមេគង្គ ឆ្នាំ១៩៩៥។ ប៉ុន្តែបញ្ហាឆ្លងដែននៃការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីដែលស្ទើឡើងនៅតាមដងទន្លេមេនៃទន្លេមេគង្គ នៅតែមិនទាន់បានដាក់បញ្ចូលក្នុងវិស័យជលផលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (*ផយអជ*) បច្ចុប្បន្នកម្ម ២០០៩-២០១៣ ក៏ដូចជាដាក់បញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់រាជរដ្ឋាភិបាលថ្នាក់ជាតិតាមរយៈ វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៏កម្ពុជា(CDCF) និងកិច្ចប្រជុំរបស់គណៈ-កម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ (GDCC)។ សំណើសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាបូរីនៅប្រទេសឡាវអាចនឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានមកដល់ប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះទន្លេមេគង្គ និងទន្លេសាបដូចជា ផលប៉ះពាល់លើផ្នែកជលផល លំហូរល្បាប់ និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅផ្នែកខាងក្រោមនៃទន្លេមេគង្គ។ ដូច្នេះ ដើម្បីសារៈសំខាន់នៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការថែរក្សាធនធានជលផល សម្ព័ន្ធទន្លេកម្ពុជាសូមស្នើឱ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ធ្វើការពិចារណាដាក់បញ្ចូលបញ្ហានេះទៅក្នុងកិច្ចប្រជុំរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងទទួលយកអនុសាសន៍នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្ររបស់គណៈកម្មការទន្លេមេគង្គ ចំពោះការពន្យាពេលយ៉ាងហោច ១០ឆ្នាំសំរាប់ការសម្រេចចិត្តលើការអនុម័តឱ្យមានការសាងសង់ទំនប់វារីអគ្គិសនីទាំង ១១ នៅតាមទន្លេមេនៃទន្លេមេគង្គ។ ប្រសិនបើមិនមានភស្តុតាងច្បាស់លាស់ស្របតាមស្តង់ដារអន្តរជាតិដែលបញ្ជាក់ពីការដោះស្រាយសំណងយុត្តិធម៌ចំពោះសហគមន៍ដែលរងផលប៉ះពាល់ទេ ផែនការសាងសង់ទំនប់នៅតាមទន្លេមេនៃទន្លេមេគង្គនេះ ជាពិសេសទំនប់វារីអគ្គិសនីសាយ៉ាបូរី មិនគួរត្រូវបានអនុម័តពីរាជរដ្ឋាភិបាលកម្ពុជាឡើយ។

***អង្គការសង្គមស៊ីវិល ដែលរួមមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា សូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការរៀបចំកិច្ចពិគ្រោះយោបល់ជាមួយយើងខ្ញុំជាច្រើនលើកទៅលើសេចក្តីព្រាងច្បាប់លើកទីមួយនៃច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីព្រាងច្បាប់លើកទីពីរនៃច្បាប់នេះដែលកំពុងត្រូវបានដាក់បញ្ជូនទៅគណៈរដ្ឋមន្ត្រីសម្រាប់ការពិភាក្សា និងអនុម័តនោះ យើងខ្ញុំសូមគូសបញ្ជាក់អំពីក្តីបារម្ភធំៗចំនួនបីនៅក្នុងសេចក្តីព្រាងច្បាប់បច្ចុប្បន្ននេះ ដែលត្រូវបានចាត់ទុកថាពិបាកនឹងទទួលយកបាន។*** ក្តីបារម្ភទាំងបីរួមមាន: (១)ការចុះបញ្ជីត្រូវធ្វើឡើងជាកាតព្វកិច្ច និងមានភាពស្មុគស្មាញមិនមែនដោយស្ម័គ្រចិត្ត និងមិនមានភាពងាយស្រួល (២)ពុំមានដំណើរការប្តឹងឧទ្ធរណ៍សម្រាប់ការបដិសេធទៅលើការចុះបញ្ជី (៣)ពុំមានការកំណត់និយមន័យទៅលើវាក្យស័ព្ទសំខាន់ៗនៅក្នុងច្បាប់ និងផ្នែកជាច្រើនពុំទាន់មានភាពច្បាស់លាស់នៅឡើយ។ ចំពោះមុខនៃការបារម្ភទាំងនេះ ថ្ងៃនេះយើងខ្ញុំទាំងអស់គ្នាមានជំហរួមមួយ បើទោះបីជាយើងមានវិធីសាស្ត្រផ្សេងៗគ្នាក្នុងការរកដំណោះស្រាយចំពោះការព្រួយបារម្ភជុំវិញសេចក្តីព្រាងច្បាប់នេះក៏ដោយ ក៏យើងខ្ញុំបានឯកភាពគ្នាថា សេចក្តីព្រាងច្បាប់ដែលស្ថិតក្នុងទម្រង់បច្ចុប្បន្ននេះគឺ **នៅមិនទាន់អាចទទួលយកបានឡើយ**។ ហេតុដូចនេះហើយ យើងខ្ញុំជាអង្គការមិនមែនរដ្ឋាភិបាល និងសមាគមសូមអំពាវនាវ (*សូមអានលំអិតសេចក្តីថ្លែងការណ៍នេះនៅក្នុងឧបសម្ព័ន្ធ*)ជាសមូហភាព និងដោយការ

គោរពចំពោះរាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើការពិចារណាឡើងវិញទៅលើសំណើសំខាន់ៗរបស់យើងខ្ញុំ និង សូមដាក់បញ្ចូលសំណើរ ឬយោបល់ទាំងនោះទៅក្នុងសេចក្តីព្រាងច្បាប់ លើកទីបីឬចុងក្រោយ។ យើងក៏សូមស្នើសុំផងដែរឱ្យមានការផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីព្រាងច្បាប់លើកទីបី ឬចុងក្រោយនោះ មុនពេលសេចក្តីព្រាងច្បាប់នេះត្រូវបានឯកភាពដោយគណៈរដ្ឋមន្ត្រី និងអនុម័តដោយរដ្ឋសភាជាតិ។

# ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ចាប់ពីខែមេសា ដល់ ខែកញ្ញា ឆ្នាំ២០១១

## ១. សេចក្តីផ្តើម

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) គឺជាសមាជិកមួយនៃក្រុមការងារបច្ចេកទេសផែនការ និងការកាត់បន្ថយភាពក្រីក្រ (TWG-PPR) និង ដើរតួនាទីជាអ្នកតំណាង ក៏ដូចជាអ្នកសម្របសម្រួលសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ចម្រុះវិស័យទៅលើការចូលរួមក្នុងដំណើរការរៀបចំ និងអនុវត្តផែនការជាតិ។ សេចក្តីថ្លែងការណ៍ចំពោះសូចនាករតាមដានរួមស្តីពីផែនការ និងការកាត់បន្ថយភាពក្រីក្រនេះត្រូវបានរៀបចំដោយ NGO Forum ដោយមានការប្រឹក្សាយោបល់ជាមួយអង្គការ CCC និង MEDiCAM ក៏ដូចជា អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ និងក្រោយពេលលទ្ធផលនៃកិច្ចប្រជុំរបស់អនុក្រុមការងារស្តីពីការរៀបចំសូចនាករត្រួតពិនិត្យតាមដានរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣នៃក្រុមការងារបច្ចេកទេសផែនការ និងការកាត់បន្ថយភាពក្រីក្រ។

## ២. សូចនាករតាមដានរួម

| ស្ថាប័នសម្របសម្រួល: **ក្រសួងផែនការ**<br>ស្ថាប័នអនុវត្ត: **ក្រសួងផែនការ** | | | | |
|---|---|---|---|---|
| លទ្ធផលរយៈពេលមធ្យម | ធាតុចេញ | សូចនាករធាតុចេញ | សកម្មភាព: ចំនុចដៅសកម្មភាព | សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ |
| ពង្រឹងសមត្ថភាពក្រសួងផែនការ និងក្រសួង/ ស្ថាប័នពាក់ព័ន្ធក្នុងការតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ រួមទាំងការរៀបចំរបាយការណ៍ការត្រួតពិនិត្យការអនុវត្តន៍ | ១. ផែនការយុទ្ធសាស្ត្រក្រសួងផែនការ ២០០៩-២០១៣<br>២. របាយការណ៍ការត្រួតពិនិត្យការអនុវត្តន៍ពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១១ | ១. តម្រឹមធនធានដែលមានទាំងធនធានរបស់ដៃគូអភិវឌ្ឍន៍ទាំងខាងរាជរដ្ឋាភិបាលដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការក្នុងឆ្នាំ២០១០-២០១១ ដែលនឹងត្រូវបញ្ចោក់ក្នុងខែមិថុនា ឆ្នាំ២០១០<br>២. របាយការណ៍ត្រួតពិនិត្យការអនុវត្តន៍ពាក់កណ្តាលអាណត្តិនៃ*ផយអជ* នឹងត្រូវបញ្ចប់ក្នុងខែកញ្ញា ឆ្នាំ២០១១ | .......<br>៥. រៀបចំនិងបញ្ចប់របាយការណ៍ការត្រួតពិនិត្យការអនុវត្តន៍ពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ក្នុងខែកញ្ញា ឆ្នាំ២០១១ ដោយមានការ ជួយជ្រោមជ្រែងរបស់អនុក្រុមការងារតាមដាន និងវាយតម្លៃនៃក្រុមការងារបច្ចេកទេសផែនការ និងកាត់បន្ថយភាពក្រីក្រ | ១. បញ្ចប់និងអនុម័តគោលការណ៍ភាពជាដៃគូដើម្បីរៀបចំអភិក្រមគ្រប់គ្រងទូទាំងវិស័យសម្រាប់ក្រសួង ផែនការត្រឹមខែ មិថុនា ឆ្នាំ២០១១<br>២. ធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវ ដើម្បីចាប់ផ្តើមអភិក្រមគ្រប់គ្រងទូទាំង វិស័យសម្រាប់ក្រសួងផែនការ |

## ៣. ការតាមដានវឌ្ឍនភាពនៃការអនុវត្តចំនុចគោលសកម្មភាព

យន្តការដែលប្រើប្រាស់ដោយរាជរដ្ឋាភិបាលកម្ពុជាសម្រាប់រៀបចំសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (*ផយអជ*) បច្ចុប្បន្នកម្ម ២០០៩-២០១៣ និងក្នុងការបង្កលក្ខណៈឱ្យភាគីពាក់ព័ន្ធ (រួមមានៈ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ) ចូលរួមក្នុងដំណើរការរៀបចំផែនការជាតិនេះ គឺយន្តការក្រុមការងារបច្ចេកទេសទាំង ១៩។ ក្នុងចំណោមក្រុមការងារបច្ចេកទេសទាំង ១៩ បច្ចុប្បន្នមានក្រុមការងារបច្ចេកទេសចំនួន ១៦ មានអង្គការមិនមែនរដ្ឋាភិបាលចូលរួមក្នុងយន្តការនេះ ដែលជាលទ្ធផលនៃការកែសម្រួល សេចក្តីណែនាំស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ ដែលទទួលស្គាល់នូវសមាជិកភាពពេញលេញនៃតំណាងអង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិលនៅក្នុងក្រុមការងារបច្ចេកទេស។ អង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់នូវសារៈសំខាន់ និងភាពស្របច្បាប់នៃយន្តការនេះក្នុងការប្រមូលធាតុចូល និងមតិយោបល់ទៅលើការរៀបចំ និងត្រួតពិនិត្យតាមដានការអនុវត្ត *ផយអជ* បច្ចុប្បន្នកម្ម ២០០៩-២០១៣។ អង្គការមិនមែនរដ្ឋាភិបាលសូមកោតសរសើរ និងអបអរសាទរក្រសួងផែនការដែលដើរតួនាទីដឹកនាំសម្របសម្រួលដំណើរការរៀបចំ *ផយអជ បច្ចុប្បន្នកម្ម* ក៏ដូចជា កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងនេះ និងសាម៉ីក្រសួងផ្សេងទៀតក្នុងការបង្កលក្ខណៈងាយស្រួលសម្រាប់អង្គការមិនមែនរដ្ឋាភិបាលចូលរួមក្នុងដំណើរការ តាក់តែងផែនការជាតិនេះ។

ដោយយល់ឃើញនូវបញ្ហាប្រឈមដែលបានជួបប្រទះដោយស្ថាប័នសម្របសម្រួល និងសាម៉ីក្រសួងនានា អង្គការមិនមែនរដ្ឋាភិបាល ក៏បានជួបប្រទះបញ្ហាប្រឈមមួយចំនួនផងដែរនៅក្នុងអំឡុងពេលរៀបចំតាក់តែង *ផយអជ បច្ចុប្បន្នកម្ម* រួមមានៈ ការផ្តល់ពេលវេលាមិនគ្រប់គ្រាន់ក្នុងការប្រមូលធាតុចូលនិងផ្តល់ជាមតិយោបល់ មានការលំបាកក្នុងការទំនាក់ទំនងជាមួយនឹងមន្ត្រីនៅតាមសាម៉ីក្រសួង/ស្ថាប័នមួយចំនួនដែលទទួលខុសត្រូវក្នុងការរៀបចំផ្នែកនីមួយៗសម្រាប់ *ផយអជ បច្ចុប្បន្នកម្ម* អវត្តមាននៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិចុងក្រោយ និងមានកិច្ចប្រជុំក្រុមការងារបច្ចេកទេសតែបីក្រុមប៉ុណ្ណោះ (រួមមាន សុខាភិបាល អប់រំ និង ដីធ្លី) ដែលបានរៀបចំការប្រជុំដោយមានរៀបចំវារៈស្តីពី ការរៀបចំតាក់តែងធាតុចូលសម្រាប់ *ផយអជ បច្ចុប្បន្នកម្ម*។ លើសពីនេះទៀត យន្តការដែលប្រើប្រាស់សម្រាប់រៀបចំ *ផយអជ បច្ចុប្បន្នកម្ម* ក៏មិនសូវបង្កលក្ខណៈងាយស្រួលក្នុងការអនុញ្ញាតិឱ្យមានការចូលរួមទូលំទូលាយពីសំណាក់អង្គការសង្គមស៊ីវិលផ្សេងទៀត និងស្ថាប័នពាក់ព័ន្ធនានាផងដែររួមមានៈ អង្គការសហគមន៍មូលដ្ឋាន គ្រឹះស្ថានឧត្តមសិក្សា សហជីព វិទ្យាស្ថានស្រាវជ្រាវ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងរដ្ឋសភាជាតិ។

## ៤. អនុសាសន៍សម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

ដូចដែលមានចែងនៅក្នុងសូចនាករតាមដានរួម ស្តីពី ផែនការ និងការកាត់បន្ថយភាពក្រីក្រ របាយការណ៍ពាក់កណ្តាលអាណត្តិ នៃ *ផយអជ បច្ចុប្បន្នកម្ម* នឹងត្រូវរៀបចំដោយរាជរដ្ឋាភិបាលនៅក្នុងអំឡុងពេលចាប់ពីខែមេសា ដល់ខែកញ្ញា ឆ្នាំ២០១១ ដោយប្រើប្រាស់នូវអភិក្រមដែលមានលក្ខណៈចូលរួម និងយន្តការដូចគ្នាទៅនឹងពេលដែលរៀបចំតាក់តែង *ផយអជ បច្ចុប្បន្នកម្ម២០០៩-២០១៣*។ ដោយយោង ទៅលើបញ្ហាប្រឈមដែលជួបប្រទះដោយអង្គការសង្គមស៊ីវិល និងដើម្បីញ៉ាំងឱ្យដំណើរការរៀបចំរបាយការណ៍នេះឱ្យមានលក្ខណៈចូលរួមកាន់តែច្រើន អង្គការមិនមែនរដ្ឋាភិបាលសូមស្នើឱ្យរាជរដ្ឋាភិបាល ដែលមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ គិតគូរពិចារណានូវអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- ក្រុមការងារបច្ចេកទេស គប្បីរៀបចំកិច្ចប្រជុំដោយដាក់បញ្ចូលនូវរបៀបវារៈទៅលើការរៀបចំរបាយការណ៍ពាក់កណ្ដាលអាណត្តិនៃ *ផយអជ បច្ចុប្បន្នកម្ម* ដើម្បីពិភាក្សាអំពីធាតុចូល និងមតិយោបល់ពីភាគីពាក់ព័ន្ធដែលរួមមានទាំងអង្គការសង្គមស៊ីវិលសម្រាប់សេចក្ដីព្រាងរបាយការណ៍នេះ។ ជាមួយគ្នាផងដែរ អង្គការមិនមែនរដ្ឋាភិបាលសូមស្នើ ក្រសួងសាមីឬស្ថាប័ននានាឱ្យមានកិច្ចពិភាក្សាបើកទូលាយ និងមានការយោគយល់គ្នាទ្វេទិសជាមួយនឹងអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលតាមរយៈការឆ្លើយតបទៅនឹងយោបល់ឬធាតុចូលរបស់ពួកគេដែលនឹងអាចជួយធានាឱ្យបានថា ពិតជាមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យនៃដំណើរការរៀបចំរបាយការណ៍ពាក់កណ្ដាលអាណត្តិនេះ។
- ក្រសួងសាមី ឬស្ថាប័នពាក់ព័ន្ធនានា និងស្ថាប័នសម្របសម្រួលរបស់រាជរដ្ឋាភិបាលគប្បីចែកផ្សាយជូន សេចក្ដីព្រាងឯកសាររបាយការណ៍ពាក់កណ្ដាលអាណត្តិនៃ *ផយអជ បច្ចុប្បន្នកម្ម និងឯកសារពាក់ព័ន្ធសម្រាប់ដំណើរការនេះ* ឱ្យបានទូលំទូលាយដល់ភាគីពាក់ព័ន្ធជាពិសេសអង្គការសង្គមស៊ីវិល និងផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់ផ្ដល់មតិយោបល់។
- ក្រៅពីអង្គការមិនមែនរដ្ឋាភិបាល គប្បីរៀបចំឱ្យមានការចូលរួមពីអង្គការសង្គមស៊ីវិលពាក់ព័ន្ធផ្សេងទៀតទៅក្នុងដំណើរការរៀបចំតាក់តែងរបាយការណ៍នេះរួមមាន អង្គការសហគមន៍ គ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នសាសនា សហជីព វិទ្យាស្ថានស្រាវជ្រាវនានា និង(យ៉ាងហោចណាស់គណៈកម្មាធិការពាក់ព័ន្ធ)រដ្ឋសភា ។ ដោយសារ រដ្ឋសភាជាតិបានអនុម័ត *ផយអជ បច្ចុប្បន្នកម្ម* ២០០៩-២០១៣ និងមានតួនាទីត្រួតពិនិត្យតាមដានលើការអនុវត្តផែនការនេះ វាមានសារៈសំខាន់ណាស់ដែលថា សមាជិករបស់រដ្ឋសភាបានទទួលព័ត៌មាន និងចូលរួមនៅក្នុងការត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការជាតិដែលនេះជាផ្នែកមួយនៃយន្តការធានានូវគណនេយ្យភាពចំពោះប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងដើម្បីធានាផងដែរនូវតុល្យភាពក្នុងចំណោមស្ថាប័នជាតិ។

**ព័ត៌មានទំនាក់ទំនង:**

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទំនាក់ទំនង:


**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា (The NGO Forum on Cambodia)**

លោក ជា គីមសុង

ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍

ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ៤២៩

ទូរសារលេខ: (៨៥៥-២៣) ៩៩៤ ០៦៣

អ៊ីម៉ែល: ngoforum@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh

អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

# វិស័យអប់រំ

## ១. សេចក្តីផ្តើម

សូចនាករតាមដានរួមថ្មីរបស់វិស័យអប់រំត្រូវបានអនុម័តនៅឯកិច្ចប្រជុំ វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី៣ ថ្ងៃទី២-៣ ខែមិថុនា ឆ្នាំ២០១០ បានឆ្លុះបញ្ចាំងអំពីសារសំខាន់ក្នុងការដោះស្រាយបញ្ហានៃការចុះឈ្មោះចូលរៀន នៅថ្នាក់មធ្យមសិក្សាបឋមភូមិ និងអត្រាឡើងថ្នាក់នៅថ្នាក់បឋមសិក្សា ។ ទោះយ៉ាងណាក៏ដោយ យើងត្រូវការកិច្ចខំ ប្រឹងប្រែងដែលកាន់តែខ្លាំងក្លា មានការសម្របសម្រួល និងមានចិរភាពថែមទៀតដើម្បីធានាបានការលើកកំពស់គុណភាពអប់រំ និងការទទួលបានសេវាអប់រំសម្រាប់កុមារដែលជួបការលំបាក និងប្រជាជនដែលងាយរងគ្រោះផ្សេងទៀត មានដូចជា កុមារពិការ កុមារផ្ទុកមេរោគអេដស៍ កុមារជនជាតិភាគតិច និងកុមារក្រីក្រ ។

## ២. សូចនាករតាមដានរួម

| ស្ថាប័នសម្របសម្រួល : **ក្រសួងអប់រំ យុវជន និងកីឡា**<br>ស្ថាប័នអ្នកអនុវត្ត : **ក្រសួងអប់រំ យុវជន និងកីឡា** | | | | |
|---|---|---|---|---|
| លទ្ធផលរយៈពេលមធ្យម | ធាតុចេញ | សូចនាករធាតុចេញ | សកម្មភាព: ចំនុចដៅសកម្មភាព | សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពបរិញ្ញាប្បទានសហប្រតិបត្តិការ |
| ៣. អត្រាចុះឈ្មោះចូលរៀននៅថ្នាក់មធ្យមសិក្សាបឋមភូមិកើនឡើង | អត្រាឡើងថ្នាក់របស់សិស្សថ្នាក់បឋមសិក្សាកើនឡើង | អត្រាឡើងថ្នាក់នៅថ្នាក់បឋមសិក្សាកើនឡើងពី ៨២.៨% នៅឆ្នាំសិក្សា ២០០៨-២០០៩ ទៅ ៨៥% នៅឆ្នាំសិក្សា ២០១០-២០១១ | ១. ពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងស្តីពីការឡើងថ្នាក់នៅគ្រប់សាលាបឋមសិក្សាទាំងអស់<br>២. ពង្រាយគ្រូចេញថ្មីពីសាលាគរុកោសល្យ ៩៥% ទៅកាន់សាលារៀនដែលខ្វះគ្រូបង្រៀន និងសាលា រៀននៅតំបន់ដាច់ស្រយាល ។<br>៣. កាត់បន្ថយភាគរយនៃសាលារៀនមិនគ្រប់កំរិត ថ្នាក់ពី ១៨% ក្នុងឆ្នាំ សិក្សា ២០០៩-២០១០ ទៅ ១៥% ក្នុងឆ្នាំសិក្សា ២០១០-២០១១<br>៤. ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំដើម្បីធ្វើជាភស្តុតាងក្នុងការសម្រេចចិត្ត<br>ឧ. នៅក្នុងបរិបទដែលមានទិន្នន័យជំរឿនប្រជាជនថ្មី | ១. ការអនុវត្តការវិភាគរួមទៅលើការពិនិត្យមើលឡើងវិញតាមវិស័យប្រចាំ ឆ្នាំ និងបង្កើតផែនការប្រតិបត្តិប្រចាំឆ្នាំឱ្យទាន់ ពេលវេលាឱ្យបានទូលំ ទូលាយ និងត្រឹមត្រូវ<br>២. ការសម្របសម្រួលឱ្យមានការផ្តួចផ្តើមការអភិវឌ្ឍន៍សមត្ថភាព ។ |

## ៣. ការតាមដានវឌ្ឍនភាពនៃការអនុវត្តចំនុចដៅសកម្មភាព

### ៣.១ វឌ្ឍនភាពដែលសំរេចបាន

**សកម្មភាពទី១ :** នៅខែមិថុនា ឆ្នាំ២០១០ ក្រសួងអប់រំ យុវជន និងកីឡាបានចេញនូវសេចក្ដីណែនាំស្ដីពីការអនុវត្ត បទបញ្ជាផ្ទៃក្នុងសម្រាប់ការឡើងថ្នាក់នៅគ្រប់សាលាបឋមសិក្សាទាំងអស់ ។ សិស្សបឋមសិក្សាដែលធ្លាក់មធ្យមភាគមានឱកាសប្រឡងឡើងថ្នាក់ឡើងវិញនៅបំណាច់ឆ្នាំសិក្សា ហើយប្រសិនបើនៅតែប្រឡងមិនជាប់ពួកគេមានឱកាសប្រឡងម្ដងទៀតនៅដើមឆ្នាំសិក្សាបន្ទាប់។

**សកម្មភាពទី២ :** គ្រូចេញថ្មីចំនួន៩៥% ពីសាលាគរុកោសល្យត្រូវបានពង្រាយទៅកាន់សាលារៀនដែលខ្វះគ្រូបង្រៀន និងសាលារៀននៅតំបន់ដាច់ស្រយ៉ាល ។

**សកម្មភាពទី៣ :** សាលារៀនមិនគ្រប់កំរិតថ្នាក់ត្រូវបានកាត់បន្ថយមកត្រឹម ១៧.២% នៅខែធ្នូឆ្នាំ ២០១០ ។ សាលារៀន ២៦២ (ក្នុងចំណោម ៥៨២ បាន និងកំពុងត្រូវបានសាងសង់) ។

**សកម្មភាពទី៤ :** ដោយបានទទួលស្ថិតិប្រជាជនពី NIS/MoP ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ(EMIS)ប្រើស្ថិតិនេះ ដើម្បីបង្កើតសូចនាករអប់រំសំខាន់ៗមួយចំនួនសម្រាប់ការធ្វើចំណោលរយៈពេលពីរឆ្នាំ។

### ៣.២ ការមិនសម្រេចបានដោយភ្ជាប់ជាមួយភស្តុតាងច្បាស់លាស់

**សកម្មភាពទី១:** ការកែសម្រួលបទបញ្ជាផ្ទៃក្នុងស្ដីពីការឡើងថ្នាក់មានសារសំខាន់ក្នុងការកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា។ តាមរយៈវិធានការទាំងនេះ លទ្ធផលនៃអត្រាគង់វង្សនៅបឋមសិក្សាមានការកើនឡើងដល់ ៨៤.២% ក្នុងឆ្នាំសិក្សា ២០០៩-២០១០ បើប្រៀបធៀបជាមួយគោលដៅដែលកំណត់ ៨៥% ក្នុងឆ្នាំសិក្សា ២០១០-២០១១ (របាយការណ៍សន្និបាតអប់រំឆ្នាំ ២០១១) នៅពេលដែលតួលេខទាំងនេះពិតជាបានបង្ហាញការរីកចម្រើនមួយចំនួននោះ បែជាមានភាពខុសគ្នាយ៉ាងធំនៅតាមតំបន់។ <u>ឧទាហរណ៍</u> នៅក្នុងខេត្តរតនគីរីទិន្នន័យថ្មីបំផុតដែលទទួលបានពីសៀវភៅទិន្នន័យថ្នាក់ខេត្តបានបង្ហាញថា ផលធៀបរវាងគ្រូ និងសិស្ស គឺ សិស្សបឋមសិក្សា ៦៥នាក់មាន គ្រូម្នាក់ ហើយមានកុមារអាយុពី ៦ ដល់ ១១ឆ្នាំ ៤៤% មិនបានចូលសាលារៀន។ ខេត្តមានអត្រាអ្នកមិនចេះអក្សរ ៥១%។ នៅឆ្នាំ ២០០៩ មានគ្រួសារ ៤៥.៦% ត្រូវបានចាត់ថ្នាក់ថាជាគ្រួសារក្រីក្រ ។ លើសពីនេះទៅទៀត គុណភាពអប់រំនៅតែជាការព្រួយបារម្ភយ៉ាងធំធេង ជាពិសេសនៅថ្នាក់ទី១ ទី២ និងទី ៣។

ទិន្នន័យរបស់សិស្សសម្រាប់ប្រលងនៅបំណាច់ឆ្នាំសិក្សា និងនៅដើមឆ្នាំសិក្សាបន្ទាប់មិនអាចរកបានទេ ដូច្នេះវាមានការលំបាកសម្រាប់យើងធ្វើការសិក្សាអោយបានម៉ត់ចត់អំពីនិន្នាការគុណភាពអប់រំ ។

បទបញ្ហាផ្ទៃក្នុងស្ដីពីការឡើងថ្នាក់របស់សិស្សមិនទាន់ផ្សព្វផ្សាយបានទូលំទូលាយនៅឡើយ។ បទបញ្ហានេះមិនទាន់បានផ្សព្វផ្សាយជាទូទៅដល់អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ដែលធ្វើការងារដោយផ្ទាល់ជាមួយ សាលារៀន និងប្រជាជននៅឡើយ ។ ជាងនេះទៅទៀត មានខេត្តខ្លះមិនទាន់បានអនុវត្តបទបញ្ហាផ្ទៃក្នុងនេះនៅ ឡើយទេ ។

**សកម្មភាពទី២:** បញ្ហាខ្វះគ្រូបង្រៀននៅតែជាបញ្ហាធំសម្រាប់វិស័យអប់រំនៅកម្ពុជា ។ លទ្ធភាពរបស់គ្រូក្នុងការ ជ្រើសរើសកន្លែងបង្រៀនមិនបានឆ្លើយតបទៅនឹងតម្រូវការសាលារៀនតាមមូលដ្ឋានទេ ។ គ្រូនៅមិនទាន់មាន ចំនួនគ្រប់គ្រាន់ទេនៅតំបន់ដាច់ស្រយាល ចំណែកឯនៅតំបន់ទីក្រុងគ្រូបែរជាមានចំនួនលើសពីតម្រូវការទៅវិញ ។ ជាលទ្ធផល សាលារៀនមួយចំនួនមានគ្រូបង្រៀនតែម្នាក់គត់ដែលគាត់ដើរតួនាទីជានាយកផង គ្រូបង្រៀនផង និង បណ្ណារក្សផង[1] ។

លើសពីនេះទៅទៀត ការលើកទឹកចិត្ត និងគុណភាពគ្រូបង្រៀនគឺជាក្ដីព្រួយបារម្ភមួយទៀតសម្រាប់ការលើកកម្ពស់គុណភាពអប់រំ ។ ដោយសារតែប្រាក់បៀវត្សន៍ទាប គ្រូបង្រៀនភាគច្រើនស្វែងរកការងារផ្សេងទៀត ដើម្បីបានប្រាក់ចំណូល ។ ដោយផ្អែកលើការសិក្សាស្រាវជ្រាវមួយដែលបានធ្វើឡើងស្ដីពី “គុណតម្លៃគ្រូបង្រៀន” ដែលរៀបចំដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) និងអង្គការអ្នកស្ម័គ្រចិត្តបំរើការងារ នៅបរទេស (VSO) មានគ្រូបង្រៀន ៩៣% ដែលយើងធ្វើការសម្ភាសន៍ ឆ្លើយថាពួកគាត់មានមុខរបរទី២ ។ តិច ឬច្រើន វាបានប៉ះពាល់ដល់ពេលវេលារៀបចំមេរៀនបង្រៀន និងការធ្វើការស្រាវជ្រាវដើម្បីអភិវឌ្ឍខ្លួនគាត់ឱ្យទាន់ ពិភពលោកដែលមានការអភិវឌ្ឍឥតឈប់ឈរ ។ កត្តាមួយទៀតនោះគឺគ្រូបង្រៀនមិនមានជំនាញគ្រប់គ្រាន់ក្នុងការ ផ្ដល់ការបង្ហាត់បង្រៀនមានស្ដង់ដាខ្ពស់ ។ គេត្រូវការវគ្គបណ្ដុះបណ្ដាលស្ដីពីវិធីសាស្ត្របង្រៀនតាមបែបគោលសិស្ស មជ្ឈមណ្ឌល ដោយតម្រូវឱ្យមានការគាំទ្រជាប្រចាំក្នុងការជួយគ្រូសម្រេចបាននូវស្ដង់ដាបង្រៀន និងការគ្រប់គ្រង់ថ្នាក់រៀនដើម្បីធានាថាសិស្សសម្រេចបាននូវស្ដង់ដាកម្មវិធីសិក្សា ។

**សកម្មភាពទី៣:** ចំនួនសាលារៀនមិនគ្រប់កំរិតថ្នាក់នៅតែមានចំនួនច្រើន ពោលគឺ ១.១៥២ សាលានៅទូទាំង ប្រទេសដែលចាំបាច់ត្រូវមានការពិចារណាឡើងវិញ ។

លើសពីនេះទៅទៀត វាមានសារៈសំខាន់ណាស់ក្នុងការចងចាំថា ការសាងសង់សាលារៀនតែមួយមុខមិនមែនជាវិធានការដើម្បីទទួលភាពជោគជ័យទេ ពីព្រោះមិនមានសាលរៀនទាំងអស់បើកបង្រៀនពេញម៉ោង និងរៀងរាល់ថ្ងៃឡើយ ហើយការខ្វះគ្រូបង្រៀនដែលទទួលការបណ្ដុះបណ្ដាលនៅតែជាបញ្ហាធំនៅកម្ពុជា ។

**សកម្មភាពទី៤:** វាជាចំណាប់អារម្មណ៍ដ៏ធំក្នុងការចាប់ផ្ដើមប្រើជនជាតិភាគតិចជាសូចនាករមួយនៅក្នុងស្ថិតិដើម្បីតាមដានមើលពីភាពជោគជ័យរបស់ក្រុមដែលជួបការលំបាកនេះ ។

---

[1] របាយការណ៍សន្និបាតអប់រំឆ្នាំ ២០០៨-២០០៩ ផ្នែកបឋមសិក្សា

## ៤. ទិសដៅនៅពេលអនាគតសម្រាប់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

➢ ការផ្សព្វផ្សាយពីបទបញ្ជាផ្ទៃក្នុងផ្សេងៗ :

ដើម្បីធានាបាននូវការចូលរួមពេញលេញ និងមានប្រសិទ្ធិភាពពីគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ ការយល់ដឹងដែលកាន់តែទូលំទូលាយមួយពីគោលនយោបាយនានា ដូចជាបទបញ្ជាផ្ទៃក្នុង និងគោលការណ៍ណែនាំស្តីពីការឡើងថ្នាក់ចាំបាច់ត្រូវតែផ្សព្វផ្សាយ ដោយមិនគ្រាន់តែសម្រាប់សាលារៀនប៉ុណ្ណោះទេ តែថែមទាំងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ផងដែរ ។ ក្រសួងអប់រំ យុវជន និងកីឡា អាចធ្វើការឱ្យបានជិតស្និតថែមទៀតជាមួយ អង្គការមិនមែនរដ្ឋាភិបាលដើម្បីលើកកំពស់ការយល់ដឹងពីគោលនយោបាយនេះ ។

ទិន្នន័យរបស់សិស្សដែលប្រឡងឡើងថ្នាក់នៅបំណាច់ឆ្នាំសិក្សា និងដើមឆ្នាំសិក្សាបន្ទាប់ចាំចាច់ត្រូវតែមាន ដើម្បីឱ្យគេអាចសិក្សាបានពីនិន្នាការនៃគុណភាពអប់រំ ។

➢ ការពង្រាយគ្រូបង្រៀន :

ទាក់ទងនឹងការជ្រាយគ្រូចេញថ្មី យើងខ្ញុំសូមផ្តល់អនុសាសន៍ថា គោលនយោបាយស្តីពីការជ្រើសរើសគ្រូតាមមូលដ្ឋានចាំបាច់ត្រូវតែពង្រឹង ។ ដោយមានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍត្រូវរៀបចំយុទ្ធសាស្ត្រច្បាស់លាស់មួយដើម្បីប្រើប្រាស់អស់លទ្ធភាពនូវធនធាន មនុស្សតាមមូលដ្ឋាន ។ ក្រសួងអប់រំ យុវជន និងកីឡាចាំបាច់ត្រូវចាត់វិធានការផងដែរក្នុងការពង្រឹងការពង្រាយ គ្រូបង្រៀន ដើម្បីធានាកុំឱ្យមានសាលារៀនដែលមានគ្រូបង្រៀនលើស និង / ឬខ្វះគ្រូបង្រៀន ដោយសារការណ៍ នេះនឹងជួយកាត់បន្ថយការចំណាយថវិកាដែលមិនចាំបាច់ ។

នៅតំបន់ជនជាតិដើមភាគតិច ចាំបាច់ត្រូវពង្រាយគ្រូបង្រៀនដែលមកពីសហគមន៍ជនជាតិដើមភាគតិច និងបណ្តុះ-បណ្តាលយុវជនជនជាតិដើមភាគតិចឱ្យក្លាយទៅជាគ្រូបង្រៀនប្រកបដោយគុណភាពពេញលេញឱ្យបាន ច្រើនថែមទៀត ។ ត្រូវមានការបញ្ជាក់ឱ្យបានច្បាស់ពីលក្ខខណ្ឌ និងសម្របសម្រួលចំពោះការដាក់បញ្ចូលគ្រូកិច្ចសន្យាទៅជាគ្រូបង្រៀនដែលមានវិញ្ញាបនប័ត្របន្ទាប់ពីបំរើការទទួលការបណ្តុះបណ្តាល និងការវាយតម្លៃក្នុង ចំនួនឆ្នាំជាក់លាក់មួយ។ គ្រូបង្រៀនដែលជាជនជាតិខ្មែរដែលទើបទទួលការបណ្តុះបណ្តាលនៅតាមតំបន់ជន ជាតិដើមភាគតិចដែលដាច់ស្រយ៉ាលត្រូវការជំនួយច្រើន : ណែនាំពួកគេឱ្យយល់ពីវប្បធម៌ និងការប្រតិបត្តិរបស់ជនជាតិដើមភាគតិចសហគមន៍ឱ្យពួកគេខ្ចីដី និងត្រូវសាងសង់ផ្ទះមួយឱ្យពួកគេរស់នៅ ។

ដូចដែលគ្រូបង្រៀនជាច្រើននៅក្នុងប្រទេសកម្ពុជាបានបញ្ជាក់ឱ្យដឹងពីបំណងប្រាថ្នារបស់ខ្លួន ពួកគាត់ត្រូវការឱ្យមានវេទិការមួយដើម្បីសម្តែងពីទស្សនៈ និងការព្រួយបារម្ភរបស់ខ្លួន ក៏ដូចជាយន្តការមួយដើម្បីពាំនាំនូវទស្សនៈ ទាំងនោះឱ្យរដ្ឋាភិបាលបានដឹង ។ យើងសូមផ្តល់អនុសាសន៍ថា ការផ្តល់ឱ្យគ្រូបង្រៀននូវកាលនុវត្តភាពនានា និង យន្តការសម្រាប់សម្តែងនូវទស្សនៈរបស់ខ្លួននឹងជួយដោះស្រាយនូវការព្រួយបារម្ភរបស់គ្រូបង្រៀន ហើយវានឹងដើរតួនាទីយ៉ាងធំមួយសម្រាប់សមាជសាធារណៈ ។

ក្រសួងអប់រំ យុវជន និងកីឡាធ្វើវិភាជន៍មូលនិធិបុគ្គលិកអប់រំដើម្បីធ្វើឱ្យគ្រូបង្រៀនមានប្រាក់ខែសមរម្យ/អាចរស់នៅបាន ក្នុងគោលបំណងកាត់បន្ថយការបង់ថ្លៃសេវាក្រៅផ្លូវការ ព្រមទាំងលើកទឹកចិត្តពួកគាត់ឱ្យយកចិត្តទុកដាក់ថែមទៀតលើការងាររបស់ខ្លួន និងបន្តស្នាក់នៅកន្លែងដែលគេបញ្ជូនពួកគាត់ទៅ ។ ដោយសារការបង់ថ្លៃសេវាក្រៅផ្លូវការគឺជាឧបសគ្គដ៏ធំចំពោះសិទ្ធិទទួលបានការអប់រំ ការធានាបាននូវគុណភាពអប់រំសម្រាប់សិស្សការយកចិត្តទុកដាក់ជាពិសេសត្រូវធ្វើឡើងសម្រាប់បញ្ហានេះ ជាពិសេសការពង្រឹងការអនុវត្តន៍សេចក្តីប្រកាស ស្តីពីការទប់ស្កាត់ការយកសេវាក្រៅផ្លូវការ ។

- ការកសាងហេដ្ឋារចនាសម្ព័ន្ធសាលារៀន :

  ជាមួយនឹងចំនួនសាលារៀនដែលក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍគ្រោងសាងសង់ កម្ពុជាត្រូវការរយៈពេលជាច្រើនឆ្នាំទៀតដើម្បីដោះស្រាយបញ្ហានៃសាលារៀនមិនគ្រប់កំរិតថ្នាក់ ។ ការណ៍នេះទោះតិចក្តី ច្រើនក្តីនឹងប៉ះពាល់ទៅលើការសម្រេចបានគោលដៅសម្រាប់ការអប់រំទាំងអស់គ្នាត្រឹមឆ្នាំ២០១៥ ។ ហេតុដូច្នេះ ហើយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍត្រូវពន្លឿនដំណើរការនៃការសាងសង់សាលារៀនដើម្បីធានាបានថាសាលាបឋមសិក្សាទាំងអស់នឹងក្លាយជាសាលាគ្រប់កំរិតថ្នាក់នៅក្នុងរយៈពេលដ៏ខ្លីខាងមុខ ។

- ការពង្រឹង EMIS

  ការពង្រឹង EMIS សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តដោយមានភស្តុតាងច្បាស់លាស់គឺមានសារៈសំខាន់ណាស់ក្នុងការធានាពីគុណភាព និងសិទ្ធិទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ។ ទោះជាយ៉ាងនេះក្តី ការនេះមិនអាចធ្វើទៅបានប្រកបដោយជោគជ័យបានទេ ប្រសិនបើពុំមានឆន្ទៈនយោបាយដ៏រឹងមាំមួយទេនោះ ។ ហេតុដូចនេះហើយ យើងខ្ញុំសូមសម្តែងការគាំទ្រចំពោះចំនុចនេះ ហើយយើងសូមផ្តល់អនុសាសន៍ថា ក្រសួងអប់រំ យុវជន និង កីឡា និងដៃគូអភិវឌ្ឍត្រូវមានឆន្ទៈនយោបាយដែលរឹងមាំជាងនេះដើម្បីសម្រេចបាននូវគោលនយោបាយនេះ ។

បញ្ហាផ្សេងៗទៀតក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍត្រូវគិតគូពិចារណាឡើងវិញក្នុងគោលបំណងសិទ្ធិទទួលបានការអប់រំ និងគុណភាពអប់រំសម្រាប់សិស្សរួមមាន :

- កសាងសមត្ថភាពនាយកសាលាដើម្បីលើកកំពស់ការងារគ្រប់គ្រងសាលា ដោយសារវានឹងជួយលើកទឹកចិត្តគ្រូបង្រៀន និងការចូលរួមរបស់សហគមន៍ ។ ជាងនេះទៅទៀត ការកសាងវិជ្ជាជីវៈគ្រូបង្រៀនសម្រាប់គ្រូបង្រៀន តាមរយៈ ការបណ្តុះបណ្តាលក្នុងសេវាកម្មឱ្យបានញឹកញាប់ក៏គួត្រូវបានគេពិចារណាផងដែរ។ ឧបករណ៍ត្រួតពិនិត្យ និងតាមដានដ៏ច្បាស់លាស់ចាំបាច់ត្រូវតែបង្កើតឡើង និងអនុវត្តតាម ។
- កែលម្អការប្រលងជាលក្ខណៈស្តង់ដាដើម្បីវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្សយ៉ាងហោចណាស់ក៏សម្រាប់សិស្សថ្នាក់ទី ៣ ៦ ៩ និង១២ ដែរ ។
- ការផលិតសៀវភៅសិក្សាត្រូវតែមានគុណភាពខ្ពស់ និងបែងចែកឱ្យទាន់ពេលវេលាដល់សិស្ស និងគ្រូ ។ ជាងនេះទៅទៀត ក្រសួងអប់រំ យុវជន និងកីឡាធ្វើវិភាជន៍ថវិកាដើម្បីដោះស្រាយនូវការខ្វះខាតដ៏ធ្ងន់ធ្ងរចំពោះសម្ភារៈសម្រាប់អានបន្ថែមទៀតសម្រាប់សិស្សនៅតាមតំបន់ជនបទដាច់ស្រយ៉ាល ។

- បង្កើនថវិកាអាហារូបករណ៍សម្រាប់សិស្សក្រីក្រ និងអ្នកដែលរស់នៅតំបន់ជនបទ និងដាច់ស្រយ៉ាល : សាងសង់អន្តេវាសិកដ្ឋានដែលកាន់តែមានសុវត្ថិភាព និងមានការគ្រប់គ្រងកាន់តែល្អ ជាពិសេសសម្រាប់សិស្សស្រីឱ្យបានទូលំទូលាយនៅទូទាំងប្រទេស និងជាពិសេសសម្រាប់កុមារក្រីក្រ និងដែលបាត់បង់ឱកាស ។
- ក្រសួងអប់រំ យុវជន និងកីឡាត្រូវកែលម្អការទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីធានាថា ការបើកថវិកាតាមកម្មវិធីឱ្យដល់សាលារៀនមានលក្ខណៈទៀងទាត់ ។ សាលារៀនមួយចំនួនបានត្អូញត្អែថា ការបើកប្រាក់តាមកម្មវិធីយឺតបានបណ្តាលឱ្យមានការខ្វះខាតថវិកាប្រតិបត្តិសម្រាប់គាំទ្រសកម្មភាពសំខាន់ៗនៅក្នុងសាលារៀនរបស់ខ្លួន ។
- ការផ្តល់សិទ្ធិដល់សាលារៀនក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅពុំទាន់មានភាពច្បាស់លាស់នៅឡើយ ។ រដ្ឋបាលរបស់សាលារៀនពុំទាន់មានការជឿជាក់នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅតាមទិសដៅនៅឡើយ ដែលការណ៍នេះធ្វើឱ្យប៉ះពាល់ដល់ការសម្រេចបានការសិក្សារបស់សិស្ស ដោយសារតែខ្វះរចនាសម្ព័ន្ធច្បាស់លាស់ ជាពិសេស ចំពោះតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ។

**ព័ត៌មានសម្រាប់ទំនាក់ទំនង:**

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទំនាក់ទំនង:

**ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)**

លោក អិន សិរិទ្ធី

នាយកប្រតិបត្តិ

ទូរស័ព្ទលេខ: (៨៩៥-២៣) ២២៤ ៧៧៤ / ០១២ ៨២៨ ១៣៥

អ៊ីម៉ែល: info@nepcambodia.org or dir@nepcambodia.org

គេហទំព័រ: www.nepcambodia.org

# វិស័យកំណែទម្រង់ដីធ្លី

## ១. សូចនាករតាមដានរួម

| ស្ថាប័នសម្របសម្រួល: GS-SLC, **ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់**, GDCC<br><br>ស្ថាប័នអ្នកអនុវត្ត: GS-SLC, **ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់**/SNCDD, **ក្រសួងមហាផ្ទៃ, ក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់ការធ្វើអត្តសញ្ញាណកម្ម ចំណាត់ថ្នាក់ និងគូសផែនទីសម្រាប់សម្បទានដីសង្គមកិច្ច** | | | | |
|---|---|---|---|---|
| លទ្ធផលរយៈពេលមធ្យម | ធាតុចូល | សូចនាករធាតុចេញ | សកម្មភាពៈចំនុចដៅសកម្មភាព | សកម្មភាពដើម្បីបង្កើនប្រសិទ្ធិភាពហិរញ្ញប្បទានសហប្រតិបត្តិការ |
| ១-លើកស្ទួយវិស័យរដ្ឋបាលដីធ្លី និងសុវត្ថិភាពក្នុងការកាន់កាប់ដី | ១- គោលនយោបាយរដ្ឋបាលដីធ្លី ការបែង ចែកដី និងការគ្រប់គ្រងដីធ្លីត្រូវបានពង្រឹង<br><br>២- ការចុះបញ្ជីដី ធ្លីត្រូវបានពង្រឹង ដោយផ្តោតលើគ្រួសារក្រីក្រ និងជនងាយរងគ្រោះ | ១- សេចក្តីព្រាង គោលនយោបាយវាយតម្លៃដីធ្លី<br>២- សេចក្តីព្រាង គោលនយោបាយលំនៅដ្ឋាន<br>៣- កម្មវិធីអនុវិស័យ គ្រប់គ្រងដីធ្លី ត្រូវបានឯកភាព<br>៤- ប័ណ្ណចុះបញ្ជីដី មានលក្ខណៈជា ប្រព័ន្ធចំនួន ១.៧ លានប័ណ្ណ ត្រូវបាន ចែកជូនប្រជាពលរដ្ឋ<br>៥-（ទិន្នន័យមូលដ្ឋាន: ១.២ លាន ប័ណ្ណត្រូវបានចែកជូន ប្រជាពលរដ្ឋ）<br>៦- ភាគរយនៃស្ត្រី ដែលមានប័ណ្ណកម្ម សិទ្ធិដីធ្លី លើសបុរស ដែលមានប័ណ្ណកម្ម សិទ្ធិដីធ្លី<br>៧-（ទិន្នន័យមូល ដ្ឋាន : Cadastral Database）<br>៨- សហគមន៍ជនជាតិដើមភាគតិចចំនួន ៣ត្រូវបានចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិ | ១- ពិភាក្សាផ្ទៃក្នុង<br>២- ពិភាក្សាផ្តល់យោបល់ជាមួយដៃគូ<br>៣- កែតម្រូវសេចក្តីព្រាង<br>៤- ដាក់បញ្ជូនទៅក្រុមប្រឹក្សាគោលនយោបាយដីធ្លី<br>៥- បង្កើតកម្មវិធីអនុវិស័យគ្រប់គ្រងដីធ្លី<br>៦- អនុវត្តកម្មវិធីចេញប័ណ្ណកម្មសិទ្ធិដីធ្លីរបស់គម្រោងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី（LASSP）នៅខេត្តទាំង ១៥ | ១- ពង្រឹងយន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃ（សម្រាប់វិស័យដីធ្លី） |
| ២- បង្កើនសមភាពក្នុងការបែងចែកដី | ៣- ការអនុវត្តយន្តការសម្បទានដីសង្គមកិច្ច | ៩- ចាប់ពីខែ មករា ឆ្នាំ ២០១០ ដល់ខែ ធ្នូ ឆ្នាំ ២០១១ ចំនួនឃុំ ដែលបានស្នើផែនការប្រើប្រាស់ដីដែលបានឯកភាពកើនដល់២០ ឃុំ（ទិន្នន័យមូលដ្ឋាន: ១០ឃុំ）<br>១០- កម្មវិធីអនុ វិស័យបែងចែកដីធ្លីត្រូវបានឯកភាព<br>១១- លទ្ធភាពស្វែងរកដីដែលសមស្របនៅទូទាំងប្រទេសសម្រាប់សម្បទានដីសង្គមកិច្ច | ៧- អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច<br>៨- បង្កើតកម្មវិធីអនុវិស័យបែងចែកដីធ្លី<br>៩- រៀបចំផែនទីចំពោះផ្ទៃដីដែលសមស្របសម្រាប់សម្បទានដីសង្គមកិច្ច | ២- ដូចខាងលើ<br>៣- រៀបចំយន្តការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់កម្មវិធីអនុវិស័យបែងចែកដីធ្លី |

## ២. ការតាមដានពីវឌ្ឍនភាពលើចំណុចដៅសកម្មភាព

១. ធាតុចេញទី១

### ១.១ សេចក្តីព្រាងគោលនយោបាយវាយតម្លៃដីធ្លី

សេចក្តីព្រាងគោលនយោបាយ វាយតម្លៃដីធ្លីត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅចុងខែមិនា តាមរយៈ សិក្ខាសាលាពិគ្រោះយោបល់មួយជាមួយអ្នកពាក់ព័ន្ធនានា រួមមានតំណាងមកពីក្រសួង ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋាភិបាលសូមធ្វើការស្វាគមន៍ចំពោះកិច្ចប្រឹងប្រែងរបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដែលបានរៀបចំអោយមានការពិគ្រោះយោបល់នេះឡើង និងការតាំងចិត្តទទួលយកនូវមតិយោបល់របស់អ្នកចូលរួមសំរាប់ធ្វើការពិចារណាដើម្បីកែលំអបន្ថែមទៀតទៅលើសេចក្តីព្រាង ដោយសារតែយោបល់ទាំងនោះត្រូវបានទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់នៅក្នុងអំឡុងពេលពិគ្រោះយោបល់។

អង្គការមិនមែនរដ្ឋាភិបាលចាត់ទុកថាសេចក្តីព្រាងនេះ គឺជាជំហានមួយទៀតដើម្បីពង្រឹងក្របខ័ណ្ឌគោលនយោបាយដីធ្លី។ អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍នូវកិច្ចប្រឹងប្រែងក្នុងការបង្កើតវេទិកាអន្តរស្ថាប័នមួយ ដើម្បីអនុវត្តនូវយន្តការវាយតម្លៃនេះ ដើម្បីធានាអោយបាននូវកិច្ចដំណើរការមួយដែលមានលក្ខណៈចូលរួម និងប្រកបដោយតម្លាភាព។ អង្គការមិនមែនរដ្ឋាភិបាលសង្ឃឹមថានឹងមានការពិគ្រោះយោបល់ក្នុងលក្ខណៈស្ថាបនា បន្ថែមទៀតលើសេចក្តីព្រាងនេះ ដូចដែលត្រូវបានប្រកាសដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

ទោះបីជាយ៉ាងណាក៏ដោយ មុនពេលមានការវាយតម្លៃដីធ្លីដ៏ត្រឹមត្រូវ ឯកសារចំណាត់ថ្នាក់ដី និងការធ្វើផែនការប្រើប្រាស់ដីគឺមានសារៈសំខាន់បំផុត។ យើងខ្ញុំសូមអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធអោយអនុវត្តកិច្ចការនេះក្នុងទូទាំងប្រទេសសិន មុននឹងធ្វើការវាយតម្លៃដីធ្លី។ ដើម្បីពង្រឹងនូវតម្លាភាពនៃការវាយតម្លៃដីធ្លី យើងខ្ញុំសូមស្នើអោយមានការអនុញ្ញាតអង្គការមិនមែនរដ្ឋាភិបាលណាដែលមានសមត្ថភាពទៅលើបញ្ហានេះ ដើម្បីធ្វើការឃ្លាំមើល និងតាមដាននូវការអនុវត្តការវាយតម្លៃនេះ។

សេចក្តីព្រាងគោលនយោបាយនេះ ត្រូវបានផ្តល់ជូនអង្គការមិនមែនរដ្ឋាភិបាលរយៈពេលតែ៣ថ្ងៃប៉ុណ្ណោះ មុនពេលពិគ្រោះយោបល់ ដែលជាហេតុធ្វើអោយមានពេលវេលាមិនគ្រប់គ្រាន់ ដើម្បីពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទូលាយលើសេចក្តីព្រាងគោលនយោបាយនេះ ការសិក្សាស៊ីជម្រៅ និងការផ្តល់យោបល់ដោយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធទាំងអស់។

### ១.២ សេចក្តីព្រាងគោលនយោបាយលំនៅឋានជាតិ

គោលនយោបាយលំនៅឋានជាតិនៅមិនទាន់ត្រូវបានអនុម័តនៅឡើយ។ កន្លងមកយើងខ្ញុំបានទទួលព័តិមានពីក្រសួងថាសេចក្តីព្រាងនេះនឹងត្រូវធ្វើជូនគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តនៅក្រោយពេលដែលសេចក្តីព្រាងនេះជួបប្រទះនូវការយឺតយ៉ាវដោយសារតែខ្វះកូរ៉ុម (quorum) នៅក្នុងចំណោមនៃសមាជិករបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លីដែលព្រមព្រៀងទៅលើសេចក្តីព្រាងនេះ មុននឹងដាក់ជូនទៅគណៈរដ្ឋមន្ត្រី។ សេចក្តីព្រាងគោលនយោបាយនេះនឹងត្រូវធ្វើជូនទៅទីស្តីការគណៈមន្ត្រីនៅក្រោយពេលកែទម្រង់ឡើងវិញស្របទៅតាមទម្រង់ថ្មីតំរូវដោយទីស្តីការគណៈរដ្ឋមន្ត្រី។

មកដល់ពេលនេះ អង្គការមិនមែនរដ្ឋាភិបាលមិនបានទទួលសេចក្តីព្រាងចុងក្រោយដែលក្រសួងបានសន្យាផ្តល់អោយមុនពេលបញ្ជូលទៅទីស្តីការគណៈរដ្ឋមន្ត្រីនោះឡើយ។ ដូច្នេះហើយ យើងនៅតែមានការបារម្ភថា តើសេចក្តីព្រាងចុងក្រោយនោះបានដាក់បញ្ចូលមតិយោបល់របស់អង្គការមិនមែនរដ្ឋាភិបាលឬទេ។

ក្នុងដំណាក់កាលនេះ ដោយយោងទៅលើសំណើរបស់អង្គការមិនមែនរដ្ឋាភិបាលដែលបានដាក់ជូនកន្លង មកនៅក្នុងកិច្ចប្រជុំ GDCC លើកទី១៧[២]។ សំណើរទាំងនោះរួមមានការប្រកាន់ខ្ជាប់នូវគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ក៏ដូចជាការសិក្សាអំពីទម្លាប់នានាក្នុងការរស់នៅរបស់គ្រួសារក្រីក្រ និងគ្រួសារដែលមានប្រាក់ចំណូលមធ្យម ដើម្បីអភិវឌ្ឍយន្តការ និងស្ថាប័នប្រកប ដោយលក្ខណៈប្រាកដប្រជា និងមានប្រសិទ្ធិភាពសម្រាប់ទទួលលទ្ធផលរំពឹងនៃផែនការលំនៅឋានជាតិ។

២. ធាតុចេញទី២

២.៤ ប័ណ្ណចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធចំនួន១,៧លានប័ណ្ណ ត្រូវបានចែកជូនប្រជាពលរដ្ឋ

២.៦ ភាគរយនៃស្ត្រីដែលមានប័ណ្ណកម្មសិទ្ធដីធ្លី លើសបុរសដែលមានប័ណ្ណកម្មសិទ្ធិដីធ្លី

ក្រសួងបានរាយការណ៍ថាពីខែកញ្ញា ឆ្នាំ២០១០ រហូតដល់ខែមករា ឆ្នាំ២០១១ LASSP បានដាក់ទិន្នន័យចូលក្នុងកំព្យូទ័របានក្បាលដីចំនួន១៦១.៤៩២ ហើយបានដាក់បង្ហាញជាសាធារណៈចំនួន១៧៩.៦២១ ក្បាលដី ដោយបានចុះហត្ថលេខាប័ណ្ណកម្មសិទ្ធិដីចំនួន ១៥២.២៩០ និងបានចែកចាយប័ណ្ណកម្មសិទ្ធិដីចំនួន១.៥១៨.៩៦៤ ក្នុងចំណោមប័ណ្ណកម្មសិទ្ធិដីចំនួន១,៧លាន សម្រាប់ដំណាច់ឆ្នាំ២០១១។ ចំនួនភាគរយនៃអចលនទ្រព្យរបស់នារីគឺ ២៣,១២ភាគរយ ហើយចំនួនភាគរយនៃអចលនទ្រព្យរបស់បុរសគឺ ១០,១៥ ភាគរយ។ ចំនួនភាគរយនៃអចលនទ្រព្យរួមរបស់ស្វាមី និងភរិយាគឺ ៦២,៣៤ភាគរយ។

អង្គការមិនមែនរដ្ឋាភិបាល សូមធ្វើការវាយតម្លៃខ្ពស់ចំពោះការខិតខំ និងវឌ្ឍនភាពដែលសម្រេចបាន ដោយក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ដែលដឹកនាំដល់កំណើនដ៏ធំមួយនៅក្នុងការបញ្ចូលទិន្នន័យ និងការចុះហត្ថលេខា និងកំណើនបង្គួរនៅក្នុងការចែកចាយប័ណ្ណកម្មសិទ្ធិ។ អង្គការមិនមែនរដ្ឋាភិបាលសូមគាំទ្រ ចំពោះក្រសួងនៅក្នុងផែនការរបស់ខ្លួនក្នុងការដាក់បង្ហាញជាសាធារណៈបន្ថែមទៀតនូវទិន្នន័យស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។

ប៉ុន្តែផ្អែកទៅលើទិន្នន័យដែលមាន យើងមិនអាចមើលឃើញច្បាស់ឡើយនូវការផ្តោតលើការផ្តល់ប័ណ្ណកម្មសិទ្ធិជូនគ្រួសារក្រីក្រ និងងាយរងគ្រោះដែលរងការគម្រាមកំហែងពីអសុវត្ថិភាពនៃការកាន់កាប់ដី និងដែលងាយរងគ្រោះចំពោះការរើលំនៅឋានដោយមិនស្ម័គ្រចិត្ត។ ជាថ្មីម្តងទៀត ថ្វីបើសូចនាករតាមដានរួមអំពាវនាវ អោយមានការពង្រឹងការចុះបញ្ជីដី ដោយផ្តោតការយកចិត្តទុកដាក់លើគ្រួសារក្រីក្រ និងងាយរងគ្រោះក្តី ក៏សូចនាករទាំងបីនេះមិនហាក់បីដូចជាវាស់ចំណុចនេះឡើយ។ អង្គការមិនមែនរដ្ឋាភិបាលសូមធ្វើការអំពាវនាវ អោយមានអភិក្រមកាន់តែផ្តោតទៅលើប្រជាជនក្រីក្រ ថែមទៀតចំពោះការផ្តល់ប័ណ្ណកម្មសិទ្ធិ។

---

[២] សូមមើលសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងកិច្ចប្រជុំ អឌជជ លើកទី១៧ តាមរយៈគេហទំព័រ: http://www.ngoforum.org.kh/eng/dip/olddipdocs/DPP_NGOStatementto17thGDCCmeeting.pdf , ទំព័រទី១៥។

ដើម្បីកែលម្អសុវត្ថិភាពនៃការកាន់កាប់ដីរបស់គ្រួសារទាំងនោះ យើងខ្ញុំសូមស្នើឡើងនូវជម្រើសនានា ចំពោះការផ្តល់ប័ណ្ណកម្មសិទ្ធិដីជាប្រព័ន្ធ ដែលនាំអោយមានការពន្លឿនកិច្ចដំណើរការចុះបញ្ជី[៣] ។ ជម្រើសទាំងនេះ រួមមានការពង្រីកកិច្ចដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិ នៅក្នុងវិធីសាស្ត្របច្ចុប្បន្នពីលើចុះក្រោម ទៅដល់វិធីសាស្ត្រពីក្រោមឡើងទៅលើ និងការផ្តល់ប័ណ្ណកម្មសិទ្ធិខ្នាតតូចដោយជ្រើសរើសតំបន់នៅកម្រិតភូមិ ឬក៏សហគមន៍ជំនួសអោយសង្កាត់ទាំងមូល ។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលសូមស្នើអោយបន្ថែមពេលវេលាសម្រាប់ការចែកចាយប័ណ្ណកម្មសិទ្ធិ ។ កន្លងមកមានគ្រួសារខ្លះមិនអាចទៅយកប័ណ្ណកម្មសិទ្ធិរបស់ខ្លួនតាមកាលកំណត់ ។

២.៨ សហគមន៍ជនជាតិដើមភាគតិច៣ ត្រូវបានចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិ

មកដល់ពេលនេះ អង្គការមិនមែនរដ្ឋាភិបាលសូមស្វាគមន៍ការប្រកាសចេញរបស់ក្រសួងរៀបចំដែនដី ស្តីពីការរៀបចំចេញសរាចរអន្តរក្រសួងមួយរវាងក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីផ្អាករាល់ការជួញដូរដីទាំងអស់នៅក្នុងសហគមន៍ជនជាតិដើមភាគតិចដែលត្រូវបានទទួលស្គាល់ស្របច្បាប់ ។

ទោះជាយ៉ាងណាក្តី ការផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពដែលត្រូវបានរំពឹងថាត្រូវចេញមុនដំណាច់ឆ្នាំ២០១០ ត្រូវបានពន្យារពេល ដែលជាហេតុធ្វើអោយអង្គការមិនមែនរដ្ឋាភិបាលនានាមានកង្វល់កាន់តែច្រើនអំពីនីតិវិធីវែងអន្លាយនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ខណៈដែលមិនទាន់មានវិធានការការពារបណ្តោះអាសន្ននៅឡើយ ។[៤]

គម្រោងសាកល្បងទាំង ៣ នៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិចជាសមូហភាពត្រូវបានអនុវត្តតាំងពីឆ្នាំ២០០៨ មក ប៉ុន្តែមកដល់ពេលនេះ ភូមិទាំងនោះនៅតែមិនទាន់មានប័ណ្ណកម្មសិទ្ធិដី រីឯតំបន់សហគមន៍ជនជាតិដើមភាគតិចមួយចំនួននៅតែបន្តប្រឈមនឹងការបាត់បង់ដីធ្លី និងធនធានធម្មជាតិរបស់ខ្លួន ដោយរងផលប៉ះពាល់ជាពិសេសពីកំណើននៃសម្បទានដីសេដ្ឋកិច្ច និងសម្បទានរ៉ែនៅក្នុងតំបន់ដែលពួកគេរស់នៅ ។ អង្គការមិនមែនរដ្ឋាភិបាលសូមផ្តល់អនុសាសន៍អោយបង្កើនល្បឿនក្នុងការទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចអោយបានដល់យ៉ាងហោចណាស់ចំនួន ៣៥ សហគមន៍ក្នុងមួយឆ្នាំ ដោយសារការទទួលស្គាល់នេះអាចផ្តល់កិច្ចការពារស្របច្បាប់មុនពេលមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ពីគោលដៅសាកល្បងចំនួន ៣ អោយបានដល់សហគមន៍ជនជាតិដើមភាគតិចចំនួន១៥ ដែលត្រូវបានចុះបញ្ជីរួចហើយជានីតិបុគ្គលដោយក្រសួងមហាផ្ទៃ ។ ភាគីពាក់ព័ន្ធទាំងអស់ គប្បីបន្តអនុវត្តការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ និងការកែលម្អនៅក្នុងដំណោះស្រាយវិវាទតាមផ្លូវច្បាប់ ដើម្បីអនុវត្តមាត្រាទី២៣ ដល់មាត្រាទី២៨ និងមាត្រាទី៥៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១ និងមាត្រាទី ១១ មាត្រាទី១៥ និងមាត្រាទី៣៧ នៃច្បាប់ព្រៃឈើ ក៏ដូចជាអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ។

៣. ធាតុចេញទី៣

---

[៣] សំណើរមួយចំនួនត្រូវបានលើកឡើងរួចហើយនៅក្នុងសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលថ្លែងទៅកាន់កិច្ចប្រជុំ GDCC លើកទី១៧ ។ សើមមើលៈ http://www.ngoforum.org.kh/eng/dip/olddipdocs/DPP_NGOStatementto17thGDCCmeeting.pdf

[៤] សូមមើលយោបល់ និងសំណើរដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល ថ្លែងទៅកាន់កិច្ចប្រជុំ GDCC លើកទី១៧ នៅលើគេហទំព័រៈ http://www.ngoforum.org.kh/eng/dip/olddipdocs/DPP_NGOStatementto17thGDCCmeeting.pdf

៣.៩ ចំនួនឃុំដែលបានស្នើផែនការប្រើប្រាស់ដីដែលបានឯកភាពកើនដល់២០ឃុំ (ទិន្នន័យមូលដ្ឋានៈ ចំនួន១០ឃុំ)

៣.១០ កម្មវិធីអនុវិស័យបែងចែកដីធ្លីត្រូវបានឯកភាព

សេចក្តីព្រាងកម្មវិធីតាមវិស័យស្តីពីការបែងចែកដី ត្រូវបានដាក់ជូន អគ្គលេខាធិកាដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី GSCLP ដើម្បីអនុម័ត។

៣.១១ លទ្ធភាពស្វែងរកដីដែលសមស្របនៅទូទាំងប្រទេសសម្រាប់សម្បទានដីសង្គមកិច្ច (SLCs)

អង្គការមិនមែនរដ្ឋាភិបាល សូមស្វាគមន៍ចំពោះប្រការដែលចែងនៅក្នុងក្របខ័ណ្ឌនៃគម្រោងស្តីពីការបែងចែកដីសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម(LASED) និងដោយមានការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ឃុំចំនួន៦នៅក្នុងខេត្តចំនួនពីរ គឺស្ថិតនៅក្នុងកិច្ចដំណើរការនៃការចុះបញ្ជីដីរដ្ឋសម្រាប់សម្បទានដីសង្គមកិច្ច។ ការធ្វើផែនការប្រើប្រាស់ដី និងការបែងចែក និងនីតិវិធីស្តីពីការជ្រើសរើសអ្នកទទួលដីកំពុងដំណើរការ។

ចំនុចនេះក៏គួរអោយកោតសរសើរផងដែរនៅក្នុងបរិបទប្រទេសកម្ពុជា ដែលនៅក្នុងនោះគេនៅឃើញមានតម្រូវការច្រើនក្នុងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងយន្តការអនុវត្តសម្រាប់គំនិតផ្តួចផ្តើមបែបនេះក្នុងការបង្កើនការអនុវត្តសម្បទានដីសង្គមកិច្ចឃុំនៅក្នុងទូទាំងប្រទេស។ កម្មវិធីរងតាមវិស័យស្តីពីការបែងចែកដីត្រូវបានអនុម័ត ដោយរាជរដ្ឋាភិបាលរួចហើយ ដើម្បីជម្រុញការអនុវត្តកម្មវិធីនេះ។ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យន្តការសម្បទានដីសង្គមកិច្ចត្រូវបានបង្កើតឡើងដើម្បីកិច្ចដំណើរការអនុវត្ត។ ទាក់ទិននឹងកិច្ចដំណើរការចែកចាយដី ការជ្រើសរើសអ្នកទទួលបានដី គឺកំពុងដំណើរការ។ ដោយសារដំណាក់កាលនេះ គឺជាដំណាក់កាលសំខាន់ វាតម្រូវអោយមានការយកចិត្តទុកដាក់កាន់តែច្រើន ដើម្បីធានាអោយបានថាគ្រួសារក្រីក្រ និងគ្មានដីធ្លីពិតប្រាកដ គឺជាអ្នកទទួលផលប្រយោជន៍ពីគម្រោងសម្បទានដីសង្គមកិច្ច។ ហេតុដូច្នេះ យន្តការតាមដានបន្តមួយពីស្ថាប័នពាក់ព័ន្ធគឺសំខាន់។ ម្យ៉ាងទៀត យុទ្ធនាការអប់រំកាន់តែច្រើនអំពីច្បាប់ភូមិបាល និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀតគប្បីត្រូវអនុវត្ត ដើម្បីកាត់បន្ថយវិវាទដែលនឹងធ្វើអោយកិច្ចដំណើរការទាំងមូលដើរយឺត។ អង្គការមិនមែនរដ្ឋាភិបាលនៅតែមានកង្វល់ថា កិច្ចដំណើរការបង្កើតសម្បទានដីសង្គមកិច្ចឃុំត្រូវចំណាយពេលវែងពេករហូតដល់ពេលដែលដីអាចចែកចាយជូនដល់គ្រួសារគ្មានដី និងគ្រួសារក្រីក្រនៅក្នុងឃុំគោលដៅ។

## ៣. អនុសាសន៍សម្រាប់ទាំងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

ក្នុងផ្នែកនេះសូមដាក់បញ្ចូលអនុសាសន៍ទាំងជូនរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា។ បញ្ហាផ្សេងទៀត ដែលមិនស្ថិតនៅក្រោមសូចនាករតាមដានរួម ក៏អាចលើកឡើងផងដែរនៅក្នុងផ្នែកនេះ ហើយក៏ជាសំណើសុំការយកចិត្តទុកដាក់ និងអន្តរាគមន៍។

- យើងខ្ញុំសូមផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលកម្ពុជាអោយធ្វើការផ្សព្វផ្សាយនូវគោលនយោបាយ ឬច្បាប់ដែលពាក់ព័ន្ធនានាជូនដល់ភាគីពាក់ពន្ធ័ទាំងអស់ ជាមួយនឹងពេលវេលាសិក្សាគ្រប់គ្រាន់មុនពេលពិគ្រោះយោបល់ ដើម្បីអនុញ្ញាតិអោយមានការសិក្សាបានស៊ីជម្រៅដែលជាហេតុរួមចំណែកដល់ការពិគ្រោះយោបល់ និងធាតុចូលប្រកបដោយលក្ខណៈស្ថាបនា។ អង្គការ

មិនមែនរដ្ឋាភិបាលសង្ឃឹមថាបានចូលរួមក្នុងកិច្ចដំណើរការពិគ្រោះយោបល់បន្ថែមទៀតប្រកបដោយលក្ខណៈស្ថាបនា និងអត្ថន័យលើសេចក្តីព្រាងគោលនយោបាយវាយតម្លៃដីនេះ។

- អង្គការមិនមែនរដ្ឋាភិបាលសូមស្នើអោយក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវតួលេខ និងទីកន្លែងជាក់ស្តែង (ភូមិ ឃុំ) នៃតំបន់ដែលបានផ្តល់ប័ណ្ណកម្មសិទ្ធិ។ លើសពីនេះទៀត យើងខ្ញុំក៏សូមស្នើផងដែរអោយក្រសួងដាក់បង្ហាញនូវសមិទ្ធិផលទាំងអស់របស់ខ្លួននៅលើគេហទំព័រ និងផ្តល់ព័ត៌មានអំពីបច្ចុប្បន្នភាពជូនដល់អង្គការមិនមែនរដ្ឋាភិបាលនានា។

- អង្គការមិនមែនរដ្ឋាភិបាល សូមស្នើអោយមានការពិភាក្សាបន្ថែមទៀតលើសំណើនានាដែលបានលើកឡើង ដើម្បីលៃលម្អប្រសិទ្ធិភាពនៃការផ្តល់កម្មសិទ្ធិដីធ្លី។

- តួនាទីរបស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ គប្បីមានកម្រិតត្រឹមតែការជួយសម្របសម្រួលនៅថ្នាក់ជាតិសម្រាប់ការផ្ទេរដី និងការធ្វើចំណាត់ថ្នាក់ដីឡើងវិញ តាមសំណើពីថ្នាក់ក្រោមជាតិ (ពីថ្នាក់ខេត្តដល់សង្កាត់)។ ចំណុចនេះនឹងមានលក្ខណៈងាយស្រួលក្នុងការរៀបចំលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយថ្នាក់ក្រោមជាតិ សម្រាប់ជ្រើសរើសដីដែលមាន និងដែលសមស្របសម្រាប់សម្បទានដីសង្គមកិច្ចឃុំ។ ប៉ុន្តែ ការអនុវត្តតាំងពីការជ្រើសរើសទីកន្លែងដល់ការអនុវត្តគម្រោងរហូតដល់ការធ្វើសេចក្តីសម្រេចចិត្ត គប្បីត្រូវធ្វើនៅថ្នាក់ក្រោមជាតិ សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា។

**ព័ត៌មានសម្រាប់ទំនាក់ទំនង:**

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទំនាក់ទំនង:


**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia)**

លោក ប៉ែន រង្សី

ប្រធានកម្មវិធីដីធ្លី និងជីវភាព

ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ៤២៩

ទូរសារលេខ: (៨៥៥-២៣) ៩៩៤ ០៦៣

អ៊ីម៉េល: raingsey@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh

អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

# វិស័យព្រៃឈើ

## ១. សូចនាករតាមដានរួម

| ស្ថាប័នសម្របសម្រួលៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន<br>ស្ថាប័នអនុវត្តៈ រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន | | | | |
|---|---|---|---|---|
| **លទ្ធផលរយៈពេលមធ្យម** | **ធាតុចេញ** | **សូចនាករធាតុចេញ** | **សកម្មភាព** | **សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ** |
| ថែរក្សាគម្របព្រៃឈើ ដោយបង្កើនបរិមាណនិងគុណភាពព្រៃឈើដោយកែលំអការគ្រប់គ្រងធនធានព្រៃឈើ | ពង្រឹងការអនុវត្តន៍កម្មវិធីព្រៃឈើជាតិ ដោយកែលំអការរៀបចំផែនការ និងការគ្រប់គ្រងវិស័យព្រៃឈើ | ជំរុញការអនុវត្តកម្មវិធីព្រៃឈើជាតិទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយតម្រឹមធនធានសម្រាប់វិស័យព្រៃឈើទៅនឹងក្របខ័ណ្ឌកម្មវិធីព្រៃឈើជាតិឱ្យបានយ៉ាងតិច៧៥ភាគរយ | ១. ដាំព្រៃឡើងវិញលើដីរេចរិលឱ្យបាន ២៥ ០០០ ហ.ត។<br>២. បោះព្រំប្រទល់ព្រៃឈើឱ្យបាន ៧៥០ គ.ម និងកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបាន ៤តំបន់។<br>៣. អនុម័តសហគមន៍ព្រៃឈើឱ្យបាន ១០០ និងសហគមន៍តំបន់ការពារធម្មជាតិឱ្យបាន ៧ សហគមន៍។<br>៤. អនុម័ត និងអនុវត្តផែនទីចង្អុលផ្លូវផែនការស្តីពីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការអនុវត្តន៍យន្តការ REDD | ១. ពង្រឹងការរៀបចំផែនការប្រចាំឆ្នាំដើម្បីគាំទ្រដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។<br>២. អនុម័តផែនការរៀបចំតំបន់សហគមន៍ ព្រៃឈើចំនួន ២លាន ហ.ត នៅលើផែនទីដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។<br>៣. រៀបចំនីតិវិធី និងបទបញ្ញត្តិនានាសម្រាប់ REDD |

## ២. ការតាមដានវឌ្ឍនភាពរបស់ចំនុចដៅសកម្មភាព

### ២.១ ដាំព្រៃឡើងវិញលើដីរេចរិលឱ្យបាន ២៥ ០០០ ហ.ត

អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារលើវិស័យព្រៃឈើសូមអបអរសាទរចំពោះវឌ្ឍនភាពដែលសម្រេចបានដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចប្រឹងប្រែងដាំព្រៃឈើឡើងវិញ បានរហូតដល់ផ្ទៃដីទំហំ ២៦.៧៧៥ ហិកតា លើដីរេចរិលដែលលើសពីគោលដៅគ្រោងទុក ទំហំត្រឹមតែ ២៥០០០ ហិកតា ថ្វីបើផ្ទៃដីដាំព្រៃឈើដែលដាំឡើងវិញភាគច្រើនគឺជាចំការកៅស៊ូនៅក្នុងសម្បទានដីសេដ្ឋកិច្ច (ELCs) ក៏ដូចជាដើមអាកាស្យា (Acacia) និងដើមប្រេងខ្យល់ (Eucalyptus) ក៏ដោយ ។

អង្គការមិនមែនរដ្ឋាភិបាលសំនូមពរ រាជរដ្ឋាភិបាលកម្ពុជា/រដ្ឋបាលព្រៃឈើ ញែកអោយដាច់នូវទិន្នន័យនៃការដាំព្រៃឈើឡើងវិញ ដែលជាដើមកៅស៊ូ ចេញពីសកម្មភាពនៃការដាំព្រៃឈើឡើងវិញ។ ការដាំព្រៃឈើឡើងវិញដោយការដាំដើមកៅស៊ូ មិនអាចត្រូវបានចាត់ទុកថាជាសមិទ្ធិផលដោយរដ្ឋបាលព្រៃឈើទេ ដោយសារក្រុមហ៊ុនឯកជនទទួលខុសត្រូវលើការដាំដើមកៅស៊ូទាំងនេះ។

ជាថ្មីម្តងទៀត អង្គការមិនមែនរដ្ឋាភិបាល សំណូមពរឱ្យរាជរដ្ឋាភិបាលសូមពិចារណាលើការកំណត់និយមន័យព្រៃឈើ ដោយគិតតែលើព្រៃឈើធម្មជាតិ ដោយមិនរាប់បញ្ចូលចំការកៅស៊ូ ឬចំការឧស្សាហកម្ម និង/ឬកសិកម្មផ្សេងទៀត។ ដោយសារថាដើមឈើ

ឯកវប្បកម្ម ដូចជាកៅស៊ូគឺមិនមានលក្ខណៈគ្រប់គ្រាន់ទេក្នុងការជំនួសឱ្យព្រៃឈើធម្មជាតិដោយសារថា វាមិនមានជីវៈចំរុះ មិនអាចមានអនុផលដូចព្រៃឈើ និងជាពិសេសសត្វព្រៃមិនអាចរស់នៅបាន។

## ២.២ បោះព្រំប្រទល់ព្រៃឈើឱ្យបាន ៧៥០ គ.ម និងកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបាន៤តំបន់

យើងខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះសមិទ្ធិផលរបស់រាជរដ្ឋាភិបាលលើការកំណត់ព្រំប្រទល់ព្រៃឈើ ក៏ដូចជាតំបន់ការពារធម្មជាតិបានតាមសូចនាករកំនត់។ ប៉ុន្តែ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ មានការបារម្ភយ៉ាងខ្លាំងអំពីនិន្នាការបច្ចុប្បន្ននៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចទៅអោយក្រុមហ៊ុនដើម្បីអភិវឌ្ឍដំណាំកៅស៊ូ និងដំណាំនានានៅក្នុងតំបន់ការពារ។ តួយ៉ាង ដូចជាបូកគោ បុទុមសាគរ វីរៈជ័យ ឱរ៉ាល់ បឹងពែ លំផាត់ និងស្នួលជាដើម។

អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលមើលឃើញថា គំរោងសម្បទានដីសេដ្ឋកិច្ច ជាកត្តាមួយក្នុងចំណោមកត្តានានានៃការបំផ្លាញព្រៃឈើនៅកម្ពុជា។ ថ្មីៗនេះ នៅក្នុងព្រៃធម្មជាតិដ៏ធំចុងក្រោយនៅកម្ពុជាដែលប្រជាជនទូទៅហៅថា **ព្រៃឡង់** ដែលស្ថិតនៅក្នុងខេត្ត ៤ៈ ព្រះវិហារ កំពង់ធំ ក្រចេះ និងស្ទឹងត្រែង ដែលគ្របដណ្តប់លើផ្ទៃដីប្រមាណជា ២៥០.០០០ ហិកតា កំពុងរងការគំរាមកំហែងពីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន២ ដែលកំពុងកាប់ព្រៃគ្នារព្រៃជាង ២០.០០០ហិកតា។ សកម្មភាពនេះមិនមែនត្រឹមតែជាការកាប់បំផ្លាញព្រៃឈើតែប៉ុណ្ណោះទេ ប៉ុន្តែវាធ្វើអោយបាត់បង់ដល់ធនធានផ្សេងៗសំរាប់សហគមន៍ដែលជាប្រភពចំណូល ថ្នាំសង្កូវ ការប្រម៉ាញ់សត្វ និងអុសទៀតផង។

## ២.៣ អនុម័ត និងអនុវត្តផែនទីចង្អុលផ្លូវ ផែនការស្តីពីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការអនុវត្តន៍យន្តការ REDD[5]

អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលទទួលស្គាល់ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈរដ្ឋបាលព្រៃឈើក្នុងការបង្កើតឡើងនូវឯកសារផែនទីបង្ហាញផ្លូវសំរាប់កម្មវិធីស្តីពី ការកាត់បន្ថយការបំភាយឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងការរេចរឹលព្រៃឈើ (REDD) ដែលមានលក្ខណៈល្អប្រសើរបើធៀបនឹងការធ្វើគោលនយោបាយទាក់ទងនឹងវិស័យព្រៃឈើមុនៗ។ ការពិគ្រោះយោបល់ថ្នាក់ជាតិត្រូវបានធ្វើ ហើយជាពិសេសសិក្ខាសាលាពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងសហគមន៍ជនជាតិដើមភាគតិចបានបើកផ្លូវសំរាប់សហគមន៍ និងអង្គការសង្គមស៊ីវិល ដើម្បីផ្តល់យោបល់លើសំណើរឱ្យមានការត្រៀមលក្ខណៈជាស្រេច(R-PP) របស់កម្ពុជា។ ថ្វីបើមានការបើកទូលាយជាងមុនៗក្តី ប៉ុន្តែដំណើរការពិគ្រោះយោបល់នៅមានឧបសគ្គ ដោយសារពេលវេលាខ្លី និងការជជែកពិភាក្សាមិនគ្រប់គ្រាន់អំពីការព្រួយបារម្ភទាក់ទិននឹងអភិបាលកិច្ច និងគោលការណ៍នានាដែលគប្បីធ្វើជាមូលដ្ឋាននៃការត្រៀមទុកជាស្រេច និងការសាកល្បងកម្មវិធីរ៉េដ (REDD)។

អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលបានចេញសេចក្តីថ្លែងការណ៍រួមរបស់ខ្លួនស្តីពីការព្រួយបារម្ភអំពី R-PP របស់កម្ពុជា។ សូមមើលពិតមានលំអិតនៅក្នុងសេចក្តីថ្លែងការណ៍រួម នៅលើគេហទំព័រ http://www.ngoforum.org.kh ឬ http://www.forestcarbonpartnership.org/fcp/Node/166។

[5] ចំពោះព័តិមានលំអិតស្តីពី REDD សូមចូលគេហទំព័រៈ http://www.forestcarbonpartnership.org/fcp/node/30

## ៧. អនុសាសន៍សម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

- សម្បទានដីសេដ្ឋកិច្ចត្រូវបានគេទទួលស្គាល់ថាជាដើមចមសំខាន់នៃការបំផ្លាញព្រៃឈើនៅប្រទេសកម្ពុជា។ បញ្ហានេះគួរតែត្រូវបានគេដោះស្រាយជាមុនមុនពេលអនុវត្ត R-PP ។ យើងខ្ញុំសូមសំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជា សូមមេត្តាបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងលុបចោលនូវគំរោងដីសម្បទានសេដ្ឋកិច្ចទាំងឡាយណាដែលកំពុងប៉ះពាល់ដល់សហគមន៍ និងតំបន់ការពារ។ ការការពារព្រៃឈើធម្មជាតិ និងធនធានធម្មជាតិនៅកម្ពុជា គឺសំខាន់ក្រៃលែងចំពោះ REDD+ និងគឺជាមូលដ្ឋានគ្រឹះដើម្បីសម្រេចបាននូវនិរន្តរភាពបរិស្ថាន។
- យើងខ្ញុំសូមលើកទឹកចិត្តដល់រដ្ឋបាលព្រៃឈើអោយអនុវត្តតាមប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុនសែន ដើម្បីប្រយុទ្ធប្រកបដោយប្រសិទ្ធភាពទល់នឹងសកម្មភាពកាប់ឈើខុសច្បាប់នៅក្នុងតំបន់ព្រៃឈើទាំងនេះ។[៦]
- រាជរដ្ឋាភិបាលកម្ពុជា មិនគួររាប់បញ្ចូលការដាំដំណាំឯកវប្បកម្មថាជាសកម្មភាពដាំដើមឈើឡើងវិញទេដោយសារថាចំការឧស្សាហកម្មទាំងនេះជាដើមចមនៃការបំផ្លាញ និងឈូសឆាយព្រៃឈើធម្មជាតិមុនពេលដាំដំណាំឧស្សាហកម្មទាំងនោះ។

### ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទំនាក់ទំនង:

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា** (The NGO Forum on Cambodia)

លោក ប៉ែន រង្សី

ប្រធានកម្មវិធីដីធ្លី និងជីវភាព

ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ៤២៩

ទូរសារលេខ: (៨៥៥-២៣) ៩៩៤ ០៦៣

អ៊ីម៉ែល: raingsey@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh

អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

[៦] សូមមើលសុន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រីកាលពីថ្ងៃទី ៧មេសា ឆ្នាំ២០១១ នៅសកលវិទ្យាល័យភូមិន្ទកសិកម្ម http://www.postkhmer.com/index.php?option=com_content&view=article&id=55903:2011-04-07-09-51-29&catid=58:online-edition&Itemid=102

# កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ

## ១. សេចក្តីផ្តើម

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) គឺជាសម្ព័ន្ធភាពនៃសមាជិកអង្គការមិនមែនរដ្ឋាភិបាលចំនួន ២៣ ដែលធ្វើការដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋក្នុងប្រទេសកម្ពុជា។ CHRAC ធ្វើការតាមដានក្របខណ្ឌច្បាប់ និងតុលាការ ដែលកំពុងត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា។ បញ្ហាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ មានសារៈសំខាន់ក្រៃលែងក្នុងការធានាការអនុវត្តនីតិរដ្ឋត្រឹមត្រូវ និងការគោរពសិទ្ធមនុស្សក្នុងប្រទេសកម្ពុជា។ CHRAC ដោយសហការជាមួយអង្គការសមាជិករបស់ខ្លួនកំពុងធ្វើការតាមដានយ៉ាងជិតស្និទ្ធលើបញ្ហាទាំងនេះ តាមរយៈការតាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពចាំបាច់ដែលមាននៅក្នុងសូចនាករតាមដានរួម និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។

## ២. សូចនាករតាមដានរួមគ្នា

| ស្ថាប័នសម្របសម្រួល : ក្រុមការងារបច្ចេកទេស កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ<br>ស្ថាប័នអនុវត្ត : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធមិ | | | | |
|---|---|---|---|---|
| លទ្ធផលរយៈពេលមធ្យម | ធាតុចេញ | សូចនាករចេញ | សកម្មភាព: ចំណុចដៅសកម្មភាព | សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ |
| កែលម្អការប្រព្រឹត្តទៅរបស់ប្រព័ន្ធតុលាការ | ១. បញ្ចប់ការរៀបចំច្បាប់សំខាន់ៗដែលទាក់ទងនឹងតុលាការ<br>២. ការអនុវត្តទស្សនាទានតុលាការគំរូក្នុងតុលាការទាំង ៤ | ១. គណៈរដ្ឋមន្ត្រីអនុម័តច្បាប់សំខាន់ៗដែលពាក់ព័ន្ធទៅនឹងតុលាការមានដូចជា:<br>ក. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ<br>ខ. ច្បាប់ស្តីពីលក្ខនិកៈចៅក្រម និងព្រះរាជអាជ្ញា<br>គ. ច្បាប់ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម<br>២.ការអនុវត្តសកម្មភាពអាទិភាពសម្រាប់ឆ្នាំ២០១១ រួមទាំងដំណើរការនៃការចុះបញ្ជីសំណុំរឿងនៅតុលាការគំរូទាំង ៤ | ១. ពិនិត្យឡើងវិញនូវលំដាប់អាទិភាពនៃការត្រួតពិនិត្យផ្នែកបច្ចេកទេសសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ទាំងបី<br>២. ក្រុមការងារពិសេសដឹកនាំដោយក្រុមប្រឹក្សាអ្នកច្បាប់ពិនិត្យសេចក្តីព្រាងច្បាប់ទាំងនេះ<br>៣...., ៤,... ៥.......<br>៥. បញ្ចប់ផែនការសកម្មភាពរបស់តុលាការគំរូទាំង ៤<br>៦. ក្រសួងយុត្តិធមិ និងតុលាការគំរូទាំង ៤ ឯកភាពលើសកម្មភាពអាទិភាពសម្រាប់ឆ្នាំ២០១១-២០១២<br>៧. ស្នើសំណើថវិកាសម្រាប់គាំទ្រផែនការឆ្នាំ២០១១-២០១២ តាមទម្រង់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣. ការគាំទ្រខាងផ្នែកថវិការបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រូវតម្រឹមជាមួយនឹងផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពរបស់តុលាការ |

## ៣. ការតាមដានវឌ្ឍនភាពនៃចំណុចគោលសកម្មភាព

**សូចនាករ ១៦.១.** បញ្ចប់ការរៀបចំច្បាប់សំខាន់ៗដែលទាក់ទងនឹងតុលាការ

១៦.១.១. ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការត្រូវបានក្រសួងយុត្តិធម៌ព្រាងឡើងរួចហើយ។ សេចក្តីព្រាងច្បាប់នេះបានត្រូវបញ្ចប់ការត្រួតពិនិត្យ និងផ្តល់យោបល់ដោយអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ហើយបានដាក់ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី។ ថ្មីៗនេះ សេចក្តីព្រាងច្បាប់នេះត្រូវបានកំពុងធ្វើការត្រួតពិនិត្យ និងផ្តល់យោបល់ដោយក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

១៦.១.២. ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ក៏ត្រូវបានក្រសួងយុត្តិធម៌បានធ្វើសេចក្តីព្រាងរួចរាល់ហើយដែរ។ សេចក្តីព្រាងច្បាប់នេះ កំពុងត្រូវបានដាក់ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី។ បច្ចុប្បន្ន ក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រីកំពុងធ្វើការត្រួតពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងនេះ ។

១៦.១.៣. ច្បាប់ស្តីពីការធ្វើវិសោធនកម្មស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានក្រសួងយុត្តិធម៌ធ្វើសេចក្តីព្រាងរួចហើយ។ សេចក្តីព្រាងច្បាប់នេះក៏បានដាក់ជូនមកទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ បច្ចុប្បន្ន ច្បាប់កំពុងស្ថិតនៅក្នុងការពិនិត្យដោយក្រុមការងារបច្ចេកទេស នៃក្រុមប្រឹក្សាអ្នកច្បាប់ ។

១៦.១.៤. បច្ចុប្បន្ននេះ គណៈរដ្ឋមន្ត្រីមិនទាន់បានអនុម័តលើសេចក្តីព្រាងច្បាប់ទាំងបីនេះនៅឡើយទេ។ យោងតាមមន្ត្រីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បានឱ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំប្រឹងប្រែងជំរុញការអនុម័តច្បាប់សំខាន់ចាំបាច់ទាំងបីឱ្យបានតាមពេលវេលាដែលបានកំណត់នៅឆ្នាំ ២០១១នេះ។

**សូចនាករ ១៦.២.** បញ្ចប់ផែនការសកម្មភាពរបស់តុលាការគំរូទាំង៤

១៦.២.៥. ប្រទេសកម្ពុជាបានរៀបចំឱ្យមានជា តុលាការគំរូ៤ លើកដំបូង រួមមានៈ សាលាដំបូងរាជធានីភ្នំពេញ សាលាដំបូងខេត្តកណ្តាល សាលាដំបូងខេត្តកំពង់ចាម និងសាលាដំបូងខេត្តបន្ទាយមានជ័យ ។ ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានភារកិច្ចរៀបចំផែនការសកម្មភាព និងឯកសារពាក់ព័ន្ធនឹងគំរោងតុលាការគំរូទាំង៤ ក៏បានរៀបចំចប់សព្វគ្រប់ហើយបញ្ជូនមកក្រសួងយុត្តិធម៌ រួចរាល់ហើយដែរ ។

១៦.២.៦.ក្រសួងយុត្តិធម៌ និងសាលាដំបូងទាំង៤ បានព្រមព្រៀងគ្នារៀបចំនូវក្រុមការងារដើម្បីកំណត់នូវសកម្មភាពជាអាទិភាពសំរាប់អនុវត្តក្នុង ឆ្នាំ ២០១១ និង ២០១២។ សកម្មភាពជាអទិភាពទាំងនោះមាន៨ គឺ :

១-រៀបចំកិច្ចប្រជុំ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ លើការងារអនុវត្តតុលាការគំរូ

២-រៀបចំផែនការសកម្មភាពមួយឆ្នាំ និងផែនការយុទ្ធសាស្ត្រ ៣ឆ្នាំ

៣-បង្កើតសៀវភៅចុះបញ្ជីសំណុំរឿង ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី សំរាប់តុលាការទាំង៤

៤-រៀបចំតារាងកាលវិភាគជំនុំជំរះក្តីប្រចាំខែ

៥-រៀបចំសៀវភៅតាមដានរឿងក្តីសំរាប់ប្រធានតុលាការ

៦-រៀបចំការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិច

៧-បណ្តុះបណ្តាលមន្រ្តីបង្គោលដើម្បីចុះបញ្ជីក្នុងសៀវភៅ និងតាមប្រព័ន្ធអេឡិចត្រូនិច

៨-រៀបចំថវិកាសំរាប់ផ្ញើឯកសាររឿងក្តីព្រហ្មទណ្ឌ និង សំរាប់ការបកប្រែ និងការធ្វើកោសល្យវិច្ច័យ ។

១៦.២.៧. ក្រសួងយុត្តិធមិបានសំរេចសមិទ្ធិផល នៃសកម្មភាពអាទិភាពដែលបានកំណត់ក្នុងផែនការ និងបានរៀបចំដាក់សំណើថវិកាសំរាប់គាំទ្រការអនុវត្តគំរោងតុលាការគំរូទៅជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចហើយ។ យោងតាមព័ត៌មានពីមន្រ្តីជាន់ខ្ពស់នៃក្រសួងយុត្តិធមិ សំណើថវិកានៃគំរោងនេះកំពុងស្ថិតក្នុងការពិចារណារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក៏ដោយ គំរោងតុលាការគំរូនេះក៏បាននិងកំពុងអនុវត្តដោយក្រសួងយុត្តិធមិ និងតុលាការគំរូទាំង៤ជាបណ្តើរៗដោយមានការគាំទ្រមូលនិធិពីគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងប្រព័ន្ធយុត្តិធមិនៅកម្ពុជារបស់អូស្ត្រាលី ។

## ៣. អនុសាសន៍សំរាប់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

- រាជរដ្ឋាភិបាលកម្ពុជា គួរតែពន្លឿនការអនុម័តច្បាប់សំខាន់ៗទាំងបីខាងលើទៅតាមការកំណត់ឆ្នាំ២០១១ ដោយអនុញ្ញាតឱ្យមានការចូលរួមពីវិស័យពាក់ព័ន្ធ ជាពិសេស អង្គការសង្គមស៊ីវិល។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរតែបែងចែកថវិកាសំរាប់ក្រសួងយុត្តិធមិដើម្បីអនុវត្តគំរោងសាកល្បងនៃតុលាការគំរូ ដែលជាការបង្ហាញជាគំរូល្អនូវប្រសិទ្ធិភាពនៃប្រព័ន្ធយុត្តិធមិនៅកម្ពុជា។
- ក្រសួងយុត្តិធមិគួរតែសហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើតយុទ្ធនាការអប់រំ និងបង្កើនចំណេះដឹងឱ្យបានទូលំទូលាយទៅដល់ថ្នាក់មូលដ្ឋានអំពីច្បាប់ជាពិសេសច្បាប់នានាដែលទើបអនុម័តថ្មីៗ។
- ដៃគូអភិវឌ្ឍន៍គួរតែបន្តការគាំទ្រសកម្មភាពអង្គការសង្គមស៊ីវិល ជាពិសេស អង្គការជំនួយផ្នែកច្បាប់ ដែលធ្វើការគាំទ្រដល់ជនក្រីក្រ និងក្រុមជនងាយរងគ្រោះនានា។
- ដៃគូអភិវឌ្ឍន៍គួរបន្តការគាំទ្រដល់រដ្ឋាភិបាល ទាំងជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស សំរាប់គាំទ្រការអនុវត្តន៍គំរោងសាកល្បងនៃតុលាការគំរូទាំង៤ នេះ។

## ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទំនាក់ទំនង:


**គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា** (CHRAC)

-លោក ធន សារ៉ាយ ប្រធានសម្របសម្រួល CHRAC/ ប្រធានសមាគមអាដហុក

-លោក សួន សារ៉េត នាយកប្រតិបត្តិនៃលេខា/ ប្រធានលេខាធិការដ្ឋាន

ទូរស័ព្ទ : ៨៥៥-២៣ ៣០៥ ៦០៩

ទូរសារ: ៨៥៥-២៣ ២១៨ ៧៥៩

Email: chrac@everyday.com.kh, chrac@forum.org.kh

Website: www.chrac.org

# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តម្លាភាពថវិកា និងការពិនិត្យមើលពីសាធារណជន

## ១. សូចនាករតាមដានរួមទី ១៩: ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| | | | | |
|---|---|---|---|---|
| **ស្ថាប័នសម្របសម្រួល:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ/ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>**ស្ថាប័នអនុវត្ត:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ឬស្ថាប័នសាមី (៣៥) | | | | |
| **ទលទ្ធផលរយៈពេលមធ្យម** | **ធាតុចេញ** | **សូចនាករធាតុចេញ** | **សកម្មភាព: ចំណុចដៅសកម្មភាព** | **សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ** |
| ពង្រឹងភាពជឿទុកចិត្តនៃថវិកា និងបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ | ......<br>គោលនយោបាយ ប្រព័ន្ធ និងសមត្ថភាពគ្រប់គ្រងសាច់ប្រាក់ និងបំណុលត្រូវបានពង្រឹង<br>....... | ......<br>៣. បង្កើនតម្លាភាពក្នុងការគ្រប់គ្រងចំណូលពន្ធ និងមិនមែនសារពើពន្ធ<br>៤. បំណុលកកស្ទះមិនឱ្យលើសពី ២%នៃចំណាយសរុប<br>៥. ចំណាយពាក់កណ្តាលឆ្នាំ ឬចុងឆ្នាំមិនត្រូវតិចជាង: ៤៥% (សម្រាប់ត្រីមាសទី២) និង ៩៦% (សម្រាប់ត្រីមាសទី៤)<br>...... | ......<br>៣. ពង្រឹងប្រព័ន្ធព្យាករណ៍ចំណូល ប្រព័ន្ធប្រមូលចំណូល និងសមត្ថភាព<br>៤. បន្តកែលម្អការកត់ត្រាអាណត្តិបើកប្រាក់ដល់កំណត់<br>៥. ពង្រឹងប្រសិទ្ធភាពនៃប្រព័ន្ធរបាយការណ៍ប្រចាំឆមាស និងធ្វើវិសហមជ្ឈការក្នុងការទទួលខុសត្រូវ<br>....... | ១. ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈមានសមាសភាព សំខាន់ៗដែលបានចូលរួមបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ (ផែនការសកម្មភាពនៃកម្មវិធីកំណែ ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ)<br>២. កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ និងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំជាច្រើនត្រូវបាន រៀបចំ ដើម្បីពិភាក្សា និងតាមដានត្រួតពិនិត្យកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |

សេចក្តីថ្លែងការណ៍នេះ ត្រូវបានរៀបចំឡើងដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលជាសមាជិកនៃក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងសមាជិកបណ្តាញបានធ្វើការតាមដានគោលបំណងទី១២ ស្តីពីការគ្រប់គ្រងបំណុល គោលបំណងទី ១៤ ស្តីពីលទ្ធកម្មសាធារណៈ និងគោលបំណងទី ២៥.៤ ស្តីពីទម្រង់នៃការធ្វើរបាយការណ៍ទៅកាន់ និងការទំនាក់ទំនងជាមួយសាធារណជន។

## ២. ការតាមដានវឌ្ឍនភាពលើចំណុចដៅសកម្មភាព និងគោលដៅគន្លឹះនៅក្នុងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២

ចាប់តាំងពីការឯកភាពលើសូចនាករតាមដានរួមឆ្នាំ២០១០ នៅក្នុងកិច្ចប្រជុំ CDCF រួចមក រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវវឌ្ឍនភាពដ៏ច្រើនជាបន្តបន្ទាប់នូវកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២។ ដូចដែលអង្គការមិនមែនរដ្ឋាភិបាលបានសង្កេតឃើញរហូតមកដល់ត្រឹម ខែមីនា ឆ្នាំ២០១១ យើងឃើញមានវឌ្ឍនភាពជាច្រើនដែលទទួលបាននៅតាមផ្នែកផ្សេងៗ (សកម្មភាព និងគោលដៅគន្លឹះ) ដែលពាក់ព័ន្ធនឹងតម្លាភាពថវិកានៅក្នុងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ដែលផ្នែកទាំងនេះត្រូវបានតាមដានដោយអង្គការមិនមែនរដ្ឋាភិបាល ជាពិសេសនៅក្នុងគោលបំណងទី ១២ លើផ្នែក "ធ្វើឱ្យប្រសើរឡើង

បន្ថែមទៀតដល់ការគ្រប់គ្រងចំណូល" គោលបំណងទី១៤ ស្ដីពី "ការធ្វើឱ្យប្រសើរឡើងបន្ថែមទៀតដល់លទ្ធកម្មសាធារណៈ" និង គោលបំណងទី ២៥.៤ ស្ដីពី "ការធ្វើឱ្យប្រសើរឡើងដល់ទម្រង់នៃការធ្វើរបាយការណ៍ទៅកាន់ និងការទំនាក់ទំនងជាមួយសាធារណជន"។

បន្ថែមលើសូចនាករតាមដានរួម និងសកម្មភាពនៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ អង្គការមិនមែនរដ្ឋាភិបាលសូមកោតសរសើរយ៉ាងខ្លាំង និងអបអរសាទរចំពោះគំនិតផ្ដួចផ្ដើមថ្មី និងការបោះជំហានទៅមុខ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងការបង្កើនតម្លាភាពនៃដំណើរការថវិកា តាមរយៈការបោះផ្សាយទាន់ពេលវេលានូវរបាយការណ៍ពាក់កណ្ដាលឆ្នាំនៃការអនុវត្តថវិកាឆ្នាំ២០១០ នៅលើគេហទំព័ររបស់ខ្លួនក្នុងខែកញ្ញា ឆ្នាំ២០១០ ហើយនិងការបញ្ចេញនូវសេចក្ដីព្រាងច្បាប់ថវិកាឆ្នាំ២០១១ ក្នុងខែវិច្ឆិកា ឆ្នាំ២០១០ ជូនដល់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជាសម្រាប់ធ្វើការវិភាគទៅលើសេចក្ដីព្រាងច្បាប់នេះ។ ការវិភាគនេះត្រូវបានប្រើជាធាតុចូលសម្រាប់ការពិភាក្សា នៅក្នុងសិក្ខាសាលាសភាស្ដីពីសេចក្ដីព្រាងច្បាប់ថវិកាឆ្នាំ២០១១ ដែលបានរៀបចំឡើងមុនពេលការពិភាក្សាអនុម័តច្បាប់នេះនៅរដ្ឋសភាជាតិ។ ជំហានទៅមុខមួយទៀតគឺថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្សព្វផ្សាយព័ត៌មាននៅលើគេហទំព័ររបស់ខ្លួនស្ដីពីលទ្ធកម្មសាធារណៈសម្រាប់រាជរដ្ឋាភិបាលទាំងមូល ដោយមានផ្សព្វផ្សាយឱកាសក្នុងការដេញថ្លៃទៅកាន់សាធារណជន។ យើងខ្ញុំសង្ឃឹមថា ជំហានវិជ្ជមាន និងការប្ដេជ្ញានេះគប្បីមានជាបន្តទៀត ដើម្បីឈានដល់សម្រេចគោលដៅផ្សេងៗទៀតនៅក្នុងគោលបំណងខាងលើ។

វឌ្ឍនភាពខាងក្រោមនេះ ផ្អែកទៅលើរបាយការណ៍វឌ្ឍនភាព ដែលបានធ្វើឡើងដោយលេខាធិការដ្ឋានការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបទពិសោធន៍របស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានជួបប្រទះក្នុងការព្យាយាមដើម្បីទទួលបាននូវឯកសារ និងព័ត៌មានថវិកាពីរាជរដ្ឋាភិបាល និងពីគេហទំព័ររបស់ក្រសួង។ ផ្នែកនីមួយៗនៃគោលបំណង និងគោលដៅ រួមជាមួយនឹងវឌ្ឍនភាពដែលនឹងត្រូវបានតាមដាន មានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ។

### ***គោលបំណងទី១២: ការតាមដានវឌ្ឍនភាពនៃការគ្រប់គ្រងចំណូល***

### **ផ្នែកទីមួយ: សកម្មភាពសម្រាប់ជំហានទី១ ដើម្បីពង្រឹងក្នុងដំណាក់កាលទី២**

| ***គោលបំណង១២: បន្តកែលម្អការគ្រប់គ្រងចំណូល*** | | | | |
|---|---|---|---|---|
| **គោលបំណង/សកម្មភាព** | **សូចនាករគន្លឹះ** | **គោលដៅ** | | |
| | | **២០០៨** | **២០០៩** | **២០១០** |
| *១២.១...*<br>*១២.២. រៀបចំ និងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងចំណូល* | ...<br>រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងចំណូលប្រចាំឆ្នាំ | ...<br>ចាប់ផ្ដើមរៀបចំយុទ្ធសាស្ត្រចំណូលប្រចាំឆ្នាំ | ...<br>យុទ្ធសាស្ត្រចំណូលប្រចាំឆ្នាំត្រូវបានរៀបចំ | ...<br>ត្រួតពិនិត្យឡើងវិញយុទ្ធសាស្ត្រ ដែលបានបង្កើត |
| *១២.៣. បង្កើនការប្រើប្រាស់ប្រព័ន្ធទិន្នន័យចំណូល* | គុណភាពនៃការកត់ត្រា និងរបាយការណ៍ចំណូលក្នុងប្រទេស និងក្រៅប្រទេសត្រូវបានកែលម្អ | បង្កើតរបាយការណ៍តាមដានចំណូលប្រចាំត្រីមាស និងប្រចាំឆ្នាំ | បង្កើតរបាយការណ៍តាមដានចំណូលប្រចាំឆ្នាំ ត្រីមាស ដែលមានលក្ខណៈពេញលេញ ព្រមទាំងធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់ជាប្រចាំ | បង្កើតប្រព័ន្ធត្រួតពិនិត្យតាមដាន និងការគ្រប់គ្រងចំណូលពេញលេញជាមួយនឹងរបាយការណ៍ស្ថិតិ និងរបាយការណ៍គ្រប់គ្រងគ្រប់ជ្រុងជ្រោយ |

ប្រភព: កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ ទំព័រ ៥០-៥១ (ជាភាសាខ្មែរ)

ដោយយោងតាមរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១០ (ដែលអាចទទួលយកបានតាមរយៈ www.pfm.gov.kh) បានបង្ហាញថា មានការប្រសើរឡើងបន្ថែមទៀតក្នុងការរៀបចំក្របខ័ណ្ឌច្បាប់ និងការកសាងសមត្ថភាព ហើយមានការផលិតជាទៀងទាត់នូវរបាយការណ៍តាមដានបំណុលប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ។ ទោះជាយ៉ាងណា មិនមានការលើកឡើងអំពីវឌ្ឍនភាពពាក់ព័ន្ធនឹងការផ្សព្វផ្សាយរបាយការណ៍បំណុលរបស់កម្ពុជានេះ ជាសាធារណៈទេ។ ដូចគ្នានេះដែរ អង្គការមិនមែនរដ្ឋាភិបាលក៏បានសង្កេតឃើញផងដែរថារបាយការណ៍ទាំងនេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬរាជកិច្ចឡើយ លើកលែងតែព័ត៌មានស្តីពីលក្ខខណ្ឌជំនួយនៃគម្រោងកម្ចីដែលកម្ពុជាជំពាក់ដែលត្រូវបានផ្សព្វផ្សាយនៅលើប្រព័ន្ធទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការក្នុងគេហទំព័រនៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ លើសពីនេះទៀត ផ្អែកលើវឌ្ឍនភាពដែលបានរាយការណ៍ឡើងដោយលេខាធិការដ្ឋានការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាលពីថ្ងៃទី២២ ខែមិនាឆ្នាំ២០១១ សេចក្តីព្រាងអនុក្រឹត្យលើកទី៨ ស្តីពីការគ្រប់គ្រងបំណុលសាធារណៈត្រូវបានបង្កើតឡើង ហើយត្រូវបានពិភាក្សានៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសេចក្តីព្រាងចុងក្រោយស្តីពីយុទ្ធសាស្ត្រការគ្រប់គ្រងបំណុលក៏ត្រូវបានបង្កើត និងពិនិត្យឡើងវិញផងដែរសម្រាប់ការពិភាក្សាផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ យើងខ្ញុំសង្ឃឹមនិងជឿជាក់ថាបញ្ញត្តិស្តីពីការផ្សព្វផ្សាយព័ត៌មានស្តីពីបំណុលជាសាធារណៈនឹងត្រូវបានដាក់បញ្ចូលនៅក្នុងអនុក្រឹត្យនេះ។

ការវិភាគរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា លើព័ត៌មានដែលពាក់ព័ន្ធនឹងលក្ខខណ្ឌជំនួយ (រួមមានអត្រាការប្រាក់ រយៈពេលអនុគ្រោះ និងរយៈពេលសងរំលោះ) នៃកម្ចីសម្បទានបរទេសសម្រាប់ប្រទេសកម្ពុជា ដោយប្រើប្រាស់ព័ត៌មានដែលមាននៅលើគេហទំព័រស្តីពីទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការដែលឋិតនៅក្រោមគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (CRBD) នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បង្ហាញថា គម្រោងចំនួន ៣៥ ឬ ៣៤%នៃគម្រោងកម្ចីសម្បទានចំនួន ១០៤ ដែលស្រង់ចេញក្នុងខែមិថុនា និងកក្កដា ឆ្នាំ២០១០ ពីគេហទំព័រនេះ មិនមានព័ត៌មានស្តីពីរយៈពេលអនុគ្រោះ ឬរយៈពេលសងរំលោះឡើយ។ លើសពីនេះទៅទៀត គម្រោងចំនួន ២២ ក្នុងចំណោមគម្រោងចំនួន ១០៤ ពុំមានព័ត៌មានអំពីកាលបរិច្ឆេទនៃការចាប់ផ្តើម និងបញ្ចប់គម្រោងឡើយ។ ដោយទទួលស្គាល់នូវបញ្ហាប្រឈមរបស់រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (និង CDC/CRBD) លើការធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នៅក្នុងប្រព័ន្ធនៃការគ្រប់គ្រងបំណុល និងវិភាគហិរញ្ញវត្ថុ (DMFAS) និងការវិភាគលើចីរភាពបំណុលនោះ អង្គការមិនមែនរដ្ឋាភិបាលសូមស្នើសុំរាជរដ្ឋាភិបាលកម្ពុជាឱ្យធ្វើការផ្តល់អាទិភាពទៅលើការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍តាមដានបំណុលនៅក្នុងត្រីមាសទី២ឆ្នាំ២០១១។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលក៏សូមសំណូមពរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងដៃគូអភិវឌ្ឍន៍ ក្នុងការចូលរួមពិភាក្សា និងលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋតាមរយៈសិក្ខាសាលានានាស្តីពីតម្លាភាពព័ត៌មានជំនួយ និងការគ្រប់គ្រងបំណុលដែលនឹងរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល។

***គោលបំណងទី១៤: ការតាមដានវឌ្ឍនភាពនៃលទ្ធកម្មសាធារណៈ***

| **គោលបំណង ១៤: បន្តកែលម្អលទ្ធកម្មសាធារណៈ** | | | | |
|---|---|---|---|---|
| **គោលបំណង/សកម្មភាព** | **សូចនាករគន្លឹះ** | **គោលដៅ** | | |
| | | **២០០៨** | **២០០៩** | **២០១០** |
| ......<br>១៤.៥. បង្កើនភាពប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការលទ្ធកម្ម តាមរយៈការបង្កើនការផ្សព្វផ្សាយជាសាធារណៈ និងដោយចំហ | គេហទំព័រសម្រាប់ដំណើរការកិច្ចលទ្ធកម្មត្រូវបានបង្កើតនិងប្រើប្រាស់ | ...... | គេហទំព័រត្រូវបានបង្កើត | ៥០%នៃការដេញថ្លៃ និងព័ត៌មានស្តីពីការប្រគល់កិច្ចសន្យាត្រូវបានបោះផ្សាយ |

ប្រភព: កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ ទំព័រ ៥៦-៥៧ (ជាភាសាខ្មែរ)

ដោយផ្អែកលើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដែលបានចែកជូននៅក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសកាលពីខែមិនា ឆ្នាំ២០១១ បានបង្ហាញថា ការប្តេជ្ញាចិត្តក្នុងការបញ្ចប់គេហទំព័រស្តីពីលទ្ធកម្ម និងការសាកល្បងត្រឹមចុងឆ្នាំ២០១០នោះមិនទាន់បានសម្រេចតាមផែនការនៅឡើយទេ ដោយសារតែការរង់ចាំ Hardware ដែលកំពុងតែដាក់ដេញថ្លៃនៅឡើយ។ ទោះជាមានការយឺតយ៉ាវយ៉ាងនេះក្តី ក៏ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ តាមរយៈការផ្សព្វផ្សាយព័ត៌មានស្តីពីការដេញថ្លៃលទ្ធកម្មនៅលើគេហទំព័ររបស់ខ្លួន។ ដោយហេតុថាគោលដៅនេះមិនត្រូវបានសម្រេចនៅក្នុងឆ្នាំ២០១០ និងនៅត្រីមាសទីមួយឆ្នាំ២០១១ ហើយនិងដោយទទួលស្គាល់អំពីតម្រូវការផ្សេងៗដែលពាក់ព័ន្ធនឹងនីតិវិធី ការបណ្តុះបណ្តាល និងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (សេចក្តីព្រាងលើកទីមួយនៃច្បាប់ ស្តីពីលទ្ធកម្មសាធារណៈ ត្រូវបានដាក់សម្រាប់ពិភាក្សាពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ និងវិស័យឯកជនកាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១) អង្គការមិនមែនរដ្ឋាភិបាលជឿជាក់ថា ដោយមានការប្តេជ្ញាខ្ពស់របស់ក្រសួង និងការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ គេហទំព័រនេះនឹងអាចសម្រេចទៅបាននៅក្នុងឆមាសទី២នៃឆ្នាំ ២០១១។

***គោលបំណងទី ២៥.៤: ការតាមដានវឌ្ឍនភាពនៃការធ្វើឱ្យប្រសើរឡើងនូវទម្រង់នៃការរាយការណ៍ទៅកាន់ និងទំនាក់ទំនងជាមួយសាធារណជន***

**ផ្នែកទី២: សកម្មភាពសម្រាប់ជំហានទី២ ដើម្បីអនុវត្តន៍ក្នុងដំណាក់កាលទី២**

| **គោលបំណង២៥: កែលម្អប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុដើម្បីធានាតម្លាភាព** | | | | |
|---|---|---|---|---|
| **គោលបំណង/សកម្មភាព** | **សូចនាករគន្លឹះ** | **គោលដៅ** | | |
| | | **២០០៨** | **២០០៩** | **២០១០** |
| ......<br>២៥.៤ កែលម្អទំរង់របាយការណ៍ និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន | ព័ត៌មានហិរញ្ញវត្ថុសំខាន់ៗអាចរកបាន:<br>- ឯកសារថវិកា<br>- របាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ<br>- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ<br>- របាយការណ៍សវនកម្មផ្ទៃ ក្រៅ<br>- ការប្រគល់កិច្ចសន្យា<br>- ការផ្តល់ធនធានសម្រាប់អង្គភាពផ្តល់សេវានៅមូលដ្ឋាន (សូចនាករ *10 PEFA*) | យ៉ាងហោចណាស់ របាយការណ៍ ៣ ក្នុងចំណោមរបាយការណ៍ទាំង៦ ត្រូវបានផ្សព្វផ្សាយ | យ៉ាងហោចណាស់ របាយការណ៍ ៤ ក្នុងចំណោម របាយការណ៍ទាំង៦ ត្រូវបានផ្សព្វផ្សាយ | យ៉ាងហោចណាស់ ត្រូវមានរបាយការណ៍ ៥ ក្នុងចំណោម របាយការណ៍ទាំង ៦ ត្រូវបានផ្សព្វផ្សាយ |

ប្រភព: កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ ទំព័រ ៧៤ (ជាភាសាខ្មែរ)

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាសូមកោតសរសើរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការផ្សព្វផ្សាយតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈប្រចាំខែនៅលើគេហទំព័ររបស់ខ្លួន និងនាពេលថ្មីៗនេះបានបញ្ចេញនូវសៀវភៅឯកសារថវិកាទូទៅរបស់រដ្ឋ(មាន៤ភាគ) បន្ទាប់ពីការដាក់លិខិតស្នើសុំរបស់យើងខ្ញុំទៅកាន់នាយកដ្ឋានថវិការបស់ក្រសួង។ ដោយយោងតាមកិច្ចប្រជុំក្រុមការងារបច្ចេកទេសការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅខែមីនា ឆ្នាំ២០១១ អង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ពីវឌ្ឍនភាពថ្មីៗ បញ្ហាប្រឈម និងការប្តេជ្ញាចិត្តដើម្បីសម្រេចបាននូវគោលដៅជាក់លាក់ និងជំហានបន្ទាប់ទៀត។ ទោះជាយ៉ាងណា តាមរយៈការសង្កេតឃើញថា ព័ត៌មានស្តីការប្រគល់កិច្ចសន្យាឬកិច្ចសន្យាដែលបានផ្តល់ ឬការផ្តល់ធនធានសម្រាប់អង្គភាពផ្តល់សេវានៅមូលដ្ឋានដែលគួរតែត្រូវបានផ្សព្វផ្សាយនៅឆ្នាំ២០១០ បន្ថែមលើឯកសារដែលបានផ្សព្វផ្សាយចំនួន៤ផ្សេងទៀត មិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅឡើយទេគិតត្រឹមខែមីនា ឆ្នាំ២០១១។ តាមរយៈការយល់ឃើញរបស់យើងខ្ញុំ ការផ្តល់កិច្ចសន្យាដែលត្រូវផ្សព្វផ្សាយនោះគួរតែស្របជាមួយនឹងការបង្កើត និងដំណើរការគេហទំព័រលទ្ធកម្មសាធារណៈ។ ទោះជាយ៉ាងណា នៅខណៈដែលគេហទំព័រនេះមិនទាន់បានបង្កើតរួចរាល់នៅឡើយនោះ ព័ត៌មានស្តីពីកិច្ចសន្យាដែលបានផ្តល់ទាំងនោះក៏អាចផ្សព្វផ្សាយបានផងដែរតាមរយៈវិធីផ្សេងទៀតដែលចំណាយតិចតួច ដូចជា ការផ្សព្វផ្សាយលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានស្រាប់ ឬនៅក្នុងសៀវភៅរាជកិច្ចជាដើម។

បន្ថែមលើសមិទ្ធិផលសម្រេចបានដោយអាជ្ញាធរសវនកម្មជាតិ និងរដ្ឋសភា នៅក្នុងការផ្សព្វផ្សាយរបាយការណ៍សវនកម្មឆ្នាំ២០០៦ នៅក្នុងខែតុលា ឆ្នាំ២០០៩ អង្គការមិនមែនរដ្ឋភិបាលសូមឱ្យមានការប្តេជ្ញាជាបន្តទៀតទៅលើការផ្សព្វផ្សាយរបាយការណ៍សវនកម្មសម្រាប់ឆ្នាំ ២០០៧ ២០០៨ និង ២០០៩ នៅក្នុងឆ្នាំ២០១១ ឬយ៉ាងហោចណាស់ក្នុងកំឡុងពេលពីរឆ្នាំបន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធដោយអនុលោមតាមការប្រតិបត្តិល្អជាអន្តរជាតិ[៧]។ លើសពីនេះទៀត ខណៈដែលមានការផ្សព្វផ្សាយជាទៀតទាត់នូវតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនោះ ប្រការគួរឱ្យកត់សម្គាល់អំពីតារាងនេះ គប្បីផ្តោតលើការកែលម្អនូវគុណភាពនៃព័ត៌មានដែលមានស្រាប់ ជាពិសេស ការដាក់បញ្ចូលនូវព័ត៌មានលម្អិតតាមក្រសួងនៅក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុប្រចាំខែ ឆមាស និងប្រចាំឆ្នាំ។ ការដាក់បញ្ចូលនូវព័ត៌មានលម្អិតទាំងនេះ នឹងអនុញ្ញាតិឱ្យសាធារណជន និងភាគីពាក់ព័ន្ធដែលរួមមានអង្គការសង្គមស៊ីវិលក្នុងការវាស់វែងពីកម្រិតនៃភាពជឿទុកចិត្តបាននៃការអនុវត្តថវិការបស់ក្រសួងសាម៉ីធៀបទៅនឹងការបែងចែកនៅក្នុងច្បាប់ថវិកាជាតិ។

## ៣. អនុសាសន៍សម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងការធ្វើឱ្យប្រសើរឡើងថែមទៀតនៃតម្លាភាពការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬថវិកាជាតិ

ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងថែមទៀតនូវតម្លាភាពហិរញ្ញវត្ថុសាធារណៈនៅប្រទេសកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលសូមអំពាវនាវដល់រាជរដ្ឋាភិបាលជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ផ្តល់អាទិភាពដល់ការសម្រេចឱ្យបាននូវចំនុចខាងក្រោម នៅក្នុងឆមាសទី២នៃឆ្នាំ២០១១ និងឱ្យបានមុនកិច្ចប្រជុំ CDCF លើកទី ៤:

---

[៧] នេះគឺជាអនុសាសន៍របស់ភាពជាដៃគូថវិកាអន្តរជាតិ។ ការប្រតិបត្តិល្អអន្តរជាតិ ដែលផ្តល់ដោយសៀវភៅណែនាំស្តីពីតម្លាភាពសារពើពន្ធរបស់ IMF ឆ្នាំ២០០៧ គឺមានរយៈពេលខ្លីជាងនេះទៅទៀត ពោលគឺ ១ ឆ្នាំក្រោយបញ្ចប់ឆ្នាំសារពើពន្ធ។

១. ផ្សព្វផ្សាយរបាយការណ៍តាមដានបំណុលប្រចាំត្រីមាស និងប្រចាំឆ្នាំ ឬដោយបញ្ចូលព័ត៌មាននេះទៅក្នុងរបាយការណ៍ស្តីពីការអនុវត្តថវិការដ្ឋរួមជាមួយនឹងតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ឬផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២. បញ្ចប់ និងដាក់ឱ្យដំណើរការនូវគេហទំព័រលទ្ធកម្មសាធារណៈ។

៣. ផ្សព្វផ្សាយកិច្ចសន្យាដែលបានផ្តល់តាមរយៈវិធីផ្សេងទៀតដែលមានទំនាក់ទំនងជាមួយសាធារណជនពោលគឺ តាមរយៈគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចគ្នានឹងព័ត៌មានដេញថ្លៃលទ្ធកម្មសាធារណៈ ឬក៏តាមរយៈសៀវភៅរាជកិច្ច។

៤. អាជ្ញាធរសវនកម្មជាតិ គប្បីផ្សព្វផ្សាយរបាយការណ៍សវនកម្មឆ្នាំ២០០៧ ២០០៨ និង ២០០៩ ក្នុងឆ្នាំ២០១១នេះ។

៥. ដាក់បញ្ចូលនូវព័ត៌មានលម្អិតតាមក្រសួងនានា នៅក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈប្រចាំខែ ឆមាស និងប្រចាំឆ្នាំ។

**ព័ត៌មានទំនាក់ទំនង**

សម្រាប់ព័ត៌មានបន្ថែមអំពីសេចក្តីថ្លែងការណ៍នេះ សូមទំនាក់ទំនង


**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា** (**The NGO Forum on Cambodia**)

លោក **ឈិត សំអាត** នាយកប្រតិបត្តិ

# ៩-១១ ផ្លូវ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ: (៨៥៥) ២៣ ២១៤ ៤២៩

ទូរសារ: (៨៥៥) ២៣ ៩៩៤ ០៦៣

អ៊ីមែល: ngoforum@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh

# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្ម

## ១. សូចនាករតាមដានរួម

សូចនាករតាមដានរួម (JMI) ដែលពាក់ព័ន្ធនឹងតម្លាភាពចំណូលធនធាន គឺជាសូចនាករតាមដានរួមលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ (PFMRP II) ។ សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន (CRRT) គឺជាសម្ព័ន្ធភាពអង្គការកម្ពុជាមួយបង្កើតឡើងសម្រាប់តាមដានតម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងចំណូល (ការប្រមូល និងការចំណាយ) ពីឧស្សាហកម្មនិស្សារណកម្ម (ប្រេង ឧស្ម័ន និងរ៉ែ) ដើម្បីធានាថា ចំណូលទាំងនេះត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលសម្រាប់ជាប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់រូប (សម្រាប់ព័ត៌មានលម្អិត សូមមើលព័ត៌មានទំនាក់ទំនងនៅផ្នែកខាងក្រោមនេះ) ។ សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន ឃ្លាំមើលផ្នែកចំណូលពីឧស្សាហកម្មនិស្សារណកម្ម នៃ PFMRP II ។

| **ស្ថាប័នសម្របសម្រួល:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ/ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>**ស្ថាប័នអនុវត្ត:** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ឬស្ថាប័នសាមី | | | | |
|---|---|---|---|---|
| **ទល្ធផល រយៈពេលមធ្យម** | **ធាតុចេញ** | **សូចនាករធាតុចេញ** | **សកម្មភាព: ចំណុចដៅសកម្មភាព** | **សកម្មភាពដើម្បីបង្កើនប្រសិទ្ធភាពហិរញ្ញប្បទាន សហប្រតិបត្តិការ** |
| ១៩. ពង្រឹងភាពជឿទុកចិត្តនៃថវិកា និងបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ | ១. គោលនយោបាយចំណូល ព្យាករណ៍ និងប្រមូលចំណូល និងពង្រឹងតម្លាភាព និងសមត្ថភាពប្រមូលចំណូល<br>...... | ......<br>២. ក្របខណ្ឌច្បាប់សម្រាប់ឧស្សាហកម្មរុករក ត្រូវបានអនុម័ត និងអនុវត្ត<br>៣. បង្កើនតម្លាភាពក្នុងការគ្រប់គ្រងចំណូលពន្ធ និងមិនមែនសារពើពន្ធ<br>...... | ......<br>២. រៀបចំសេចក្តីព្រាងច្បាប់ពន្ធដារ ស្តីពីប្រេង និងឧស្ម័ន<br>៣. ពង្រឹងប្រព័ន្ធព្យាករណ៍ចំណូល ប្រព័ន្ធប្រមូលចំណូល និងសមត្ថភាព<br>...... | ១. ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានសមាសភាពសំខាន់ៗដែលបានចូលរួមបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ (ផែនការសកម្មភាពនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ)<br>២. កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ និងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំជាច្រើនត្រូវបានរៀបចំ ដើម្បីពិភាក្សា និងតាមដានត្រួតពិនិត្យកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |

## ២. វឌ្ឍនភាពនៃក្របខណ្ឌការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្ម

| **សកម្មភាព** | **សូចនាករគន្លឹះ** | **គោលដៅ** | | |
|---|---|---|---|---|
| | | **២០០៩** | **២០១០** | **២០១១** |
| ១១.២. បង្កើត និងអនុវត្តគោលនយោបាយចំណូលពីប្រេង/ឧស្ម័ន/រ៉ែ ។ បង្កើត | របបសារពើពន្ធលើប្រេង/ឧស្ម័ន/រ៉ែត្រូវបានកំណត់ និងក្របខណ្ឌច្បាប់ត្រូវបាន | របបសារពើពន្ធត្រូវបានកំណត់<br>ការសិក្សាពី EITI ត្រូវបាន | EITI ត្រូវបានអនុវត្តជាបឋម<br>ក្របខណ្ឌគ្រប់គ្រងចំណូល | អនុវត្ត EITI<br>អនុវត្តក្របខណ្ឌច្បាប់សម្រាប់គ្រប់គ្រងចំណូល |

| | | | | |
|---|---|---|---|---|
| និងអនុវត្តយន្តការគ្រប់គ្រងប្រកបដោយតម្លាភាពលើលំហូរចំណូលដោយរួមទាំងEITI ការវាយតម្លៃ និងសមត្ថភាពប្រមូល ចំណូល | អនុម័ត និងចាប់ផ្តើមអនុវត្ត | បញ្ចប់<br><br>ជម្រើសគោលនយោបាយគ្រប់គ្រងចំណូលប្រេង/ឧស្ម័ន/រ៉ែ ត្រូវបានរៀបចំ និងឯកភាព | ប្រេង/ឧស្ម័ន/រ៉ែ ត្រូវបានបង្កើត | ប្រេង/ឧស្ម័ន/រ៉ែ |

ប្រភព: កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ផែនការសកម្មភាពរួមសម្រាប់ដំណាក់កាលទី ២ (CAP2)

សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន បានកត់សម្គាល់អំពីវឌ្ឍនភាពសំខាន់ៗក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ជាពិសេសក្របខណ្ឌច្បាប់សម្រាប់គ្រប់គ្រងវិស័យឧស្សាហកម្មនិស្សារណកម្ម និងការកែលម្អការផ្សព្វផ្សាយព័ត៌មាន។ យោងតាមរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានផ្សព្វផ្សាយក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១១ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងធ្វើឱ្យប្រសើរឡើងនូវទិដ្ឋភាពមួយចំនួននៃការអភិវឌ្ឍឧស្សាហកម្មនិស្សារណកម្ម និងគួរត្រូវបានអបអរសាទរចំពោះការអភិវឌ្ឍជាវិជ្ជមាននេះ ដែលរួមមាន:

- គោលនយោបាយប្រមូលចំណូលត្រូវបានបញ្ចប់ទាន់ពេលវេលាក្នុងខែមីនា ឆ្នាំ២០១១ ទាំងភាសាខ្មែរ និងអង់គ្លេស
- គំរូសេដ្ឋកិច្ចដើម្បីវិភាគព្យាករណ៍លើការបែងចែកចំណូលពីប្រេង និងឧស្ម័នត្រូវបានកសាង
- សេចក្តីព្រាងច្បាប់វិសោធនកម្មទី២នៃច្បាប់សារពើពន្ធលើពន្ធប្រតិបត្តិការប្រេងកាត សេចក្តីព្រាងច្បាប់បរធនបាលកិច្ច និងសេចក្តីព្រាងដំបូងនៃច្បាប់ស្តីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ ត្រូវបានកសាង
- ប្រកាសស្តីពីការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត ត្រូវបានរៀបចំជាបណ្តើរៗ

ការអភិវឌ្ឍផ្សេងៗទៀត បន្ថែមពីលើរបាយការណ៍វឌ្ឍនភាពរបស់ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន ការធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់អាជ្ញាធរប្រេងកាតជាតិកម្ពុជា (ជាទីភ្នាក់ងារសម្រាប់ការទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុនសាជីវកម្មក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម) ការកែលម្អគេហទំព័ររបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មប្រេង ដែលត្រូវបានរៀបចំឡើងដោយអាជ្ញាធរប្រេងកាតជាតិកម្ពុជា និងការកែលម្អការកត់ត្រាចំណូលពីឧស្សាហកម្មនិស្សារណកម្មក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋ នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំពោះវឌ្ឍនភាពទាំងនេះ សមាជិកសម្ព័ន្ធភាពស្តីពីតម្លាភាពចំណូលធនធានសូមសម្តែងនូវការកោតសរសើរចំពោះការរីកចម្រើន និងការរៀបចំជាវិជ្ជមានទុកជាមុន ដើម្បីឈានឆ្ពោះទៅកាន់ការចាប់ផ្តើមនៃការរុករកប្រេង ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០១២ ខាងមុខនេះ។ ទោះជាយ៉ាងនេះក្តី ស្របជាមួយនឹងវឌ្ឍនភាពទាំងនេះ មានចំនុចមួយចំនួននៅមិនទាន់សម្រេចបាននៅឡើយដែលត្រូវបានសង្កេតឃើញក្នុងរបាយការណ៍វឌ្ឍនភាព និងការអនុវត្តជាក់ស្តែងរួមមាន:

- ផែនការអនុវត្តគោលនយោបាយប្រមូលចំណូល ដែលនឹងត្រូវកសាងត្រឹមខែធ្នូ ២០១០ និងសេចក្តីព្រាងក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រនៃការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលនឹងត្រូវរៀបចំត្រឹមខែធ្នូ ២០១០ មិនទាន់បានសម្រេចបានតាមផែនការទេ។

- សេចក្តីព្រាងច្បាប់វិសោធនកម្មទី២នៃច្បាប់សារពើពន្ធលើពន្ធប្រតិបត្តិការប្រេងកាត សេចក្តីព្រាងដំបូងនៃច្បាប់ស្តីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មប្រេង មិនត្រូវបានផ្សព្វផ្សាយសម្រាប់ការពិភាក្សា និងការពិគ្រោះយោបល់ជាសាធារណៈឡើយ ។

**ការកែលម្អបន្តទៀតនូវសកម្មភាពស្តីពីការពិគ្រោះយោបល់ជាសាធារណៈ និងគោលការណ៍ EITI**

តួនាទីដ៏សំខាន់របស់អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការជម្រុញឱ្យមានតម្លាភាព ត្រូវបានគេកត់សម្គាល់នៅក្នុងផែនការសកម្មភាពរបស់ក្រុមការងារអន្តរក្រសួងក្នុងការកៀរគរ និងគ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និងធនធានរ៉ែ និងដោយមានការទទួលស្គាល់របស់អាជ្ញាធរប្រេងកាតជាតិកម្ពុជា ដែលបានដាក់គេហទំព័ររបស់សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន ភ្ជាប់ទៅនឹងគេហទំព័ររបស់ខ្លួន ។ ទោះជាយ៉ាងនេះក្តី ដូចដែលបានសង្កេតឃើញខាងដើម គេពុំទាន់ឃើញមានការពិគ្រោះយោបល់ជាសាធារណៈ ឬការចូលរួមរបស់សង្គមស៊ីវិលដែលផ្តល់ដោយរាជរដ្ឋាភិបាលឡើយទៅលើ សេចក្តីព្រាងឯកសារច្បាប់សំខាន់ៗពាក់ព័ន្ធនឹងឧស្សាហកម្មនិស្សារណកម្ម ទោះជាមានការស្នើសុំជាបន្តបន្ទាប់ពីសំណាក់អង្គការសង្គមស៊ីវិលក៏ដោយ ។ ដោយហេតុថា ច្បាប់ និងលិខិតបទដ្ឋាន ទាំងនេះនឹងបង្កើតឱ្យមានក្របខណ្ឌដ៏រឹងមាំមួយ ថាតើអាជ្ញាប័ណ្ណ និងសម្បទាននានានឹងត្រូវបានផ្តល់ឱ្យដោយរបៀបណាខ្លះ ហើយឋិតក្រោមស្ថានភាពណាខ្លះ កន្លែងណាខ្លះ និងរបៀបណាខ្លះ ហើយឋិតនៅក្នុងកាលៈទេសៈដែលប្រាក់ចំណូលនឹងត្រូវបានបង់ឱ្យ និងរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា និងសម្រាប់ដោះស្រាយនូវបញ្ហាសង្គម និងសេដ្ឋកិច្ចដែលអាចប៉ះពាល់ដល់ប្រទេសកម្ពុជានាពេលជាច្រើនឆ្នាំខាងមុខ ការផ្សព្វផ្សាយនូវសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈនឹងផ្តល់នូវឱកាសដល់សាធារណជន និងអង្គការមិនមែនរដ្ឋាភិបាលបានចូលរួមចំណែកនៅក្នុងដំណើរការអភិវឌ្ឍវិស័យនេះ និងរឹតតែធ្វើឱ្យប្រសើរឡើងថែមទៀតទៅលើតម្លាភាពការគ្រប់គ្រងចំណូលពីធនធានសាធារណៈទាំងនេះ ។

ម្យ៉ាងវិញទៀត យោងតាមរបាយការណ៍វឌ្ឍនភាពឆ្នាំ ២០១០ ស្តីពីការអនុវត្ត PFMRP ក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់រៀបចំផែនការសកម្មភាព និងតាមដានការអនុវត្តការងារកៀរគរ និងគ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និងធនធានរ៉ែ ជាអ្នកទទួលបន្ទុកសិក្សា និងអនុវត្តគោលការណ៍គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម (EITI) ។ ប៉ុន្តែ ពុំទាន់មានសេចក្តីរាយការណ៍ណាមួយស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលការណ៍ EITI ពីសំណាក់ក្រុមការងារបច្ចេកទេសអន្តរក្រសួងនៅឡើយទេ ចាប់តាំងពីបានបង្កើតឡើងនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៩ និង/ឬក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ទោះជាយ៉ាងនេះក្តី ការប្តេជ្ញាចិត្តទាញយកគោលការណ៍ EITI មកអនុវត្ត ដែលបានបញ្ជាក់ក្នុង PFMRP មានវឌ្ឍនភាពតិចតួចប៉ុណ្ណោះក្នុងការផ្តល់ព័ត៌មានជាសាធារណៈស្តីពីចំណូល លើកលែងតែការកត់ត្រាចំណូលសរុបក្នុងបន្ទាត់មួយនៅក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) និងខ្លឹមសារមួយចំនួននៅក្នុងគេហទំព័រថ្មីរបស់អាជ្ញាធរប្រេងកាតជាតិកម្ពុជា ។ ប្រសិនបើរាជរដ្ឋាភិបាលមិនពិចារណាអំពីសមាជិកភាព EITI ទេ អង្គការមិនមែនរដ្ឋាភិបាលសូមសំណូមពរឱ្យរដ្ឋាភិបាលផ្សព្វផ្សាយថាតើ គោលការណ៍ណាមួយដែលរាជរដ្ឋាភិបាល បានអនុម័តយកមកប្រើប្រាស់ ឬមានផែនការអនុម័តយកមកប្រើប្រាស់ ដើម្បីធានានូវតម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណកម្មនេះ ។ តាមរយៈការផ្សព្វផ្សាយនេះ នឹងអាចឱ្យសាធារណជនបានយល់ដឹងបានកាន់តែច្បាស់ពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៅក្នុងការគ្រប់គ្រងចំណូលធនធាននេះ ។

## ៧. អនុសាសន៍សម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍លើការគ្រប់គ្រងចំណូលពីឧស្សាហកម្មនិស្សារណៈកម្ម

ផ្អែកលើវឌ្ឍនភាព និងការព្រួយបារម្ភដែលត្រូវបានលើកឡើងខាងលើ សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន សូមអំពាវនាវដល់រាជរដ្ឋាភិបាល (ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងអាជ្ញាធរប្រេងកាតជាតិកម្ពុជា) ចាត់វិធានការណ៍ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចឱ្យបាននូវគោលដៅដែលមិនទាន់បានសម្រេចខាងលើតាមរយៈ

១. ការឱ្យមានការចូលរួមពីសាធារណជន និងអង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីពន្ធប្រេង ច្បាប់សារពើពន្ធលើការធ្វើអាជីវកម្មរ៉ែ និងច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មប្រេង ពោលគឺតាមរយៈការផ្សព្វផ្សាយឯកសារសេចក្តីព្រាងច្បាប់ទាំងនេះ ព្រមជាមួយនិងការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការធ្វើការពិគ្រោះយោបល់ជាសាធារណៈ ។

២. ការបន្តពិចារណាអំពីសមាជិកភាព EITI ជាកត្តាអាទិភាពមួយនៅក្នុងផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសអន្តរក្រសួង ហើយព្រមទាំងប្រកាន់យកគោលការណ៍ EITI ដោយធ្វើឱ្យប្រសើរឡើងនូវភាពទៀងទាត់ និងភាពគ្រប់ជ្រុងជ្រោយនៃការរាយការណ៍អំពីចំណូលដែលបានមកពីឧស្សាហកម្មនិស្សារណកម្មនៅក្នុង TOFE លើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### ព័ត៌មានទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីសេចក្តីថ្លែងការណ៍នេះ សូមទាក់ទងមកកាន់:


**សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន (CRRT)**

# ៨៨ ផ្លូវ ៤៦៨ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

លោក **ម៉ម សម្បត្តិ** ប្រធានក្រុមប្រឹក្សាភិបាល

ទូរស័ព្ទ: (៨៥៥) ២៣ ២១៧ ៦០៧

ទូរស័ព្ទដៃ: (៨៥៥) ១២ ៧៧៩ ៧៣៤

អ៊ីមែល: mam.sambath@dpacam.org

លោក **ឆាយ សារ៉ាត** អ្នកសម្របសម្រួល

ទូរស័ព្ទ: (៨៥៥) ២៣ ២១៧ ៦០៧

ទូរស័ព្ទដៃ: (៨៥៥) ១២ ៥៨៩ ៥៥៨

អ៊ីមែល: crrtcoordinator@online.com.kh

គេហទំព័រ: www.crrt-cambodia.org

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

# ៩-១១ ផ្លូវ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

លោក **ឈិត សំអាត** នាយកប្រតិបត្តិ

ទូរស័ព្ទ: (៨៥៥) ២៣ ២១៤ ៤២៩

ទូរសារ: (៨៥៥) ២៣ ៩៩៤ ០៦៣

អ៊ីមែល: ngoforum@ngoforum.org.kh

គេហទំព័រ: www.ngoforum.org.kh

# ឧបសម្ព័ន្ធ

# បញ្ហាឆ្លងដែននៃការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីក្នុងតំបន់ទន្លេមេគង្គ

## ១. សារតា

ទន្លេមេគង្គ ជាទន្លេអន្តរជាតិហូរកាត់ប្រទេសចំនួន៦ដែលរួមមាន ប្រទេសចិន ភូមា ថៃ ឡាវ កម្ពុជា និងវៀតណាម។ ប្រទេស ៤ ក្នុងចំណោមប្រទេសទាំងនេះ រួមមានប្រទេសកម្ពុជា បានចុះកិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៃអាងទន្លេមេគង្គនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៩៥។[៨] នេះបញ្ជាក់យ៉ាងច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវឆន្ទៈការពារទន្លេមេគង្គឱ្យមាននិរន្តភាព និងចូលរួមសហប្រតិបត្តិការគ្រប់កម្មវិធីអភិវឌ្ឍន៍ទាំងអស់ ដែលរួមមានវិស័យថាមពលលើការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេគង្គ។ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី ដែលបានលើកឡើងនៅតាមដងទន្លេមេនៃទន្លេមេគង្គទាំង១១ គឺជាមាតិកាដ៏សំខាន់មួយ នៃរបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រោះវាបានបង្ហាញភាពជាប់ទាក់ទងគ្នាអំពីហានិភ័យនៃបរិស្ថាន និងសង្គម និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីធានានូវការកាត់បន្ថយភាពក្រីក្រ និងការកាត់បន្ថយផលប៉ះពាល់បរិស្ថានឱ្យឋិតក្នុងកំរិតអប្បបរិមា។

ទន្លេមេគង្គ និងទន្លេសាប គឺជាទន្លេដែលមានប្រព័ន្ធជាប់ទាក់ទងគ្នាយ៉ាងជិតស្និទ្ធដែលត្រូវបានទទួលស្គាល់តាំងពីបុរាណកាលមក។ ការផ្លាស់ប្ដូរលំហូរនៃទន្លេមេគង្គ គឺប៉ះពាល់ដល់ការផ្លាស់ប្ដូរប្រព័ន្ធអេកូឡូស៊ីនៃតំបន់បឹងទន្លេសាប ជាពិសេស គឺការចរាចរត្រីពីទន្លេសាបទៅទន្លេមេគង្គ និងពីទន្លេមេគង្គត្រឡប់មកទន្លេសាបវិញ។ ទន្លេសាបត្រូវបាន ទទួលស្គាល់ថាជាតំបន់ដែលមានធនធានជលផលទឹកសាបធំបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងទន្លេមេគង្គជាទន្លេជាប់ លំដាប់ថ្នាក់ទី២លើពិភពលោកដែលសំបូរដោយជីវចំរុះក្នុងទន្លេ។ ត្រីចំនួន៧០%ធ្វើបំលាស់ទីពីទន្លេសាបទៅទន្លេមេគង្គ រួចពីទន្លេមេគង្គត្រឡប់មកទន្លេសាបវិញ[៩]។ តាមរយៈការព្យាករណ៍ជលសាស្ត្រនៃប្រព័ន្ធទន្លេមេគង្គនេះឃើញថា ត្រីមានចំនួនកាន់តែច្រើនឡើងៗនៅតំបន់ទន្លេមេគង្គក្រោមដោយក្នុងនោះរួមមាន ២៨៤ ប្រភេទត្រូវបានរកឃើញនៅតំបន់ទន្លេសាប ២១៤ ប្រភេទនៅទន្លេសេកុង ២០៤ ប្រភេទនៅទន្លេមេគង្គពីខេត្តស្ទឹងត្រែងមកក្រចេះ ២០៤ ប្រភេទទៀតនៅទន្លេស្រែពក និង ១៣៣ ប្រភេទនៅទន្លេសេសាន[១០]។ ប្រជាជនប្រហែលជា ១.២៥លាននាក់ដែលរស់នៅជុំវិញបឹងទន្លេសាបអាចរកចំណូលបានប្រហែល ២៣៣ លានដុល្លាក្នុងមួយឆ្នាំ ដោយក្នុងនោះរួមបញ្ចូលទាំងគ្រួសារក្រីក្របំផុតដែលពឹងផ្អែកផ្ទាល់ទៅលើធនធានក្នុងទឹកនៃទន្លេនេះ អាចរកចំណូលបានតិចជាង១ពាន់ដុល្លាក្នុងមួយឆ្នាំ[១១] ហើយប្រហែលជាជាង៧០%នៃប្រជាជនកម្ពុជាពឹងអាស្រ័យលើធនធាននេះក្រោមរូបភាពជាអាហារ ប្រាក់ចំណូល និងជាសំណាញ់សុវត្ថិភាពតាមកម្រិតផ្សេងៗគ្នា[១២]។

---

[៨] គណៈកម្មការទន្លេមេគង្គ ១៩៩៥។ កិច្ចព្រមព្រៀងស្ដីពីកិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៃអាង ទន្លេមេគង្គ ៥ មេសា ១៩៩៥។

[៩] គណៈកម្មការទន្លេមេគង្គ ២០១០។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ។ http://www.mrcmekong.org/ish/SEA.htm

[១០] របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ.គណៈកម្មការទន្លេមេគង្គ ទំព័រទី១០ ខែតុលា ឆ្នាំ២០១០។

[១១] ហាប ណាវី, សេង លាង, ជឿន ភក្តី អ. ២០០៦។ សេដ្ឋកិច្ចសង្គម និងតម្លៃជីវភាពនៃជលផលបឹងទន្លេសាប។ ស្ថាប័នត្រីពិភព លោក និងស្ថាប័នអភិវឌ្ឍន៍និងស្រាវជ្រាវត្រីទឹកសាប។ ភ្នំពេញ កម្ពុជា ទំព័រទី ២៤។ (បកប្រែក្រៅផ្លូវការ)

[១២] គណៈកម្មការទន្លេមេគង្គ ២០១០។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ។ http://www.mrcmekong.org/ish/SEA.htm

បើមើលទៅលើបទពិសោធន៍នៃការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំនៅលើពិភពលោកវិញឃើញថា ទំនប់ទាំងនោះបាននាំមកនូវផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី និងប្រជាពលរដ្ឋ។ តាមរយៈការស្រាវជ្រាវរបស់គណៈកម្មការ ពិភពលោកស្តីទីទំនប់លើទំនប់ខ្នាតធំចំនួន ១២៥ ជុំវិញពិភពលោកបានបង្ហាញពីផលខាតជាជាងផលចំណេញដែលបានពីការអភិវឌ្ឍន៍នេះ ទាំងនោះរួមបញ្ចូលនូវសំណងការខូចខាតទៅដល់បរិស្ថាន និងការរើទីលំនៅរបស់ប្រជាជនដែលរងផលប៉ះពាល់ ព្រមទាំងការបែងចែកផលប្រយោជន៍មិនស្មើគ្នារវាងអ្នកប្រើប្រាស់ថាមពល និងអ្នករងផលប៉ះពាល់។ ជាងនេះទៅទៀត ភាពលំបាកក្នុងការធ្វើឱ្យមានតម្លាភាព និងគណនេយ្យភាពចំពោះកិច្ចពិគ្រោះយោបល់ជាសាធារណៈ[១៣]។ ជាក់ស្តែង ចំពោះគម្រោងសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាបូរីដែលជាទំនប់ដំបូងបង្អស់ដែលគ្រោងនឹងសាងសង់នៅតាមដងទន្លេមេនៃទន្លេមេគង្គ ត្រូវបានប៉ាន់ប្រមាណថានឹងត្រូវបានរាំងនូវបំលាស់ទីត្រីពី ២៣-១០០ ប្រភេទ ដែលទាំងនេះបញ្ជាក់ថាធនធានជលផលនៅប្រទេសកម្ពុជានឹងត្រូវបានថយចុះ។ ជាងនេះទៅទៀត ទំនប់នេះនឹងគំរាមកំហែងដល់ការបាត់បង់ពូជត្រី ៤១ ប្រភេទ ដែលក្នុងនោះត្រីរាជជាប្រភេទកម្រនៅទន្លេមេគង្គកម្ពុជានឹងត្រូវបាត់បង់។ រីឯលំហូរដីល្បាប់ដែលមានសារៈសំខាន់ក្នុងការនាំមកនូវជីជាតិសំរាប់ទ្រទ្រង់តំបន់ដីសើមប្រទេសកម្ពុជា និងប្រព័ន្ធបឹងទន្លេសាបនឹងត្រូវថយចុះដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ផលិតភាពកសិកម្មក្នុងប្រទេសកម្ពុជា[១៤]។

ក្នុងរបាយការណ៍ផែនការអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ បានបង្ហាញថា "គោលដៅរាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីធានា និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយចីរភាពដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកំពស់កម្រិតជីវភាពប្រជាជន ការរីកចំរើននៃសេដ្ឋកិច្ចសង្គម ក៏ដូចជាសហគមន៍នេសាទ[១៥]"។ ប៉ុន្តែ ប្រសិនបើទំនប់សាយ៉ាបូរី ត្រូវបានអនុម័តឱ្យសាងសង់ដោយរាជរដ្ឋាភិបាលទាំង៤ នោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាអាចបកស្រាយបានថាជាបញ្ហាប្រឈមមួយ។ នេះដោយសារផលប៉ះពាល់ដ៏ធំធេងទៅលើធនធានជលផលទាំងទន្លេមេគង្គ និងទន្លេសាប ជាពិសេសគឺប្រជាពលរដ្ឋក្រីក្រដែលពឹងអាស្រ័យលើធនធានទាំងនេះ។

ក្រៅពីវិស័យថាមពល និងជលផលដែលបានលើកឡើងនៅក្នុងរបាយការណ៍ផែនការអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ បញ្ហាផលប៉ះពាល់ឆ្លងដែនករណីដូចជាការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីដែលគ្រោងសាងសង់នៅតាមដងទន្លេមេនៃទន្លេមេគង្គ គឺមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ផែនការនេះ និងលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំកំពូលៗរបស់រាជរដ្ឋាភិបាលថ្នាក់ជាតិ តាមរយៈវេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ក៏ដូចជាកិច្ចប្រជុំរបស់គណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍។ ដូច្នេះបញ្ហាអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេនៃមេគង្គគួរតែត្រូវបានលើកយកមកពិចារណា និងធ្វើការសម្រេចចិត្តនៅក្នុងកិច្ចប្រជុំថ្នាក់ជាតិ។

ជាងនេះទៅទៀត បើតាមក្របខ័ណ្ឌច្បាប់ទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន យើងឃើញថាប្រទេសកម្ពុជាបានអនុម័តច្បាប់ជាច្រើនដែលបង្ហាញពីបច្ចុប្បន្នកម្មនៃចលនាកំណែទម្រង់ច្បាប់។ ចាប់តាំងពីឆ្នាំ១៩៦៦-២០១១ ច្បាប់ទាំងនោះបានដើរតួនាទីយ៉ាងសំខាន់ក្នុងគម្រោងអភិវឌ្ឍន៍នានា។ ទោះបីជាច្បាប់ទាំងនោះដើរតួយ៉ាងសំខាន់ក៏ដោយ ក៏ប្រទេសកម្ពុជានៅតែប្រឈរមុខ

[១៣] គណៈកម្មការស្តីពីទំនប់ពិភពលោក, ខែធ្នូ ឆ្នាំ ២០០១។ ទំនប់ និងការអភិវឌ្ឍន៍ : គោលការណ៍ថ្មីសំរាប់ការសម្រេចចិត្ត។

[១៤] គណៈកម្មការទន្លេមេគង្គ ២០១១។ របាយការណ៍ពិនិត្យគម្រោងទំនប់សាយ៉ាបូរីដែលគ្រោងសាងសង់នៅលើទន្លេមេគង្គ នៃកិច្ចពិគ្រោះយោបល់ជាមុន ថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១១។ (ផ្សាយចេញក្នុងថ្ងៃទី ២៤ ខែមិនា ឆ្នាំ ២០១១)

[១៥] ផែនការអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣, ខែមិថុនា ឆ្នាំ ២០១០។ ជំពូក៤ គោលនយោបាយ និង សកម្មភាពអទិភាព ២០០៩-២០១៣ ទំព័រ ទី ២១៦។

នឹងភាពមិនគ្រប់ជ្រុងជ្រោយក្នុងការអនុវត្តន៍ច្បាប់ទាំងនោះឱ្យមានប្រសិទ្ធិភាព ជាក់ស្តែងដូចជាច្បាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និងច្បាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺមិនទាន់បានរៀបចំឱ្យស្របតាមស្តង់ដារអន្តរជាតិឡើយ ។

## ២. អនុសាសន៍

អាស្រ័យដោយការព្រួយបារម្ភដែលបានលើកឡើងខាងលើ និងដើម្បីពង្រឹងការប្តេជ្ញាចិត្តក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការចូលរួមជាសាធារណៈចំពោះអភិបាលកិច្ច អង្គការមិនមែនរដ្ឋាភិបាល នៅប្រទេសកម្ពុជាសូមអំពាវនាវដល់រាជរដ្ឋាភិបាលដូចខាងក្រោម:

១. រាជរដ្ឋាភិបាលកម្ពុជាគប្បីធ្វើការពិចារណា និងទទួលយកនូវលទ្ធផល និងអនុសាសន៍នៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្ររបស់គណៈកម្មការទន្លេមេគង្គ ចំពោះដំណើរការនៃការសាងសង់ទំនប់វារីអគ្គិសនី ដែលគ្រោងសាងសង់នៅតាមដងទន្លេមេនៃទន្លេមេគង្គ ដែលបានចង្អុលបង្ហាញពីហានិភ័យដ៏សម្បើម និងផលប៉ះពាល់ ដែលបណ្តាលមកពីការសាងសង់ទំនប់ទាំង១១នេះ និងអនុសាសន៍ឱ្យពន្យាពេលយ៉ាងហោច១០ឆ្នាំ ដើម្បីធ្វើការសិក្សាស្រាវជ្រាវបន្ថែម ។

២. របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃទំនប់សាយ៉ាប៊ូរីនេះគឺមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយក្នុងរបាយការណ៍មិនបានបញ្ចូលនូវផលប៉ះពាល់ឆ្លងដែន ឬក៏សំណងដល់ប្រទេសកម្ពុជាដែលរំពឹងថានឹងត្រូវរងផលប៉ះពាល់ពីគម្រោងនេះ ។ ជាងនេះទៀត ការពិគ្រោះយោបល់ជាសាធារណៈដែលមានតម្លាភាពលើរបាយការណ៍នេះនៅក្នុងប្រទេសកម្ពុជាក៏មិនទាន់មានដែរ ។ ឧរាបណាគ្មានភស្តុតាងជាក់លាក់ដើម្បីបង្ហាញពីការវិភាគការចំណាយ និងផលចំណេញដោយរួមបញ្ចូលទាំងផលប្រយោជន៍ និងសំណងយុត្តិធម៌ជូនចំពោះសហគមន៍រងផលប៉ះពាល់ដោយសារការសាងសង់ទំនប់នេះទេ ផែនការសាងសង់ទំនប់តាមដងទន្លេមេនៃទន្លេមេគង្គពុំគួរមានការឯកភាពពីរាជរដ្ឋាភិបាលកម្ពុជាដើម្បីឱ្យសាងសង់ឡើយ ជាពិសេសទំនប់សាយ៉ាប៊ូរី ។

៣. គួរមានការផ្សព្វផ្សាយជម្រើសថាមពលបែបវិមជ្ឈការ និងនិរន្តរភាពចំពោះប្រទេសតាមដងទន្លេមេគង្គដោយការពង្រឹង គោលនយោបាយថាមពល និងការបង្កើតការលើកទឹកចិត្តដើម្បីឱ្យអ្នកវិនិយោគទុនផ្នែកនេះមានការប្រកួតប្រជែងយុត្តិធម៌ជាមួយក្រុមហ៊ុនទំនប់វារីអគ្គិសនីខ្នាតធំ តាមរយៈការដកចេញនូវរបាំងការវិនិយោគក្នុងពេលបច្ចុប្បន្ន និងដោយបង្កើតនូវគោលនយោបាយថាមពលដែលផ្អែកលើប្រសិទ្ធិផលការការពារបរិស្ថាន និងតម្រូវការប្រជាពលរដ្ឋដែលរស់នៅក្នុងអនុតំបន់ទន្លេមេគង្គ ។ ដោយសារការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំនៅប្រទេសកម្ពុជា ដែលឋិតនៅក្នុងតំបន់ត្រូពិចគឺអាចបញ្ចេញនូវបរិមាណមេតានច្រើន ដែលជាធាតុធ្វើឱ្យមានការកើនឡើងកំដៅផែនដី រាជរដ្ឋាភិបាលកម្ពុជា គួរតែជម្រុញឱ្យមានបច្ចេកវិទ្យាជម្រើសថាមពលដោយចីរភាពដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិច ដែលជាមូលហេតុនាំឱ្យមានផលប៉ះពាល់ដល់បម្រែបម្រួលអាកាសធាតុក៏ដូចជាការកើនឡើងកំដៅផែនដី ។

៤. បញ្ចូលភាពទាក់ទងគ្នារវាងទន្លេសាប និងទន្លេមេគង្គទៅក្នុងវិស័យជលផលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយផ្តោតលើបញ្ហាឆ្លងដែនដែលអាចកើតមានឡើង ប្រសិនបើមានការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេនៃទន្លេមេគង្គ ។ នេះដោយសារតែផលប៉ះពាល់ទាំងនោះអាចនឹងរីករាលដាលដល់តំបន់ឋបនីយជីវមណ្ឌលនៃបឹងទន្លេសាប ដែល

បានចុះព្រះរាជក្រឹតនៅខែធ្នូ ឆ្នាំ ២០០១ ដែលមានតំបន់ស្នូលបីរួមបញ្ចូល ព្រែកទាល់ ២១.៣៤២ហិចតា បឹងទន្លេឆ្មារ ១៤.៥៦០ហិចតា និងស្ទឹងសែន ១៤.៥៦០ហិចតា[១៦] ព្រមទាំងតំបន់ផ្សេងទៀតនៃទន្លេសាប។

៥. គួរតែមានគោលការណ៍ច្បាប់គ្រប់គ្រាន់សំរាប់គម្រោងអភិវឌ្ឍន៍។ រាជរដ្ឋភិបាលគួរតែអនុម័តច្បាប់ដែលទាក់ទងនឹងច្បាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ក៏ដូចជាច្បាប់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីត្រួតពិនិត្យ និងតាមដានសំរាប់គ្រប់គម្រោងអភិវឌ្ឍន៍ទាំងអស់។ ក្រៅពីនោះទៀត ស្នើសុំឱ្យរាជរដ្ឋាភិបាលប្រកាន់ជំហរឯករាជ្យ និងប្តេជ្ញាចិត្ត ដើម្បីអនុវត្តន៍នូវច្បាប់ទាំងអស់នោះ។

**ព័ត៌មានទំនាក់ទំនង**

សម្រាប់ព័តិមានបន្ថែមចំពោះសេចក្តីថ្លែងការនេះ សូមទាក់ទង:


**សម្ព័ន្ធទន្លេកម្ពុជា (RCC)**

លោក **ឈិត សំអាត** នាយកប្រតិបត្តិនៃវេទិកាមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF)

ទូរស័ព្ទ : (៨៥៥) ២៣ ២១៤ ៤២៩

អ៊ីម៉ែល : ngoforum@ngoforum.org.kh

គេហទំព័រ : http://www.ngoforum.org.kh

អាស័យដ្ឋាន : ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ ស/ង ទួលទំពូង១, ខ័ណ្ឌ ចំការមន ភ្នំពេញ ប្រអប់សំបុត្រ ២២៩៥

លោក **មៀច មាន** អ្នកសម្របសម្រួល អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង (3SPN)

ទូរស័ព្ទ : (៨៥៥) ៧៥ ៩៧៤ ១១២

អ៊ីម៉ែល : sesan@online.com.kh

គេហទំព័រ : http://3spn.cfsites.org

អាស័យដ្ឋាន : ស្រុកបានលុង ខេត្តរតនះគីរី

លោក **ទេព បុ៊ណ្ណារិទ្ធ** នាយកប្រតិបត្តិ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA)

ទូរស័ព្ទ : (៨៥៥) ២៣ ៨៨១ ៦១៣

អ៊ីម៉ែល : cepa@cepa-cambodia.org

គេហទំព័រ : www.cepa-cambodia.org

អាស័យដ្ឋាន : ផ្ទះលេខ ៥១ អេហ្វ ផ្លូវ ២១០ ស/ង ទឹកល្អក់៣ ខ័ណ្ឌទួលគោក ភ្នំពេញ ប្រអប់សំបុត្រ ១៤៨៦

លោក **ឱម សាវ៉ាត** នាយកប្រតិបត្តិ សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល


[១៦] http://www.wcscambodia.org/saving-wild-places/tonle-sap-lake-and-floodplain/the-tonlesap-bioshpere-reserve.html

ទូរស័ព្ទ : (៨៥៥) ២៣ ៩៩២ ០៤៤

អ៊ីម៉ែល : savath@fact.org.kh

គេហទំព័រ : www.fact.org.kh

អាស័យដ្ឋាន : ផ្ទះលេខ ២១៥ ផ្លូវ ១៥០ ស/ង ទឹកល្អក់២ ខ័ណ្ឌទួលគោក ភ្នំពេញ ប្រអប់សំបុត្រ ៤២០ (CCC)

លោក **ស៊ុន យូរ៉ា** នាយកប្រតិបត្តិ អង្គការភូមិខ្ញុំ

ទូរស័ព្ទ : (៨៥៥) ២៣ ៦៣ ៥៥ ១៦៧

អ៊ីម៉ែល : myvillage@mvicambodia.org

គេហទំព័រ : www.mvicambodia.org

អាស័យដ្ឋាន : ផ្ទះលេខ ៧៨ អា ផ្លូវ ១៣៥ ស/ង ទួលទំពូង១, ខ័ណ្ឌ ចំការមន ភ្នំពេញ ប្រអប់សំបុត្រ ៤៦៦ (CCC)

# សេចក្តីថ្លែងការណ៍រួមរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល
# ចំពោះសេចក្តីព្រាងលើកទី២នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

យើងខ្ញុំជាអង្គការសង្គមស៊ីវិល ដែលរួមមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាសូមសម្តែងនូវការកោតសរសើរដ៏ខ្ពង់ខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងសង្គមស៊ីវិល ដែលជាកត្តាសំខាន់មួយនៅក្នុងការអភិវឌ្ឍកម្ពុជាពីប្រទេសមួយដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម មកជាប្រទេសកំពុងអភិវឌ្ឍន៍ ប្រកបដោយសន្តិភាពយ៉ាងរស់រវើក។ បើទោះបីជាមានគំនិតយោបល់ខុសគ្នាមួយចំនួនកន្លងមកក៏ដោយ តាមរយៈកិច្ចពិភាក្សាបែបស្ថាបនា រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលមានចំណុចឯកភាពគ្នាដែលទទួលបានលទ្ធផលជាច្រើនប្រកបដោយការយោគយល់គ្នា និងសហប្រតិបត្តិការល្អ។

ទោះបីជាយ៉ាងណា សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បង្ហាញនូវការធ្វើដំណើរមួយចាកពីវិថីដ៏ជោគជ័យនេះ។ យើងខ្ញុំទាំងអស់គ្នាមានការបារម្ភយ៉ាងខ្លាំងអំពីសេចក្តីព្រាងលើកទីពីរនៃច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានផ្តល់សិទ្ធិអំណាចយ៉ាងទូលំទូលាយដល់អាជ្ញាធរ ដើម្បីត្រួតត្រាទៅលើសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការប្រមូលផ្តុំ និងអនុវត្តសិទ្ធិរបស់ពួកគេ។ សិទ្ធិទាំងនេះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា៣១, ៣៥ និង ៤២) និងសន្ធិសញ្ញាអន្តរជាតិដូចជាសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា២ វាក្យខណ្ឌទី១) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា១៤ និង ២២) ដែលប្រទេសកម្ពុជាបានចុះហត្ថលេខា។

អង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជាមានលក្ខណៈចំរុះ និងច្រើនប្រភេទរួមមានអង្គការ សមាគម និងក្រុម ហើយមានចំណាប់អារម្មណ៍ និងគោលជំហរផ្សេងៗគ្នា។ លក្ខណៈចំរុះនេះគឺជាភាពខ្លាំងរបស់អង្គការសង្គមស៊ីវិល និងបង្ហាញអំពីទស្សនៈទានសំខាន់ៗគ្រប់មជ្ឈដ្ឋាន ដើម្បីរួមចំណែកក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ឥឡូវនេះយើង ទាំងអស់គ្នាបាននាំមកនូវសំលេងរួមពីគ្រប់មជ្ឈដ្ឋាននៃអង្គការសង្គមស៊ីវិលនានា ដែលកន្លងមកមានទស្សនៈផ្សេងៗគ្នា និងមានការឆ្លើយតបជាច្រើនចំពោះសេចក្តីព្រាងច្បាប់នេះ។ មានអង្គការមួយចំនួនបានមានជំហរមុតមាំថាមិនចាំបាច់ឱ្យមានច្បាប់នេះឡើយ ហើយអង្គការមួយចំនួនទៀតបានសម្រេចចូលរួមពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាល ដើម្បីកែលំអរសេចក្តីព្រាងច្បាប់នេះ និងមានអង្គការមួយចំនួនទៀតបានបញ្ចុះបញ្ចូលឱ្យដាក់បញ្ចូលនូវតម្រូវការជាក់លាក់នៅក្នុងច្បាប់នេះ។ អង្គការទាំងអស់នេះ បានបន្តការពិភាក្សាជាបន្តបន្ទាប់ដោយគោរពនូវទស្សនៈគ្នាទៅវិញទៅមក ដែលនេះគឺជាអ្វីដែលហៅថាប្រជាធិបតេយ្យ។

ថ្ងៃនេះ យើងទាំងអស់គ្នាមានជំហររួម។ បើទោះបីជាយើងមានវិធីសាស្រ្តផ្សេងៗគ្នាក្នុងការរកដំណោះស្រាយការព្រួយបារម្ភជុំវិញសេចក្តីព្រាងច្បាប់នេះក៏ដោយ ក៏យើងបានឯកភាពគ្នាថា សេចក្តីព្រាងច្បាប់ដែលស្ថិតក្នុងទម្រង់បែបនេះ គឺមិនអាចទទួលយកបានឡើយ។

យើងខ្ញុំយល់ថា រដ្ឋមួយប្រកបដោយអធិបតេយ្យភាពដូចជាប្រទេសកម្ពុជា មានកាតព្វកិច្ចធានាឱ្យមាននូវការប្រកាសដាក់ឱ្យប្រើប្រាស់ច្បាប់ បទដ្ឋានគតិយុត្តិ និងការអនុវត្តនានាផ្អែកលើគោលការណ៍ប្រជាធិបតេយ្យអន្តរជាតិ។ យ៉ាងណាមិញ ដំណើរការនៃការអនុម័តច្បាប់ត្រូវគោរពគោលការណ៍ប្រជាធិបតេយ្យ។ លើសពីនេះទៀត ច្បាប់មិនត្រូវរំលោភទៅលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដែលរួមមានសិទ្ធិសេរីភាពក្នុងការបង្កើត ចូលរួមនៅក្នុងសមាគម និងសេរីភាពក្នុងការបញ្ចេញមតិយោបល់។ តាមពិតការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជានៅក្នុងរយៈពេលជាច្រើនឆ្នាំ មិនអាចកើតឡើងបាននោះទេប្រសិនបើមិនមានការប្រមូលផ្តុំ

និងបញ្ចេញមតិយោបល់ដោយសេរី។ ការអភិវឌ្ឍសង្គមប្រកបដោយជោគជ័យទូទាំងសកលលោក គឺអាស្រ័យដោយការបើកចំហរបស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋរបស់ខ្លួន។

សេចក្តីព្រាងលើកទីពីរនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមាននៅក្នុងទម្រង់បច្ចុប្បន្ននេះ ពុំបានគោរពសិទ្ធិជាមូលដ្ឋានទាំងនេះឡើយ។

យើងសូមគូសបញ្ជាក់អំពីក្តីបារម្ភធំៗចំនួនបី នៅក្នុងសេចក្តីព្រាងច្បាប់បច្ចុប្បន្ននេះដូចខាងក្រោម:

១. ការចុះបញ្ជីត្រូវធ្វើឡើងជាកាតព្វកិច្ច និងមានភាពស្មុគ្រស្មាញ មិនមែនដោយស្ម័គ្រចិត្ត និងមិនមានភាពងាយស្រួល

២. ពុំមានដំណើរការប្តឹងឧទ្ធរណ៍សម្រាប់ការបដិសេធទៅលើការចុះបញ្ជី

៣. ពុំមានការកំណត់និយមន័យទៅលើវាក្យស័ព្ទសំខាន់ៗនៅក្នុងច្បាប់ និងផ្នែកជាច្រើនពុំមានភាពច្បាស់លាស់

មាត្រា៦ បានចែងអំពីបញ្ញតិហាមឃាត់នៃសេចក្តីព្រាងច្បាប់លើកទីពីរនេះ នៅតែមិនមានការផ្លាស់ប្តូរ។ វានៅតែបន្តហាមឃាត់សកម្មភាពរបស់អង្គការ សមាគមដែលមិនបានចុះបញ្ជី។ ការចុះបញ្ជីគឺជាកាតព្វកិច្ចចាំបាច់ ហើយអង្គការដែលមិនបានចុះបញ្ជីនឹងត្រូវហាមឃាត់។ តម្រូវការនៃការចុះបញ្ជីជាកាតព្វមាននៅក្នុងច្បាប់នេះមានការរិតត្បិតជាច្រើនលើ សិទ្ធិសេរីភាពរបស់សមាគមដែលបំពានលើគោលការណ៍ នាដែលប្រទេសកម្ពុជាបានសន្យា គោរព និងអនុវត្តតាមមាត្រា២២ នៃកត្តិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ យោងតាមមាត្រា ២២ ក៏ដូចជាកត្តិការសញ្ញាជាច្រើនទៀតបានចែងថា សេរីភាពក្នុងការបង្កើតសមាគមគឺជាសិទ្ធិជាមូលដ្ឋាន ដែលមិនជាអ្វី ដែលចាំបាច់ឱ្យរដ្ឋាភិបាលផ្តល់ដល់ប្រជាពលរដ្ឋនេះទេ។

មាត្រា១៧ និង៣២ ដែលចែងអំពីការដាក់ពាក្យចុះបញ្ជី និងសំណើរចុះអនុសារណៈស្តីពីការយោគយល់គ្នា គឺមានកង្វះខាតក្នុងការការពារសិទ្ធិ (បទដ្ឋានជាក់លាក់សំរាប់ការពិនិត្យឡើងវិញ និងការបដិសេធនៃការចុះបញ្ជី និងសិទ្ធិក្នុងការប្តឹងតវ៉ាទៅតុលាការដែលមានឯករាជ្យ និងមានសមត្ថភាព)។ មាត្រាទាំងអស់នេះធ្វើឱ្យឱនភាពនៃមាត្រា ៦៥ នៃក្រមរដ្ឋប្បវេណី។

ក្នុងអំឡុងពេលនៃដំណើការពិគ្រោះយោបល់អង្គការសង្គមស៊ីវិល បានគូសបញ្ជាក់យ៉ាងច្បាស់លាស់អំពីចំណុចខ្សោយទាំងនេះ ប៉ុន្តែហាក់ដូចជាពុំបានលទ្ធផល។ យើងមានការខកចិត្តដែលសេចក្តីព្រាងច្បាប់លើកទីពីរនេះ ពុំបានដោះស្រាយក្តីបារម្ភធំៗទាំងនោះ ។

ដូច្នេះ យើងជាអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ដែលមានចុះហត្ថលេខាខាងក្រោម សូមអំពាវនាវជា សមូហភាពដោយការគោរពចំពោះរាជរដ្ឋាភិបាលកម្ពុជា ឱ្យធ្វើការពិចារណាឡើងវិញទៅលើសំណើសំខាន់ៗរបស់យើង និងបញ្ចូលសំណើរទាំងនោះទៅក្នុងសេចក្តីព្រាងច្បាប់លើកទីបី ។ យើង ក៏សូមស្នើសុំផងដែរ ឱ្យមានការចែករំលែកជាសាធារណៈនូវសេចក្តីព្រាងច្បាប់លើកទីបី មុនពេលសេចក្តីព្រាងច្បាប់នេះត្រូវបានឯកភាពដោយទីស្តីការគណៈរដ្ឋមន្ត្រី និងអនុម័តដោយរដ្ឋសភាជាតិ ។

អង្គការមិនមែនរដ្ឋាភិបាល និងសមាគមត្រៀមខ្លួនរួចជាស្រេចក្នុងគោលបំណងប្រើប្រាស់សិទ្ធិប្រជាធិបតេយ្យ ដើម្បីសម្តែងនូវការមិនពេញចិត្តរបស់យើងតាមរយៈមធ្យោបាយប្រជាធិបតេយ្យនិងមធ្យោបាយប្រកបដោយសន្តិភាពដទៃទៀត។

បញ្ជីអង្គការមិនមែនរដ្ឋាភិបាល និងសមាគមដែលគាំទ្រលើការព្រួយបារម្ភ និងជំហររួមដែលបានលើកឡើងក្នុងសេចក្តីថ្លែងការណ៍:

**A**
1. ADHOC
2. Asian Hope Organization
3. AIESEC in Cambodia
4. AMARA Organization
5. AAD Association
6. Asian Outreach Cambodia
7. ACR/Caritas Australia
8. AEC Cambodia
9. Actual Khmer Association for Development
10. American Friends Service Committee
11. Association for Human Resource Development and Health Education
12. AARR Organization
13. API Institute
14. Asia Cambodia Ministries
15. Alliance for Conflict Transformation
16. AFD Organization
17. ANAKOT KUMAR

**B**
18. BTF Organization
19. BNSD Organization
20. Buddhism Development Association and Supporting
21. Build Your Future Today Center
22. Bandos Komar
23. Baptis Missionary Association of the Philippines
24. Broederlijk Delen
25. Buddhism For Development Kampong Thom
26. Bayon Learning Tree
27. BCV

**C**
28. Cooperation Committee for Cambodia
29. Center for Advance Study
30. Christian Learning Circle for Development Association
31. Children Better Future
32. Catholic Relief Services/Cambodia Program
33. Cooperation for Social Services and Development
34. Cambodian Association for Orphan Development
35. Cambodian Vision in Development
36. Cambodian Community Development
37. Christian Reformed World Relief Committee-Cambodia
38. Cambodian Population Community
39. CIDC Organization
40. CWARS Organization
41. CESO Organization
42. CDA Organization
43. CUF Organization
44. CRDT Organization
45. Community Council for Development
46. Community Capacity Development-Kratie
47. Community Support Improve Development
48. Cambodian Union Federation
49. Cyclo Conversation and Careers Association
50. Community Poverty Reduction
51. Center for Development Service
52. Children Development Association
53. Cambodian League for the Promotion and Defense of Human Rights
54. Cambodian Youth Development Center
55. Cambodian Youth Development
56. Cambodian Rural Development Team
57. Cambodia Population Community
58. CWDA
59. Cambodian Development Veteran Association
60. Christian Center for Cambodia
61. Cambodian Health Education Development
62. COSECAM Organization
63. CNRO Organization
64. CEA Organization
65. CARAM Cambodia
66. Community for Transformation
67. CANDO Organization
68. CPR Organization
69. Cambodian Organization for Children and Development
70. Cambodia Center for Human Right
71. CSSD Organization
72. Cambodia Trust
73. Cambodian Association for Development of Economy Together
74. Cambodian Association for Orphan Development
75. Cambodian Community Development
76. CAFOD Organization
77. CLHO Organization
78. CCFD Organization
79. Cambodian Association for Development of Economy Together
80. CIVICUS
81. CDCAM
82. Cambodian Organization Women Support
83. Cambodian Human Rith Action Committee
84. Chetthor in Prey Veng
85. Children for Development Service
86. CCD Organization
87. CYDSO
88. Child Hope Organization
89. Cambodian Defenders Project
90. Cambodia Woman’s Development Agency

91. Child Rights Foundation
92. Cambodian Center for the Protection of Children Right
93. Child Assistance for Mobilization and Participation
94. Cambodian Hope Organization
95. CONCERN WorldWide
96. CDRCP Organization
97. Center for Development Service
98. Charity Foundation for Children
99. Cambodian Family Economic Development Association
100. Children and Life Association
101. Community for Transformation
102. Children Friend for Development
103. CJR Organization
104. CCPRC
105. CHHRA

**D**

106. Development in Partnership and Action
107. Don Bosco Foundation of Cambodia
108. Democratic Service Organization
109. DKK Organization
110. Dai Kou Kaksekor
111. DS Organization
112. Development in Cambodia
113. Drug Addict Releif Association of Cambodia
114. Development Organization for Children
115. Development Association Resource Economic
116. DARE Organization
117. DDSP Organization
118. Diakonia Cambodia

**E**

119. End Child Prostitution, Abuse and Trafficking in Cambodia
120. Education and Development of Cambodian Skills
121. Environment and Health Education
122. ECPAT-Cambodia
123. Epic Arts Cambodia
124. ETEA Foundation
125. East Meet West Foundation
126. Empowerment Advocates International

**F**

127. Far East Broadcasting Cambodia
128. Future of Khmer Children Organization
129. Family Economic Development Community for Cambodia
130. Federation for Integrated Development of Agriculture in Cambodia
131. Future of Khmer Children Organization
132. Farmer of Cambodia Organization
133. Fundamental Building Organization
134. Freedom Cambodia
135. Foundation for International Development/Relief
136. FH Cambodia
137. Foundation for Developing Cambodian Communities
138. Farmer Development Association
139. FIDAC Organization
140. FDCC Organization
141. Fundamental Building Organization
142. FOC Organization
143. Family In Development

**G**

144. Gender and Development for Cambodia
145. Gospel For Children Organization
146. Genesis Community of Transformation
147. Goutte D'eau-Cambodia
148. Generation Hope
149. Generous

**H**

150. HAPO Organization
151. Housing Rights Task Force
152. Human Inborn Freedom
153. Health Education
154. HAGAR International
155. HRECO Organization
156. Health Care Center for Children
157. Homeland (MPK)
158. Happy Tree
159. Human Resource Education Center Organization
160. HROTP
161.

**I**

162. Ideal Family Federation
163. Indigenous Community Support Organization
164. IDEA Association
165. Institute for Development of Education and Agriculture
166. Istituto per la Cooperazione allo Sviluppo
167. ICC Organization
168. Intervida Cambodia
169. Indratevi Association

**J**

170. Japan International Volunteer Centre
171. Japan Lay Missionary Movement

**K**

172. Khmer Cultural Development Institute
173. Khmer Vision for Development
174. KVD Organization
175. KMR Organization

176. Khmer Angkor Development Organization
177. KADRA Organization
178. Khmer Community for Agriculture Development
179. Komar Rikreay Association Center
180. KWRA organization
181. Komar Rik Reay
182. Kumar Ney Kdey Sangkheum
183. Kokkyo naki Kodomotachi
184. Khmer Kampuchea Krom for Human Right and Development
185. Khmer Kampuchea Krom Women Organization
186. Kumnit Thmey Organization
187. KKEV Cambodia

188. Khmer for Khmer Organization
189. Kone Kmeng Organization
190. Khmer Student Association for Social Development
191. Khmer Saving the Poor Children
192. KIND
193. KID
194. KYA
195. KKKHRA
**L**
196. Legal Aid of Cambodia
197. Life and Hope Association
198. Life New of Unity
199. Legal Support for Children and Women
200. Lighthouse Organization
201. Land Mind Disability Support
202. Live and Learn Environmental Education
203. IDA
**M**
204. Mekong Plus
205. Medical Teams International
206. My Village
207. Mennonite Central Committee
208. Mission of Generous Cambodia Alliance
209. Manos Unidas
210. Marist MISSION AUSTRALIA
211. M'lop Tapang
212. MEDECINCE DE L’SPORT CAMBODGE
**N**
213. NGO Forum on Cambodia
214. NGO CRC
215. NGO Education Partnership
216. Neak Poan Orgazation For development
217. National Prosperity Association
218. NOMAD Recherche et Soutien International
219. Non-Timber Forest Products
220. NGOs advocacy network
221. NGO DKKP
222. NLF Cambodia Organization
223. National Prosperity Association
224. New Initiative for Livelihood and Health
225. Nature and Youth Development Organization
**O**
226. Our Home Cambodia Organization
227. Operation Enfants du Cambodge
228. One World Action
229. OKADA Organization
230. Organization for Economic Cooperation and Development in Cambodia
**P**
231. People's Forum on Cambodia, Japan
232. Ponlok Khmer
233. Partners for Development/Cambodia
234. People Improvement Organization
235. People to people Diplomacy
236. Partnership for Development in Kampuchea
237. PADV Organization
238. PTEA TEUK DONG-Cambodia
239. Pioneering Partner in Cambodia
240. Prom Vihearthor
241. Phum Baitong
242. Protection of Juvenile Justice
243. PNKS Organization
244. Peace Family Organization
245. PDP
**Q**
**R**
246. Room to Read-Cambodia
247. READA Organization
248. Rescue Khmer Famers Organization
249. RCEDO Organization
250. Rural Aid Organization
251. Rural Community and Environment Development Organization
252. RiverKids Foundation
253. RKF Organization
254. RCSCD
255. Rain Water Organization
256. Rural Animal Health Development Organization
257. Rachna Strie Organization
258. Road Safety Coalition
**S**
259. Siem Reap NGO Advocacy Networks
260. Save the Earth Cambodia
261. SAO SARY FOUNDATION
262. Suo Sdei Cambodia Association
263. Sustainable Cambodia
264. SAFE HOUSE CENTER

265. SEA Organization STREY KHMER Organization
266. Sun Moon Organization
267. SSCA Organization
268. Sprouting Knowledge Orphans
269. Sustainable Social Organization
270. Support Rural Children Organization
271. Support Association for Rural Farmer
272. Santaphana Chivit Organization
273. Save Incapacity Teenagers
274. Sovann Phoum Organization
275. 3SPN Coalitions
276. SECEA Association
277. Sevakapea Komar
278. Street Families Center
279. Social Service of Cambodia
280. Saving Aid and Cambodia International Worker for Human Right

**T**

281. Tekdey Sovanaphum
282. This Life Cambodia
283. The Center of Miltenberg-Cambodia
284. The Lake Clinic
285. The Future for Cambodian Children
286. Tourism Federation (CTSWF)
287. Terra Renaissance in Cambodia
288. Terre de Hommes
289. TDSP Organization
290. The Center for Advanced Study
291. The Center of Miltenberg Cambodia
292. Takao Community Forestry Integrated Development Association
293. The Cambodian Woman’s crisis Center

**U**

**V**

294. Village Economic Support Organization
295. VSA Cambodia
296. Village Economic Support Organization
297. Vulnerable Children Assistant Organization

**W**

298. Women Association For Community Development
299. Women Service Organization
300. Welt Hunger Hilfe/German Agro Action
301. WED Cambodia
302. Worker's Information Center-WIC
303. World Toilet Organization
304. Welthungerhilfe Regional Office
305. WOSO Organization
306. WACD Organization
307. World Eight Direction Cambodia
308. Who Will Village
309. Welthaus Graz
310. World Vision Cambodia
311. Wathnak Pheap

**X**

**Y**

312. Youth With A Mission
313. Youth Resource Development Program
314. Youth for Peace
315. YOUTH WITH DISABILITIES FOUNDATION FOR EDUCATION AND EMPLOYMENT

**Z**

**ព័ត៌មានទំនាក់ទំនង:**

សម្រប់ព័ត៌មានបន្ថែមអំពីបញ្ហាដែលបានលើកឡើងនៅក្នុងឯកសារនេះ សូមទំនាក់ទំនង:

**អង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)**
លោក លុន បូរិទ្ធិ
នាយកប្រតិបត្តិ
គេហទំព័រ: www.ccc-cambodia.org
អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ ទួលទំពូង ១ ប្រអប់សំបុត្រលេខ ៨៨៥ ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ១៥៣/២១៦ ០០៩
ទូរសារលេខ: (៨៥៥-២៣) ២១៦ ០០៩
អ៊ីម៉ែល: info@ccc-cambodia.org

**អង្គការម៉េឌីខាំ (MEDiCAM)**
លោកវេជ្ជបណ្ឌិត ស៊ិន សុមុនី
នាយកប្រតិបត្តិ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៨៨០ ២៩១
ទូរសារលេខ: (៨៥៥-២៣) ៨៨០ ២៩២
អ៊ីម៉ែល: info@medicam-cambodia.org
គេហទំព័រ: www.medicam-cambodia.org
អាសយដ្ឋាន: ផ្ទះលេខ ៤ ផ្លូវលេខ ៥២២ ទួលគោក ប្រអប់សំបុត្រលេខ ១១៦៤ ភ្នំពេញ កម្ពុជា

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia)**
លោក ឈិត សំអាត
នាយកប្រតិបត្តិ
ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខ: (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល: ngoforum@ngoforum.org.kh
គេហទំព័រ: www.ngoforum.org.kh
អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

# គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល ដើម្បីតាមដាននូវ
# សូចនាកររបស់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

**NGO Committee for the Monitoring of 3rd CDCF Indicators**

សេចក្តីថ្លែងការណ៍ស្តីពីការតាមដានលើសូចនាករតាមដានរួមដែលបានអនុម័តដោយវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ក្នុងខែមិថុនា ឆ្នាំ២០១០ សម្រាប់កិច្ចប្រជុំលើកទី១៨នៃគណកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ ត្រូវបានចងក្រងដោយអង្គការ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងអាចទាញយកបានតាមរយៈគេហទំព័ររបស់អង្គការនេះគឺ http://www.ngoforum.org.kh/eng/core/dppdoc.php